ក្រសួងអធិការកិច្ច

Ministry of Inspection

## របាយការណ៍

# លទ្ធផលការងារ
# ឆ្នាំ២០២៤

## និងទិសដៅការងារឆ្នាំ២០២៥

**2024 - 2025**



# មាតិកា


មាតិកា ..... i

អារម្ភកថា .....

ជំពូក ១. សេចក្តីផ្តើម ..... ៣

ជំពូក ២. លទ្ធផលការងារ ..... ៥

២.១. ការងារអធិការកិច្ច ..... ៥

២.១.១. ការអនុវត្តតួនាទី ភារកិច្ច ..... ៦

២.១.២. ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ..... ៧

២.១.៣. គម្រោងសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ..... ៧

២.១.៤. អធិការកិច្ចតាមបណ្តឹង ..... ៨

២.១.៥. ការចាត់វិធានការជំរុញការកែលម្អចំណុចខ្វះខាត ..... ៩

២.២. ការងារតាមដានការអនុវត្តច្បាប់ ..... ១០

២.២.១. អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ..... ១០

២.២.២. អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ..... ១១

២.២.៣. បទបញ្ជារបស់នាយករដ្ឋមន្ត្រី ..... ១២

២.៣. ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ..... ១២

២.៤. ការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ ..... ១៣

២.៤.១. ការអប់រំផ្សព្វផ្សាយច្បាប់ ..... ១៣

២.៤.២. ការងារវេទិកាសាធារណៈ ..... ១៥

២.៥. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ..... ១៥

២.៥.១. សេចក្តីសម្រេច និងប្រកាស ..... ១៦

២.៥.២. ច្បាប់ស្តីពីអធិការកិច្ច ..... ១៦

២.៥.៣. អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច ..... ១៧

២.៦. ការជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន ..... ១៧

២.៦.១. ការងាររដ្ឋបាល ..... ១៧

២.៦.២. ការងារបុគ្គលិក និងធនធានមនុស្ស ..... ១៨

២.៦.៣. ការងារហិរញ្ញវត្ថុ និងលទ្ធកម្ម ..... ២១

២.៦.៤. ការងារផែនការ និងស្ថិតិ ..... ២២

២.៦.៥. ការងារសវនកម្មផ្ទៃក្នុង ..... ២៤

២.៦.៦. ការងារវិទ្យាស្ថានជាតិអធិការកិច្ច ..... ២៤

២.៧. ការងារសហប្រតិបត្តិការ និងភាពជាដៃគូ........................................................................២៥
២.៧.១. ការជួបសម្តែងការគួរសម និងចូលរួមពិធីផ្សេងៗ ........................................................ ២៥
២.៧.២. ដំណើរទស្សនកិច្ច............................................................................................... ២៦
២.៧.៣. ការទទួលគណៈប្រតិភូដៃគូសហប្រតិបត្តិការ ............................................................២៧
២.៧.៤. សហប្រតិបត្តិការ និងភាពជាដៃគូ..........................................................................២៧
២.៨. ការងារបរិវត្តកម្មឌីជីថល...............................................................................................៣០
២.៩. ការងារផ្សេងៗ.......................................................................................................... ៣២
២.៩.១. ការងារថ្នាក់ដឹកនាំ ..............................................................................................៣២
២.៩.២. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និង FMIS.......................................................៣២
២.៩.៣. ការកែទម្រង់រដ្ឋបាលសាធារណៈ...........................................................................៣៣
២.៩.៤. ការងារយេនឌ័រ ...................................................................................................៣៣
២.៩.៥. ការងារក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួង.......................................... ៣៤
២.៩.៦. ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង......................................................... ៣៤
២.៩.៧. ការងារអន្តរវិស័យ ................................................................................................ ៣៤
២.៩.៨. ការងារផ្សេងទៀត................................................................................................. ៣៦
ជំពូក ៣. បញ្ហាប្រឈម ........................................................................................................ ៣៦
ជំពូក ៤.ទិសដៅ.................................................................................................................៣៧
៤.១. ការអនុវត្តយុទ្ធសាស្ត្រព៤ជ៤ ........................................................................................ ៣៧
៤.២. ការពង្រឹងការងារអធិការកិច្ច ........................................................................................៣៩
៤.៣. ការពង្រឹងការងារតាមដានការអនុវត្តច្បាប់......................................................................៣៩
៤.៤. ការពង្រឹងការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ..................................................៤០
៤.៥. ការពង្រឹងការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ ............................................ ៤១
៤.៦. ការជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត ........................................................................៤២
៤.៧. ការជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន.............................................................................៤៣
៤.៨. ការជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ..................................................................៤៥
៤.៩. ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ..........................................................................៤៦
៤.១០. ការងារផ្សេងៗ ........................................................................................................៤៧
៤.១០.១. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និង FMIS ...................................................... ៤៧
៤.១០.២. ការងារយេនឌ័រ .................................................................................................៤៨

៤.១០.៣. ការងារចងសម្ព័ន្ធមេត្រីភាព ..................................................................... ៤៨
៤.១០.៤. ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង ..................................................... ៤៨
៤.១០.៥. ការងារក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួង ........................................... ៤៨
**ជំពូក ៥. សេចក្តីសន្និដ្ឋាន** ..................................................................................... ៤៨



# អារម្ភកថា

## ឯកឧត្តម សុខ សូកេន
## រដ្ឋមន្ត្រីក្រសួងអធិការកិច្ច

ព្រះរាជាណាចក្រកម្ពុជាក្រោមម្លប់បារមីរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះមហាក្សត្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងក្រោមម្លប់ដ៏ត្រជាក់ នៃសន្តិភាព ដែលបានមកពីយុទ្ធសាស្ត្រឈ្នះ-ឈ្នះ របស់អគ្គមគ្គុទ្ទេសក៍ឯក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កម្ពុជាបានក្លាយទៅជារដ្ឋមួយដែលមានរក្សាបាននូវឯករាជ្យ បូរណភាពទឹកដី អធិបតេយ្យ-ភាពពេញលេញ ធ្វើឱ្យប្រជាជនកម្ពុជាមានសិទ្ធិសេរីភាពបរិបូណ៌ និងជីវភាពកាន់តែធូរជារ រស់នៅក្នុងសន្តិភាព និងសុភមង្គល។ ក្រោយពីរស់រានមានជីវិតឡើងវិញពីសង្គ្រាម សោកនាដកម្ម និងវិនាសកម្ម នៃរបបប្រល័យពូជសាសន៍កម្ពុជា បានប្រែក្លាយពីប្រទេសមួយ ក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោក មកជាប្រទេសមានចំណូលមធ្យម កម្រិតទាប និងឈានបន្តទៅជាប្រទេស ដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ម៉ឺងម៉ាត់ និងប្រកបដោយចក្ខុវិស័យវែងឆ្ងាយប្រាកដនិយមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បី**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយបន្តផ្តោតជាសំខាន់លើរបៀបវារៈជាតិ **"ប្រសិទ្ធភាពសមិទ្ធកម្ម"** ដែលកំណត់សូចនាករ និងក្របខ័ណ្ឌច្បាស់លាស់ តាមរយៈការបន្តអភិវឌ្ឍ**អភិក្រមទាំង ៥ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** និង**អភិក្រម "ជីវភាពនៃ ប្រព័ន្ធតួអង្គតែមួយ"** ព្រមទាំងកំណត់យក**អាទិភាពគន្លឹះ៥ មនុស្ស ផ្លូវ ភ្លើង ទឹក និងបច្ចេកវិទ្យា** និងបានកំណត់ គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ព្រមទាំងយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូល ការកសាងជាតិ និងការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព។ ស្របទៅនឹងឆន្ទៈ មោះមុតឥតងាករេ និងចក្ខុវិស័យវែងឆ្ងាយ ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ពាក់ព័ន្ធនឹង**ការកែទម្រង់ ការពង្រឹងអភិបាលកិច្ច** និង**ការលើកកម្ពស់និងពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** ត្រូវបានប្តូរឈ្មោះមកជា **ក្រសួងអធិការកិច្ច** ដើម្បីដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ច នៃព្រះរាជាណាចក្រកម្ពុជា សំដៅបង្ការទប់ស្កាត់ កែលម្អ ប្រឆាំងការបំពានដោយអំណាច និងបាតុភាពអសកម្មនានា។

ក្នុងឆ្នាំ២០២៤ ក្រសួងអធិការកិច្ចបានបំពេញតួនាទីយ៉ាងសកម្ម ដូចដែលបានកំណត់ក្នុងផែនការសកម្មភាព ដោយមានការសហការនិងគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ។ ជាមួយនឹងសមិទ្ធផលដែលក្រសួងអធិការកិច្ចសម្រេចបាន នាពេលកន្លងមក នៅមានបញ្ហាប្រឈមមួយចំនួនដែលទាមទារ ឱ្យមានដំណោះស្រាយជាប្រព័ន្ធប្រកបដោយភាពប្រទាក់ក្រឡា ដូច្នេះ ក្រសួងបានដាក់ចេញនូវទិសដៅការងារសំខាន់ៗ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២៥ ដើម្បីបន្តចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នានា។

ជាមួយនឹងទិសដៅការងារបន្តឆ្នាំ២០២៥ ក្រសួងអធិការកិច្ចបានដាក់ចេញនូវយុទ្ធសាស្ត្រ «**៣៤៥៤**» ដែលក្នុងនោះ «**៣៤**» សំដៅដល់ការពង្រឹងការងារស្នូលចំនួន៤ រួមមាន៖ (១) ពង្រឹងការងារអធិការកិច្ច (២) ពង្រឹងការងារដោះស្រាយបណ្តឹង (៣) ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និង (៤) ពង្រឹងការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ និង «**៥៤**» សំដៅដល់ការជំរុញការងារគាំទ្រចំនួន៤ រួមមាន៖ (១) ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត (២)ជំរុញនិងបង្កើនសមត្ថភាពស្ថាប័ន (៣)ជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ និង(៤)ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

យុទ្ធសាស្ត្រ «**៣៤៥៤**» ត្រូវបានចូលរួមរៀបចំឡើងតាមរយៈការសិក្សា ស្រាវជ្រាវ វិភាគ ដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ដែលបានកំណត់នៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងអនុសាសន៍តម្រង់ទិសដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** សម្រាប់ដាក់ឱ្យអនុវត្តឆ្នាំ២០២៥-២០២៨ របស់ក្រសួងអធិការកិច្ច។ ក្រសួងអធិការកិច្ចនឹងអនុវត្តយុទ្ធសាស្ត្រ «**៣៤៥៤**»នេះ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងទៅភាគីពាក់ព័ន្ធ និងបង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រសួងអធិការកិច្ច ក្នុងការកសាងសមត្ថភាពស្ថាប័នឱ្យកាន់តែរឹងមាំ ចូលរួមលើកកម្ពស់នីតិរដ្ឋ និងអភិបាលកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព។

ខ្ញុំមានជំនឿថា ទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងដែលបានកំណត់ផ្អែកលើភាពជាក់ស្តែងនៃការអនុវត្តការងារប្រកបដោយភាពបុរេសកម្ម និងបញ្ហាប្រឈមដែលបានជួបប្រទះនាពេលកន្លងមក ព្រមជាមួយគ្នានូវការដាក់ចេញនូវយុទ្ធសាស្ត្រ «**៣៤៥៤**» នឹងក្លាយជាត្រីវិស័យ ដើម្បីតម្រង់ទិសក្រសួងអធិការកិច្ចក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅរកភាពជោគជ័យ និងសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការយ៉ាងល្អរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងបុព្វហេតុនៃវិស័យអធិការកិច្ចនាពេលកន្លងមក និងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងអធិការកិច្ចទាំងអស់ដែលបានរួមសាមគ្គីគ្នាជាធ្លុងមួយ ខិតខំបំពេញភារកិច្ចតាមតួនាទីរៀងៗខ្លួន រហូតបានសម្រេចជោគជ័យគួរជាទីមោទនៈជូនជាតិមាតុភូមិ។

ថ្ងៃពុធ ១១ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥
**រដ្ឋមន្ត្រីក្រសួងអធិការកិច្ច**

**សុខ សូកេន**

# ជំពូក ១. សេចក្ដីផ្ដើម

ឆ្នាំ២០២៤ បានកន្លងផុតទៅ ស្របពេលដែលសភាពការណ៍សកលលោកបានបន្តវិវត្តតាមលក្ខណៈស្មុគស្មាញផុយស្រួយ គ្រោះថ្នាក់ និងមិនប្រាកដប្រជា ដោយបន្សល់ទុកនូវបញ្ហាប្រឈមជាច្រើន រួមមានការប្រកួតប្រជែងដណ្ដើមឧត្តមភាពខាងយោធា និងអាវុធប្រល័យលោក ការប្រកួតប្រជែងនៃភូមិសាស្ត្រនយោបាយ ការប្រទាញប្រទង់រវាងសេរីភាវូបនីយកម្មនិងការគាំពារនិយមផ្នែកពាណិជ្ជកម្ម សង្គ្រាមពាណិជ្ជកម្ម សង្គ្រាមនៅបណ្ដាតំបន់មួយចំនួននៃពិភពលោក គ្រោះមហន្តរាយធម្មជាតិ រួមមាន ការរញ្ជួយដី ដែលកើតឡើងថ្មីៗ ខ្យល់ព្យុះ ទឹកជំនន់ និងការកើនឡើងកម្ដៅនៃភពផែនដី ដោយសារការប្រែប្រួលអាកាសធាតុ ជាដើម។ សភាពការណ៍បែបនេះបានជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា ជាពិសេស ដល់បរិយាកាសវិនិយោគ និងពាណិជ្ជកម្ម ដែលទាមទារភាពបត់បែន ទន់ភ្លន់ ឈ្លាសវៃ និងការសម្របសម្រួលឱ្យបានទាន់ពេលវេលា និងស្របទៅនឹងសភាពការណ៍ជាក់ស្ដែង។

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលជាប្រមុខដឹកនាំវ័យក្មេង ប្រកបដោយជវភាព ថាមពល ភាពបុរេសកម្ម ចក្ខុវិស័យវែងឆ្ងាយ និងការប្ដេជ្ញាចិត្តយ៉ាងមុតមាំ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានបន្តថែរក្សាយ៉ាងរឹងមាំនូវ សន្តិភាព ស្ថិរភាពនយោបាយ សេដ្ឋកិច្ច សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់ និងប្រកបដោយភាពឈ្លាសវៃ ដែលបានបង្កលក្ខណៈឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ច មានការអភិវឌ្ឍលើគ្រប់វិស័យប្រកបដោយភាពរស់រវើក និងរក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ចបានយ៉ាងរឹងមាំ តាមរយៈការដាក់ចេញយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីឈានទៅសម្រេចឱ្យបានចក្ខុវិស័យ ក្នុងការប្រែក្លាយកម្ពុជា ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។



*រូបថតអនុស្សាវរីយ៍ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាមួយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទាំង៦១រូប ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដំបូង នីតិកាលទី៧ នៃរដ្ឋសភា នៅវិមានសន្តិភាព*

យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ត្រូវបានដាក់ចេញ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយបន្តផ្ដោតជាសំខាន់លើរបៀបវារៈធានា «**ប្រសិទ្ធភាពសមិទ្ធកម្ម**» តាមរយៈការអនុវត្តអភិក្រម «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**» និងអភិក្រម «**ជវភាពនៃប្រព័ន្ធតួអង្គ**

**តែមួយ**»។ ទន្ទឹមនេះ យុទ្ធសាស្ត្រនេះបានកំណត់យកអាទិភាពគន្លឹះ ៥ គឺ «**មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**» ជាពិសេស «**បច្ចេកវិទ្យាឌីជីថល**» សំដៅឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ក្នុងការចូលរួមលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និងមធ្យោបាយដ៏សំខាន់ ដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

**ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** ត្រូវបានប្តូរឈ្មោះទៅជា **ក្រសួងអធិការកិច្ច** កាលពីខែតុលា ឆ្នាំ២០២៣ ស្របតាមចក្ខុវិស័យវែងឆ្ងាយ និងធន្ទះមុតស្រួចរបស់រាជរដ្ឋាភិបាល។ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងដំណើរការ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ចត្រូវបាននិងកំពុងរៀបចំបង្កើតថ្មី ឬកែសម្រួលឡើងវិញជាបន្តបន្ទាប់។ ក្នុងក្របខ័ណ្ឌ នៃការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងអធិការកិច្ច បានបញ្ចប់ការងារវិភាគមុខងារ និងការពិនិត្យនិងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ មុខងារ និងភារកិច្ចរបស់ក្រសួង ដូចមានកំណត់ក្នុងអនុក្រឹត្យ លេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច។

ការបង្កើតក្រសួងអធិការកិច្ច គឺជាតម្រូវការដ៏ចាំបាច់មួយ និងជាផ្នែកមួយដ៏សំខាន់ នៃការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ដែលក្រសួងអធិការកិច្ច ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងមានបេសកកម្ម តួនាទីនិងភារកិច្ចកាន់តែមុតស្រួច និងច្បាស់លាស់លើវិស័យអធិការកិច្ច ដើម្បីចូលរួមពង្រឹងអភិបាលកិច្ច និងភាពស្អាតស្អំ ក្នុងរដ្ឋបាលសាធារណៈ និងបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរាជរដ្ឋាភិបាល។

ក្នុងឆ្នាំ២០២៤ កន្លងទៅ ក្រសួងអធិការកិច្ចបានអនុវត្តការងារសំខាន់ៗ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយជាតិសំខាន់ៗ របស់រាជរដ្ឋាភិបាលប្រកបដោយភាពជោគជ័យជាទីមោទនះ។



*រូបថតអនុស្សាវរីយ៍ **ឯកឧត្តម សុខ សូកេន** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច*
*ក្នុងកិច្ចប្រជុំផ្ទៃក្នុងដំបូង នៅទីស្តីការក្រសួងអធិការកិច្ច*

ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រ«**៣៤៥៤**»សម្រាប់ធ្វើជាត្រីវិស័យក្នុងទិសដៅឆ្នាំ២០២៥-២០២៨ ដែលក្នុងនោះ៖ «**៣៤**» សំដៅពង្រឹងការងារស្នូលចំនួន៤ ដែលរួមមាន៖ (១) ពង្រឹងការងារអធិការកិច្ច (២) ពង្រឹងការងារដោះស្រាយបណ្តឹង (៣) ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និង (៤) ពង្រឹងការងារអប់រំ ផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ និង «**៥៤**» សំដៅជំរុញការងារគាំទ្រចំនួន៤ ដែលរួមមាន៖ (១) ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត (២) ជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន (៣) ជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ និង (៤) ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ស្របតាមយុទ្ធសាស្ត្រ«**៣៤៥៤**» ក្រសួង បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៥ ដោយមានគោលដៅយុទ្ធសាស្ត្រ វិធានការគន្លឹះ និងសកម្មភាពសំខាន់ៗ ដើម្បីអនុវត្តការងារប្រកបដោយភាពសកម្ម បុរេសកម្ម និងអន្តរសកម្ម សំដៅសម្រេចឱ្យបាននូវសមិទ្ធផលថ្មីៗថែមទៀត ក្នុងការចូលរួមពង្រឹងអភិបាលកិច្ច និងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ឆ្ពោះទៅកសាង និងអភិវឌ្ឍមាតុភូមិកម្ពុជាឱ្យកាន់តែរឹងមាំ ខ្លាំងក្លា និងមានការអភិវឌ្ឍលើគ្រប់វិស័យ ឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

សមិទ្ធផលសំខាន់ៗ បញ្ហាប្រឈមនានា ដំណោះស្រាយជាយុទ្ធសាស្ត្រ ផែនការសកម្មភាពអាទិភាព និងទិសដៅការងាររបស់ក្រសួងអធិការកិច្ច ត្រូវបានរៀបរាប់នៅតាមផ្នែកសំខាន់ៗនានា ដូចខាងក្រោម៖

# ជំពូក ២. លទ្ធផលការងារ

ក្នុងស្មារតីទទួលខុសត្រូវខ្ពស់តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល និងក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច** ក្នុងឆ្នាំ២០២៤កន្លងទៅ ក្រសួងអធិការកិច្ចទទួលបានសមិទ្ធផលសំខាន់ៗជាច្រើន ដូចខាងក្រោម៖

## ២.១. ការងារអធិការកិច្ច

ក្រសួងបានធ្វើអធិការកិច្ចលើវិស័យសេដ្ឋកិច្ច រដ្ឋបាល និងសង្គមកិច្ច ដូចខាងក្រោម៖

- បានចុះធ្វើអធិការកិច្ចលើ (១) ការអនុវត្តតួនាទី ភារកិច្ច (២) ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣) ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង-ស្រុក-ខណ្ឌ សាលាដំបូងរាជធានី ខេត្ត ពន្ធនាគាររាជធានី ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌ មន្ទីរ អង្គភាពជុំវិញរាជ-ធានី ខេត្ត អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ ក្នុងរាជធានី ខេត្តសរុបចំនួន ១៧ រួមមាន៖ រាជធានីភ្នំពេញ ខេត្តតាកែវ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តរតនគិរី ខេត្តព្រៃវែង ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តកោះកុង ខេត្តកណ្តាល ខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ ខេត្តមណ្ឌលគិរី ខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង ស្មើនឹង ៦១៩ មន្ទីរ-អង្គភាព។
- បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ក្នុងការិយបរិច្ឆេទ២០២៣ នៅក្រសួង ស្ថាប័នចំនួន ១១ និងសហគ្រាសសាធារណៈ ចំនួន១២ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងបរិស្ថាន ក្រសួងផែនការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល អគ្គិសនីកម្ពុជា និងរដ្ឋាករទឹកសាធារណៈចំនួន ១១ សរុបស្មើនឹង ២៨៩អង្គភាព។

- បានចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងការផ្តល់សេវារដ្ឋបាលនៅអង្គភាព/ការិយាល័យច្រកចេញចូលតែមួយ និងការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំផ្លូវថ្នល់ នៅរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២៣ និងបណ្តាឆ្នាំពាក់ព័ន្ធ ក្នុងរាជធានី ខេត្ត សរុបចំនួន១០ រួមមាន៖រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងខេត្តកំពត ស្មើនឹង ១២១អង្គភាព។

- បានចុះធ្វើអធិការកិច្ចតាមករណីបណ្តឹងលើ (១) ការអនុវត្តតួនាទី ភារកិច្ច និងការគ្រប់គ្រងរបបជីវភាពជនជាប់ឃុំ ក្នុងការិយបរិច្ឆេទ២០២៣ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅមណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ (ព្រៃស) អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ និង (២) បានចុះធ្វើអធិការកិច្ចតាមករណីបណ្តឹងលើការអនុវត្តតួនាទី ភារកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ និងបណ្តាឆ្នាំពាក់ព័ន្ធនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។

ក្នុងការបំពេញបេសកកម្មការងារអធិការកិច្ច ក្រសួងបានរកឃើញនូវចំណុចខ្វះខាតមួយចំនួនរបស់ក្រសួង ស្ថាប័ន និងអង្គភាពរងអធិការកិច្ច ដែលទទួលបានលទ្ធផល ដូចខាងក្រោម៖

### ២.១.១. ការអនុវត្តតួនាទី ភារកិច្ច

ក្នុងការចុះអធិការកិច្ចលើការងារអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ និងបណ្តាឆ្នាំពាក់ព័ន្ធ ជាលទ្ធផលក្រសួងបានរកឃើញថា៖

- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពមួយចំនួន មានភាពខ្វះចន្លោះក្នុងការអនុវត្តតួនាទី ភារកិច្ច ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នសាមី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពមួយចំនួន ពុំទាន់បានកែសម្រួលលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់តួនាទី ភារកិច្ច ឱ្យស្របតាមស្ថានភាពជាក់ស្តែង
- ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ពុំទាន់បានចាត់វិធានការ និងជំរុញម្ចាស់អាជីវកម្មមួយចំនួន ដែលកំពុងប្រកបអាជីវកម្មដោយពុំមានលិខិតអនុញ្ញាតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន
- ក្រុមហ៊ុនអាជីវកម្ម និងសេវាកម្មដែលជាប្រភពបំពុលនៅក្នុងភូមិសាស្ត្រនៃបណ្តាខេត្តមួយចំនួន ពុំបានធ្វើកិច្ចសន្យា និងបង់វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន
- មន្ទីរ អង្គភាពមួយចំនួន ពុំទាន់បានបង្វែរគ្រង់នូវប្រាក់រង្វាន់លើកទឹកចិត្តចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារនៅឡើយ និង
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពមួយចំនួន ពុំទាន់បានចាត់វិធានការតឹងទារបំណុលដើម្បីបង់ចូលថវិការដ្ឋដោយសារមូលហេតុផ្សេងៗ។

## ២.១.២. ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ

ក្រសួងអធិការកិច្ចបានផ្លាស់ប្តូរទម្លាប់ការងារពីអធិការកិច្ចតាមផែនការ ទៅជាអធិការកិច្ចផ្អែកលើហានិភ័យ និងបណ្តឹង ជាពិសេសអភិក្រមនៃការធ្វើអធិការកិច្ច ដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ អាស្រ័យហេតុនេះ នៅឆ្នាំ២០២៤ ការផ្តល់សេវាសាធារណៈ ត្រូវបានកំណត់ជាកម្មវត្ថុជាក់លាក់ដើម្បីធ្វើអធិការកិច្ច។ ជាលទ្ធផល ក្រសួងបានរកឃើញនូវចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម៖

- អង្គភាព/ការិយាល័យច្រកចេញចូលតែមួយ និងមន្ទីរ អង្គភាពនៅតាមបណ្តារាជធានី ខេត្តមួយចំនួនមានភាពយឺតយ៉ាវក្នុងការផ្តល់សេវាសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- អ្នកប្រមូលចំណូលនៃមន្ទីរ អង្គភាពមួយចំនួន ពុំបានធ្វើរបាយការណ៍អំពីស្ថានភាពបញ្ចេញបញ្ចូលបង្កាន់ដៃបង់ប្រាក់ ចំណូលទទួលបានពីការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ និងប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ពុំទាន់បានត្រឹមត្រូវ
- ឯកសារស្នើសុំសេវាសុរិយោដីមួយចំនួនបានចូលតាមច្រកចេញចូលតែមួយ ប៉ុន្តែលទ្ធផលសម្រេចជាផ្លូវការរបស់អ្នកស្នើសុំ ពុំបានចេញតាមរយៈច្រកចេញចូលតែមួយ
- មន្ទីរ អង្គភាពមួយចំនួន ពុំបានបិទផ្សាយជាសាធារណៈនូវតារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីនៃការផ្តល់សេវានៅកន្លែងផ្តល់សេវាសាធារណៈ
- អង្គភាព-ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយចំនួន ពុំបានចុះស្រង់ទិន្នន័យអាជីវកម្ម សិប្បកម្ម សេវាកម្ម និងទិន្នន័យពាក់ព័ន្ធ ដើម្បីចងក្រងបញ្ជីសេវារដ្ឋបាលតាមវិស័យនីមួយៗជារៀងរាល់ឆ្នាំឱ្យបានគ្រប់វិស័យ
- អង្គភាព-ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយចំនួនមានភាពខ្វះចន្លោះក្នុងការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តតាមលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- បុគ្គលិកជួរមុខរបស់ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួន ពុំទាន់បានទទួលការបណ្តុះបណ្តាល ឱ្យបានជាប្រចាំអំពីការពិនិត្យសំណុំឯកសារស្នើសុំសេវាតាមវិស័យនីមួយៗ
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយចំនួន ពុំបានរៀបចំក្រុមការងារដើម្បីចុះត្រួតពិនិត្យជាក់ស្តែងដល់ទីតាំងអ្នកស្នើសុំសេវារដ្ឋបាលមួយចំនួន ដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ និងមានតម្រូវការបច្ចេកទេសច្រើន
- រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌមួយចំនួន ពុំបានរៀបចំតារាងស្តីពីការកំណត់ប្រភេទសេវារដ្ឋបាល និងពេលវេលាជាក់លាក់នៃការផ្តល់សេវារដ្ឋបាល។

## ២.១.៣. គម្រោងសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

ការអនុវត្តគម្រោងសាងសង់ ជួសជុល និងថែទាំសំណង់ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាកម្មវត្ថុនៃការធ្វើអធិការកិច្ចមួយទៀតដែល ក្រសួងបានជ្រើសរើសដើម្បីធ្វើអធិការកិច្ច។ តាមរយៈអធិការកិច្ច ក្រសួងបានរកឃើញនូវចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម៖

- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពមួយចំនួន បានប្រគល់-ទទួលការងារជួសជុលសំណង់ ពុំសមស្របតាមទំហំការងារ និងប្រតិទិនការងារដែលស្នើឡើងដោយអ្នកទទួលការ

- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពមួយចំនួន ពុំបានផាកពិន័យក្រុមហ៊ុនទទួលការដែលមានភាពយឺតយ៉ាវក្នុងការប្រគល់-ទទួល

- មន្ទីរ អង្គភាពមួយចំនួន បានអនុវត្តគម្រោងជួសជុលខុសទីតាំង ដែលបានលើកឡើងក្នុងផែនការលទ្ធកម្ម

- មន្ទីរ អង្គភាពមួយចំនួន ពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលការអនុវត្តគម្រោង

- មន្ទីរ អង្គភាពមួយចំនួន ពុំទាន់បានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារ សំណង់

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមួយចំនួន ពុំបានយកសំណាកទឹកអណ្ដូងស្នប់ អាហ្វ្រីដេវ ទៅត្រួតពិនិត្យនៅមន្ទីរពិសោធន៍នៃនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ មុននឹងដាក់ជូនប្រជាពលរដ្ឋឱ្យប្រើប្រាស់ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ

- មន្ទីរ អង្គភាពមួយចំនួន ដែលបានទទួលការពីក្រសួងជំនាញលើការងារសាងសង់ ថែទាំ ជួសជុលផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ ប្រាំងទន្លេ ពុំបានអនុវត្តឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលមានចែងក្នុងបញ្ជីប៉ាន់តម្លៃ ធ្វើឱ្យសំណង់ពុំមានគុណភាព និងបន្តការខូចខាត

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមួយចំនួន បានជីកស្រះសហគមន៍ដោយពុំបានសាងសង់កាំជណ្ដើរ និងរបងព័ទ្ធជុំវិញស្រះ ដែលអាចធ្វើឱ្យគ្រោះថ្នាក់ជាយថាហេតុដល់មនុស្ស និងសត្វ

- មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរធនធានទឹក និងឧតុនិយមរាជធានី ខេត្តមួយចំនួន ពុំបានប្រើប្រាស់កម្លាំងពលកម្មរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដោយបានប្រើប្រាស់គ្រឿងចក្រមិនស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា

- សហគមន៍កសិករប្រើប្រាស់ទឹកនៃមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់ ពុំបានរៀបចំផែនការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដើម្បីជានាការអនុវត្តការងារជួសជុល ការកែលម្អ និងការបង្កើនលទ្ធភាពរបស់ប្រព័ន្ធធារាសាស្ត្រ

- អគ្គិសនីខេត្តសៀមរាប អគ្គិសនីខេត្តត្បូងឃ្មុំ និងអគ្គិសនីខេត្តព្រះសីហនុ មានទីតាំងអតិថិជនមួយចំនួនបានតម្លើងប្រព័ន្ធបណ្ដាញ ពុំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស

- អគ្គិសនីខេត្តសៀមរាប ពុំទាន់កែលម្អខ្សែបណ្ដាញ MV មុខកាត់ ៣៥ sq.mm ដែលមានប្រវែង ២៥ Km នៅសាខាស្រុកបន្ទាយស្រី

- នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ពុំទាន់មានគោលការណ៍កំណត់រយៈពេល នៃការផ្ដល់សេវាលើកម្មវិធីផ្ដល់ទុនសម្រាប់ពង្រីកបណ្ដាញអគ្គិសនីជនបទ

- នាយកដ្ឋានលទ្ធកម្មនៃអគ្គិសនីកម្ពុជា ពុំបានដាក់បញ្ចូលគ្នានូវសម្ភារៈ និងពលកម្មពង្រីកបណ្ដាញអគ្គិសនីជូនអគ្គិសនីខេត្តជាឡូត៍លទ្ធកម្ម

- កំពង់ផែមួយចំនួនពុំមានលិខិតអនុញ្ញាតវាយតម្លៃផែនការកម្ម លិខិតអនុញ្ញាតសាងសង់កំពង់ផែ និងកំពង់ផែចំនួន២៧ ពុំមានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការកំពង់ផែ។

## ២.១.៤. អធិការកិច្ចតាមបណ្ដឹង

គណៈប្រតិភូអធិការកិច្ចបានធ្វើអធិការកិច្ចលើករណីបណ្ដឹង (១) ការអនុវត្តតួនាទី-ភារកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ ក្នុងការិយបរិច្ឆេទ២០២២ និង២០២៣ និងបណ្ដាឆ្នាំពាក់ព័ន្ធ នៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម និង (២) ចុះធ្វើអធិការកិច្ច លើករណីបណ្ដឹង ការអនុវត្តតួនាទី-ភារកិច្ច និងការគ្រប់គ្រងជីវភាពជនជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១ និងមណ្ឌល អប់រំកែប្រែទី២ (ព្រៃស)។

ជាលទ្ធផល អធិការកិច្ចតាមករណីបណ្តឹងនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម គណៈប្រតិភូបានរកឃើញថា (១) លោកប្រធានផ្នែកបណ្តុះបណ្តាល នៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម បានកិបកេងថវិកាបង់ថ្លៃសិក្សារបស់សិស្សសរុបចំនួន ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក (២) ការគ្រប់គ្រងការបង់ថ្លៃសិក្សារបស់វិទ្យាស្ថានគ្មានភាពច្បាស់លាស់ និងគ្មានតម្លាភាព និង (៣) គ្រូបង្រៀនមួយចំនួនពុំបានទទួលបន្ទប់ដែលវិទ្យាស្ថានផ្តល់ជូនស្នាក់នៅទេ ផ្ទុយទៅវិញវិទ្យាស្ថានបែរជាផ្តល់ជូនគ្រូបង្រៀនដែលពុំមានតម្រូវការស្នាក់នៅដោយគ្រូបង្រៀនទាំងនេះបានយកបន្ទប់ទាំងនោះទៅជួលបន្ត។ ចំណែកករណីការគ្រប់គ្រងជីវភាពជនជាប់ឃុំ (១) មានការខ្វះខាតក្នុងការគ្រប់គ្រងសន្តិសុខ (២) មានការយឺតយ៉ាវក្នុងការផ្តល់របបឧបត្ថម្ភ (៣) របបសេវាអប់រំកែប្រែសម្រាប់ទណ្ឌិតពុំទាន់សមស្រប និង (៣) ចំពោះពាក្យបណ្តឹងរបស់ទណ្ឌិតទាំង១៥នាក់ដែលធ្វើ ឡើងតាមការរៀបចំរបស់ទណ្ឌិតមួយរូបបានប្រព្រឹត្តទៅដោយខុសពីបទបញ្ជាផ្ទៃក្នុង នៃមណ្ឌលអប់រំកែប្រែ។

## ២.១.៥. ការចាត់វិធានការជំរុញការកែលម្អចំណុចខ្វះខាត

តាមរយៈការងារអធិការកិច្ច ក្រសួងបានរកឃើញចំណុចខ្វះខាត តាមរយៈការចេញសេចក្តីជូនដំណឹងកែលម្អជូនក្រសួង ស្ថាប័ន អង្គភាពរងអធិការកិច្ច ដើម្បីកែលម្អ និងចាត់វិធានការ ដូចខាងក្រោម៖

- បានដាក់វិន័យរដ្ឋបាលដល់មន្ត្រីរាជការ និងចាត់បញ្ជូនទៅតុលាការចំពោះបទល្មើសធ្ងន់ធ្ងរ ដូចជាករណីប្រព្រឹត្តបទល្មើសព្រៃឈើ បទល្មើសជលផល និងការបំផ្លិចបំផ្លាញធនធានរ៉ែ ជាដើម

- បង្ខំឱ្យសង និងបង់ចូលថវិការដ្ឋវិញ ករណីកិបកេងទ្រព្យសម្បត្តិរដ្ឋ ចំណូលថវិការបស់រដ្ឋ និងការបញ្ចាចំណាយខុសគោលដៅជាដើម

- បង្ខំឱ្យម្ចាស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចអនុវត្តកាតព្វកិច្ចបង់ថវិកាចូលរដ្ឋតាមកិច្ចសន្យា និងបំពេញភារកិច្ចដូចដែលបានចែងក្នុងកិច្ចសន្យា

- ណែនាំឱ្យមុខសញ្ញារងអធិការកិច្ចបំពេញតួនាទី ភារកិច្ច ទៅតាមសមត្ថកិច្ចរបស់ខ្លួនឱ្យបានល្អ ដើម្បីទទួលបានជោគជ័យ និងសមិទ្ធផលក្នុងការងារដែលរាជរដ្ឋាភិបាលបានប្រគល់ជូន

- ណែនាំឱ្យមុខសញ្ញារងអធិការកិច្ចគ្រប់គ្រង និងចាត់ចែងថវិការដ្ឋ ទ្រព្យសម្បត្តិរដ្ឋ និងធនធាននានាសមស្របទៅតាមគោលការណ៍ហិរញ្ញវត្ថុ និងច្បាប់ជាធរមាន

- ណែនាំឱ្យមុខសញ្ញារងអធិការកិច្ចខិតខំប្រមូលចំណូលមិនមែនសារពើពន្ធ និងចំណូលសារពើពន្ធឱ្យអស់លទ្ធភាព

- ណែនាំឱ្យក្រសួង ស្ថាប័ន និងអង្គភាពមួយចំនួនចាត់វិធានការតឹងទារបំណុលរ៉ាំរ៉ៃ ដែលអតិថិជនបានជំពាក់

- ណែនាំឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់ក្នុងការផ្តល់សេវាសាធារណៈឱ្យបានល្អ និងទាន់ពេលជូនប្រជាពលរដ្ឋ

- បានធ្វើសេចក្តីជូនដំណឹងដល់ប្រធានស្ថាប័ន ឱ្យជួយជំរុញដល់អង្គភាពក្រោមឱវាទឱ្យកែលម្អ នូវចំណុចខ្វះខាតតាមវិធានការអធិការកិច្ចដែលបានរកឃើញ។

ដោយឡែក នៅឆ្នាំ២០២៤ ជាលទ្ធផលនៃការចុះអធិការកិច្ចលើការងារអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ និងបណ្តាឆ្នាំពាក់ព័ន្ធ ក្រសួងមានចំណាត់ការដូចតទៅ៖

- បានចេញសេចក្តីជូនដំណឹងស្តីពីការជំរុញកែលម្អចំណុចខ្វះខាត ក្នុងការងារអធិការកិច្ចលើ (១) ការអនុវត្តតួនាទី ភារកិច្ច (២) ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តកោះកុង ខេត្តកណ្តាល ខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តមណ្ឌលគិរី និងទៅក្រសួងចំនួន១៩ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងផែនការ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

- បានចេញសេចក្តីជូនដំណឹងស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតលើ (១) ការអនុវត្តតួនាទីភារកិច្ច (២) ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ក្នុងការិយបរិច្ឆេទ២០២៣ ទៅក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងផែនការ ក្រសួងបរិស្ថាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គិសនីកម្ពុជា និងរដ្ឋាករទឹកសាធារណៈចំនួន១១។

## ២.២. ការងារតាមដានការអនុវត្តច្បាប់

### ២.២.១. អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១

ក្រសួងបានចុះតាមដានត្រួតពិនិត្យការអនុវត្តអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តព្រះសីហនុ ខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ ស្មើនឹង ៥៦មុខសញ្ញា។

ជាលទ្ធផលក្រសួងបានរកឃើញនូវចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម៖

- ចំនួនមន្ត្រីជំនាញប្រចាំការនៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារមួយចំនួន លើសពីការកំណត់ ពុំមានការផ្លាស់ប្តូរ ជាពិសេសមន្ត្រីទាំងនេះបានបម្រើការងារហួសអាណត្តិ។

- កិច្ចសហការត្រួតពិនិត្យទំនិញ និងអ្នកដំណើរឆ្លងកាត់របស់សមត្ថកិច្ចនៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារមួយចំនួន ពុំទាន់មានភាពរលូន និងពុំមានការត្រួតពិនិត្យរួមគ្នា តាមខ្លឹមសារនៃអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ រួមមាន ការត្រួតពិនិត្យអ្នកដំណើរចេញ-ចូល ធ្វើឡើងដោយសមត្ថកិច្ច

នគរបាលជាតិ រីឯការត្រួតពិនិត្យទំនិញចេញ-ចូល ធ្វើឡើងដោយសមត្ថកិច្ចគយ និងរដ្ឋាករ ដោយអនុលោមតាមអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលស្ថាប័នមាន សមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ-នាំចូល ដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា និងស្របតាមបទបញ្ជាលេខ០១ បប ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងការបង្ក្រាបអំពើរត់គេចពន្ធ។

### ២.២.២. អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥

ក្រសួងបានចុះតាមដានត្រួតពិនិត្យអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី ស្មើនឹង១៣៨មុខសញ្ញា។

ជាលទ្ធផល ក្រសួងបានរកឃើញនូវចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម៖

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន១៤ ស្ថិតក្នុងខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគិរី ពុំទាន់បានធ្វើអនុប្បយោគ ដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋឱ្យបានរួចរាល់
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន២៥ ស្ថិតក្នុងខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគិរី ពុំទាន់បានចុះបញ្ជីដីឯកជនរបស់រដ្ឋឱ្យបានរួចរាល់
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន៤៤ ស្ថិតក្នុងខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី ពុំទាន់បានធ្វើកិច្ចសន្យាកែតម្រូវរយៈពេលវិនិយោគមកនៅត្រឹមរយៈពេល ៥០ឆ្នាំ
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន៦៤ ស្ថិតក្នុងខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី ពុំទាន់បានធ្វើផែនការមេកែសម្រួលថ្មីឱ្យបានរួចរាល់នៅឡើយ
- ក្រុមហ៊ុនវិនិយោគមួយ ស្ថិតក្នុងខេត្តក្រចេះ ពុំបានដាក់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន៥៧ ស្ថិតក្នុងខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី ពុំទាន់បានរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៅឡើយ
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២ ស្ថិតក្នុងខេត្តស្ទឹងត្រែង មិនទាន់ទទួលបានការឯកភាពលើរបាយការណ៍ វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ពីក្រសួងបរិស្ថាននៅឡើយ
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន៤២ ស្ថិតក្នុងខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី ពុំទាន់បានបង់ថ្លៃសម្បទាន ឬថ្លៃឈ្នួលប្រចាំឆ្នាំ
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន១៩ ស្ថិតក្នុងខេត្តក្រចេះ ពុំបានរៀបចំស្លាកដាក់តាំងនៅជាប់ផ្លូវជាតិ ឬផ្លូវចូលទៅកាន់ទីតាំងស្នាក់ការរបស់សម្បទានដីសេដ្ឋកិច្ច នូវព័ត៌មានសំខាន់ៗរបស់ក្រុមហ៊ុន
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន៣៦ ស្ថិតក្នុងខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី មានភាពយឺតយ៉ាវក្នុងការដាំដុះ និងការដាំដុះសារឡើងវិញ
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន២៤ ស្ថិតក្នុងខេត្តក្រចេះ និងខេត្តព្រះវិហារ មិនមានសកម្មភាព
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៥ ស្ថិតក្នុងខេត្តព្រះវិហារ មិនទាន់បានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៥ ស្ថិតក្នុងខេត្តព្រះវិហារ មិនមានការឈូសឆាយ និងដាំដុះលើសពី២ឆ្នាំ

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសរុបចំនួន២៥ ស្ថិតក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ មិនទាន់រៀបចំផែនការអនុវត្តប្រចាំឆ្នាំនៃគម្រោងវិនិយោគ រួចដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៤ ស្ថិតក្នុងខេត្តកំពង់ធំ មិនទាន់ធ្វើកិច្ចសន្យាការពារបរិស្ថាន

- ក្រុមហ៊ុនមួយ ដែលបានទទួលកិច្ចសន្យាវិនិយោគពីរដ្ឋាភិបាល លើផ្ទៃដីទំហំ ៩.០១៨ ហិកតា ស្ថិតនៅឃុំរយ៉ ឃុំស្រែសង្គម និងឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ពុំមានសកម្មភាព និង ពុំអាចទំនាក់ទំនងបាន

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២ ស្ថិតក្នុងខេត្តកំពង់ធំ ពុំមានសកម្មភាពអភិវឌ្ឍន៍ ហើយដីរបស់ក្រុមហ៊ុនត្រូវបានប្រជាពលរដ្ឋកំពុងកាន់កាប់ គ្រប់គ្រង និងអាស្រ័យផល។

### ២.២.៣. បទបញ្ជារបស់នាយករដ្ឋមន្ត្រី

ក្រសួងបានចុះតាមដានត្រួតពិនិត្យការអនុវត្តបទបញ្ជារបស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលបញ្ជាឱ្យអភិបាលរាជធានី-ខេត្តទាំងអស់ ត្រួតពិនិត្យជាបន្ទាន់លើទីតាំងល្បែងផ្សងសំណាង ក្នុងករណីមានបន្តបើកថ្មីទៀត សូមចាត់វិធានការបិទជាបន្ទាន់ និងរាយការណ៍ផ្ទាល់ ជូនសម្តេច។ តាមរយៈបេសកកម្មរបស់គណៈប្រតិភូ ក្នុងការចុះតាមដានអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល នៅខេត្តព្រះសីហនុ ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ ទទួលបានលទ្ធផលល្អ ដោយគណៈបញ្ជាការឯកភាពខេត្តទាំង៣ បានចេញបទបញ្ជាដល់បណ្តាគណៈបញ្ជាការឯកភាពក្រុង-ស្រុក ដោយសហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ដោយបានចុះបង្ក្រាប និងតម្រូវឱ្យម្ចាស់ទីតាំងអាជីវកម្មល្បែងខុសច្បាប់ទាំងនោះធ្វើកិច្ចសន្យា ព្រមទាំងបិទទាំងស្រុងជាស្ថាពរ និងបន្តតាមដានត្រួតពិនិត្យជាប្រចាំនៅតាមមូលដ្ឋានរបស់ខ្លួន។




*រូបថតអនុស្សាវរីយ៍ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និង លើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច*

## ២.៣. ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ឆ្នាំ២០២៤ ក្រសួងទទួលពាក្យបណ្តឹងបានសរុបចំនួន ១៥២បណ្តឹង (ថ្នាក់ជាតិទទួលបានចំនួន ៦៩បណ្តឹង និងថ្នាក់ក្រោមជាតិទទួលបានចំនួន ៨៣បណ្តឹង) និងបានដោះស្រាយបញ្ចប់ចំនួន ៥០បណ្តឹង ក្នុងនោះ

អគ្គនាយកដ្ឋាន ១៨បណ្តឹង មន្ទីររាជធានី ខេត្ត ចំនួន ៣២បណ្តឹង (មន្ទីរខេត្តកំពង់ស្ពឺ ចំនួន ១៣បណ្តឹង មន្ទីរខេត្តកំពង់ឆ្នាំង ចំនួន៥បណ្តឹង មន្ទីរខេត្តស្វាយរៀង ចំនួន៤បណ្តឹង មន្ទីរខេត្តបាត់ដំបង ចំនួន៣បណ្តឹង មន្ទីរខេត្តកំពង់ចាម ចំនួន ២បណ្តឹង មន្ទីរខេត្តស្ទឹងត្រែង ចំនួន ២បណ្តឹង មន្ទីរខេត្តកណ្តាល ចំនួន ១បណ្តឹង មន្ទីរខេត្តព្រះវិហារ ចំនួន ១បណ្តឹង និងមន្ទីរខេត្តព្រះសីហនុ ចំនួន ១ បណ្តឹង)។ ពាក្យបណ្តឹងបញ្ជូនទៅក្រសួងស្ថាប័នផ្សេងពិនិត្យដោះស្រាយចំនួន ១៧បណ្តឹង (អគ្គនាយកដ្ឋាន ចំនួន ១៣បណ្តឹង មន្ទីររាជធានី ខេត្ត ចំនួន ៤បណ្តឹង)។ ពាក្យបណ្តឹងនៅសល់ ចំនួន ៨៥បណ្តឹង (អគ្គនាយកដ្ឋាន ចំនួន ៣៨បណ្តឹង និងមន្ទីររាជធានី ខេត្ត ចំនួន ៤៧ បណ្តឹង) កំពុងបន្តអង្កេតស្រាវជ្រាវ។ ពាក្យបណ្តឹងដែលក្រសួងបានទទួលការឆ្លើយតបពីក្រសួងស្ថាប័នផ្សេង មានចំនួន ១៤បណ្តឹង។

ពាក្យបណ្តឹងទាំងអស់ត្រូវបានយកមកពិនិត្យ និងវាយតម្លៃយ៉ាងល្អិតល្អន់ បន្ទាប់មកក្រសួងបានចាត់ថ្នាក់ទៅតាមអាទិភាព និងចាត់គណៈប្រតិភូចុះទៅអង្កេត ស្រាវជ្រាវ និងដោះស្រាយដល់ទីតាំងទំនាស់ និងអញ្ជើញភាគី ទំនាស់ដើម្បីដោះស្រាយនៅទីស្តីការក្រសួង។

បណ្តឹងដែលថ្នាក់ជាតិទទួលបាន និងដោះស្រាយ មានចំនួន ៦៩ ករណី ក្នុងនោះមាន ៦៧ ករណី ឬ ៩៧ % ជាបណ្តឹងដែលទាក់ទងនឹងទំនាស់ដីធ្លី និងមានតែ ២ករណី ឬ ៣% ប៉ុណ្ណោះជាទំនាស់ដែលទាក់ទងនឹងបំណុល។ ជាលទ្ធផលនៃការងារអង្កេត ស្រាវជ្រាវ និងដោះស្រាយ មាន ២៣ ករណី ឬ ៣៣% បានបញ្ចប់ដោយការសម្របសម្រួល ៣៨ ករណី ឬ ៥៥% ត្រូវបញ្ជូនទៅស្ថាប័នផ្សេងដើម្បីដោះស្រាយបន្ត និង ៨ ករណី ឬ ១២% ត្រូវបញ្ចប់ដោយមិនចាត់ការ។

## ២.៤. ការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

### ២.៤.១. ការអប់រំផ្សព្វផ្សាយច្បាប់

ក្រសួងបានចុះអប់រំផ្សព្វផ្សាយច្បាប់ ដែលត្រូវបានជ្រើសរើសជាអាទិភាព នៅតាមរាជធានី ខេត្ត ទូទាំងប្រទេស ដូចខាងក្រោម៖

- បានចុះផ្សព្វផ្សាយច្បាប់ចំនួន១៨៣លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន ១៥លើក និងមន្ទីររាជធានី ខេត្តចំនួន១៦៨លើក) រួមមាន៖ (១) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន ៧០ លើក ក្នុងនោះនៅខេត្តក្រចេះចំនួន១១លើក កណ្តាលចំនួន៩លើក ស្វាយរៀងចំនួន៧លើក កំពង់ធំចំនួន៦លើក កំពង់ចាមចំនួន៥លើក តាកែវចំនួន៥លើក រាជធានីភ្នំពេញចំនួន៤លើក កែបចំនួន៤លើក បន្ទាយមានជ័យចំនួន៤លើក រតនគិរីចំនួន៤លើក កំពង់ស្ពឺចំនួន៣លើក ព្រះសីហនុចំនួន៣លើក ត្បូងឃ្មុំចំនួន២លើក សៀមរាបចំនួន១លើក កំពតចំនួន១លើក និងខេត្តបាត់ដំបងចំនួន១លើក (២) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន ៩៥ លើក ក្នុងនោះ នៅខេត្តស្ទឹងត្រែងចំនួន ១០ លើក ក្រចេះចំនួន ១០ លើក ព្រះសីហនុចំនួន៩លើក ឧត្តរមានជ័យចំនួន៩លើក ស្វាយរៀងចំនួន៩លើក កំពង់ចាមចំនួន៥លើក តាកែវចំនួន៥លើក កែបចំនួន៥លើក កំពង់ធំចំនួន៥លើក ពោធិ៍សាត់ចំនួន៥លើក កំពង់ស្ពឺចំនួន៤លើក កណ្តាលចំនួន៤លើក ត្បូងឃ្មុំចំនួន៤លើក សៀមរាបចំនួន៣លើក កំពតចំនួន២លើក មណ្ឌលគិរីចំនួន២លើក ព្រះវិហារចំនួន២លើក បន្ទាយមានជ័យចំនួន១លើក និងខេត្តបាត់ដំបងចំនួន១លើក (៣) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចំនួន៣លើក នៅខេត្តក្រចេះ (៤) ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ចំនួន៤លើកនៅខេត្តកែប (៥) ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

ចំនួន១លើក នៅខេត្តក្រចេះ (៦) ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារចំនួន១លើក នៅខេត្តកែប (៧) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន២លើក ក្នុងនោះ នៅរាជធានីភ្នំពេញចំនួន១លើក និងខេត្តកំពង់ធំចំនួន១លើក (៨) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងក្រមព្រហ្មទណ្ឌចំនួន៧លើក នៅខេត្តព្រៃវែង

- ជាសរុប មានអ្នកចូលស្តាប់ ចំនួន៤២,២៩០នាក់ (ស្ត្រីចំនួន២០,៤៧៥នាក់) និងបានទទួលសំណួរចំនួន៣,០០៧សំណួរ

- បានបញ្ច្រាបនូវខ្លឹមសារច្បាប់ស្តីពីការបង្ការទប់ស្កាត់ជំងឺអេដស៍/មេរោគអេដស៍ដល់អង្គពិធី នៅគ្រប់កម្មវិធីផ្សព្វផ្សាយច្បាប់ទាំង១៥លើក របស់អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា

- បានថតវីដេអូផ្សព្វផ្សាយច្បាប់ចំនួន២ប្រធានបទរួមមាន៖ (១) ប្រធានបទ៖ បទល្មើសមិនគោរពសញ្ញាចរាចរណ៍ (ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក) ដោយលោក ចែម ជឿន ប្រធានការិយាល័យទំនាក់ទំនងអប់រំផ្សព្វផ្សាយច្បាប់ ធ្វើជាវាគ្មិន (២) ប្រធានបទ៖ ការប៉ះពាល់ដល់ជីវិតមនុស្ស (ក្រមព្រហ្មទណ្ឌ) ដោយលោក នូ អ៊ីន អនុប្រធាននាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់ធ្វើជាវាគ្មិន

- បានទទួលសៀវភៅច្បាប់ចំនួន៦,០០០ក្បាល ពីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់សម្រាប់ចុះផ្សព្វផ្សាយច្បាប់ (ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន២,៤០០ក្បាល និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន៣,៦០០ ក្បាល)

- បានទទួលនូវឯកសារទាក់ទងនឹងច្បាប់ពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១០០ក្បាល សៀវភៅអប់រំខ្លីទាក់ទងនឹងគ្រឿងញៀនចំនួន១០០ក្បាល និងខិតបណ្ណអប់រំខ្លីទាក់ទងនឹងគ្រឿងញៀនចំនួន២,០០០សន្លឹក)

- បានទទួលនូវឯកសារទាក់ទងនឹងច្បាប់ពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបន្ទាយមានជ័យ (សៀវភៅច្បាប់តូចអប់រំខ្លីស្តីពីចរាចរណ៍ផ្លូវគោកចំនួន១៥០ក្បាល) និងខេត្តបាត់ដំបង (ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន១២០ក្បាល មួកសុវត្ថិភាពចំនួន២០មួក សៀវភៅម៉ូតូ អ្វីដែលអ្នកបើកបរទោចក្រយានយន្តត្រូវយល់ដឹង សៀវភៅតូចចំនួន៦០០ក្បាល ស្ទីកឃ័រចំណាំងផ្លាតM3ចំនួន១,០០០បន្ទះ ខិតបណ្ណសុវត្ថិភាពបើកបរយានយន្តចំនួន២០០ច្បាប់ ខិតបណ្ណជំនួយស្មារតីស្តីពីចរាចរណ៍ផ្លូវគោក ប្រការសំខាន់ៗ ដែលត្រូវចងចាំចំពោះអ្នកប្រើប្រាស់ផ្លូវចំនួន៦០០ច្បាប់ និងផ្ទាំងការកំណត់ទំហំទ្រុងរថយន្ត ការកំណត់ ទំហំផ្ទុកទំនិញ ចំនួន ១០០ផ្ទាំង)

- បានចុះវិភាគស្ថានភាព និងវាយតម្លៃអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋមុនពេលចុះផ្សព្វផ្សាយច្បាប់ចំនួន៤ឃុំរួមមាន៖ (១) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៅស្រុកថ្ពងចំនួន២ឃុំ ខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមចំនួន១១៩នាក់ (ស្ត្រីចំនួន២៣នាក់) (២) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅក្រុងសែនមនោរម្យចំនួន២ឃុំ ខេត្តមណ្ឌលគិរី ដោយមានអ្នកចូលរួមចំនួន១០៦នាក់ (ស្ត្រីចំនួន៦៦នាក់)

- បានចុះវិភាគស្ថានភាព និងវាយតម្លៃអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋក្រោយពេលចុះផ្សព្វផ្សាយច្បាប់ចំនួន៤ឃុំរួមមាន៖ (១) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៅស្រុកថ្ពងចំនួន២ឃុំ ខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមចំនួន១០០នាក់ (ស្ត្រីចំនួន៥៧នាក់) (២) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅក្រុងសែនមនោរម្យចំនួន២ឃុំ នៅខេត្តមណ្ឌលគិរីចំនួន២កន្លែង ដោយមានអ្នកចូលរួមចំនួន១០០នាក់ (ស្ត្រីចំនួន៧០នាក់)

- បានចុះវិភាគស្ថានភាព និងវាយតម្លៃពីការយល់ដឹងរបស់ប្រជាពលរដ្ឋ ក្រោយការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅស្រុកសៀមបូកចំនួន៧ឃុំ និងស្រុកសេសានចំនួន៣ឃុំ ខេត្តស្ទឹងត្រែង ដោយមានអ្នកចូលរួមចំនួន៦៦៣នាក់ (ស្ត្រីចំនួន៣៩១នាក់)

- បានបង្កើតកម្រងសំណួរច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សម្រាប់ការចុះវិភាគស្ថានភាព និងវាយតម្លៃអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋមុន និងក្រោយការផ្សព្វផ្សាយច្បាប់

- បានតាមដានផេកហ្វេកបុកនាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់ ដោយទទួលបានអ្នកតាមដានគេហទំព័រ ឬផេក(page) ចំនួន៥៣៦នាក់

- បានតាមដានពីវឌ្ឍនភាព នៃការផ្សព្វផ្សាយច្បាប់តាមរយៈវីដេអូឃ្លីបចំនួន២១វីដេអូឃ្លីប (១៦ច្បាប់) ដែលមានគេហទំព័រ ឬផេកហ្វេសបុក (Facebook Page) ចំនួន៦ គឺ (១) ផេកហ្វេសបុកក្រសួងអធិការកិច្ច Ministry of Inspection (២) ផេកហ្វេសបុកអគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា (៣) ផេកហ្វេសបុកនាយកដ្ឋានអប់រំ ផ្សព្វផ្សាយច្បាប់ (៤) ផេកហ្វេសបុកបណ្ណាល័យច្បាប់ cll-insp (៥) ផេកហ្វេសបុក Apsara TV11 (៦)ផេកហ្វេសបុក ទូរទស្សន៍ជាតិកម្ពុជា ទទក-TVK ដោយមានអ្នកចូលទស្សនាចំនួន ២,១១៩នាក់

- បានផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (អំពីទោសទណ្ឌនៃការប្រើប្រាស់ និងជួញដូរគ្រឿងញៀន) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក លក្ខណៈសម្បត្តិភូមិ-ឃុំមានសុវត្ថិភាព និងលិខិតបទដ្ឋានគតិយុត្តនានា តាមរយៈវិទ្យុជាតិ FM 92. 5ភ្នំប្រុសភ្នំស្រី និងផេកមន្ទីរព័ត៌មានខេត្តកំពង់ចាមចំនួន៥៣០លើក

- បានតម្លើងប៉ាណូផ្សព្វផ្សាយសារអប់រំអំពីផលប៉ះពាល់ដែលបណ្តាមកពីគ្រឿងញៀន ចំនួន១០ ទីតាំង ក្នុងនោះ ស្រុកទ្រាំង ចំនួន៣ទីតាំង ក្រុងដូនកែវ ចំនួន៣ទីតាំង ស្រុកកោះអណ្តែតចំនួន១ទីតាំង ស្រុកត្រាំកក់ ចំនួន១ ទីតាំង ស្រុកព្រៃកប្បាសចំនួន១ទីតាំង និងស្រុកសំរោងចំនួន១ទីតាំង ក្នុងខេត្តតាកែវ។

### ២.៤.២. ការធ្វើវេទិកាសាធារណៈ

ក្រសួងបានសម្រេចការងារធ្វើវេទិកាសាធារណៈដូចខាងក្រោម៖

បានរៀបចំធ្វើវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន១២លើក គឺខេត្តបាត់ដំបង ចំនួន ២លើក រួមមាន៖ ខេត្តត្បូងឃ្មុំចំនួន២លើក កំពង់ធំចំនួន២លើក ស្វាយរៀងចំនួន២លើក ពោធិ៍សាត់ចំនួន២លើក និងខេត្តព្រះវិហារចំនួន២លើក ដោយមានអ្នកចូលរួមចំនួន២,៣៥៩នាក់ (ស្ត្រីចំនួន៩៦២នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន១៦២ សំណូមពរ

- បានចុះស្ទង់មតិប្រជាពលរដ្ឋស្តីពីការយល់ដឹងលើច្បាប់ចំនួន៥៨លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន១២លើក និងមន្ទីររាជធានី ខេត្តចំនួន៤៦លើក) រួមមាន៖ (១) ច្បាប់ភូមិបាល (២) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិចំនួន១លើក (៣) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (៤) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (៥) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (៦) ផលប៉ះពាល់ នៃការប្រើប្រាស់បារីអេឡិចត្រូនិក (វ៉េប) ដោយមានអ្នកចូលរួមចំនួន ៥,៩០២នាក់ (ស្ត្រីចំនួន២,៥០៤នាក់)។

## ២.៥. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទទួលបាននូវលទ្ធផលការងារ ដូចខាងក្រោម៖

- បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើគំរូលិខិតរដ្ឋបាលរបស់ក្រសួងអធិការកិច្ច ចំនួន ៣លើក

- បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើផែនការអាទិភាពនៃការ កសាងលិខិតបទដ្ឋានគតិយុត្តដែលជាតម្រូវការអាទិភាពរបស់ក្រសួងអធិការកិច្ចរបស់ក្រសួងអធិការកិច្ចចំនួន៣លើក

- បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន និងអង្គភាព នៃក្រសួងអធិការកិច្ចចំនួន៦លើក

- បានរៀបចំកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួងអធិការកិច្ចចំនួន១លើក

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួង វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំនានាចំនួន១៤លើក

- បានបញ្ចូលឯកសារច្បាប់ចំនួន៥២ច្បាប់ (ព្រះរាជក្រឹត្យចំនួន១ ច្បាប់ចំនួន១ អនុក្រឹត្យចំនួន២៨ ប្រកាសចំនួន១៣ សេចក្តីសម្រេចចំនួន៣ និងសារាចរចំនួន៦) ទៅក្នុងបណ្ណាល័យអេឡិចត្រូនិក

- បានសិក្សាស្រាវជ្រាវច្បាប់មួយចំនួនរួមមាន៖ (ច្បាប់ សម័យសាធារណរដ្ឋខ្មែរ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៥ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦ និងបានស្រាវជ្រាវច្បាប់សម័យកម្ពុជាប្រជាធិបតេយ្យ)

- បានរៀបចំកិច្ចប្រជុំតាមដានវឌ្ឍនភាពរបស់ក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច ចំនួន២លើក

- បានរៀបចំប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះអគ្គនាយកដ្ឋានអធិការកិច្ច នៅទីស្តីការក្រសួងអធិការកិច្ចចំនួន ៣លើក

- បានរៀបចំប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះអគ្គនាយកដ្ឋានដោះស្រាយបណ្តឹង នៅទីស្តីការក្រសួងអធិការកិច្ច ចំនួន ២លើក

- បានរៀបចំប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងវិទ្យាស្ថានជាតិអធិការកិច្ចនៅទីស្តីការក្រសួងអធិការកិច្ចចំនួន២លើក

ក្រុមការងារនីតិកម្ម ក្រសួងបានចូលរួមប្រជុំពិនិត្យ និងពិភាក្សា លើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច លើសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះ ប្រជុំអន្តរក្រសួង វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន១០៣លើក។ ក្រសួងបានបញ្ចូលឯកសារព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេចសរុបចំនួន ៥២ច្បាប់ទៅក្នុងបណ្ណាល័យអេឡិចត្រូនិក។

ក្រុមការងារនីតិនៃក្រសួងអធិការកិច្ចបានសម្រេចនូវលទ្ធផលពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្ត ដូចខាងក្រោម៖

### ២.៥.១. សេចក្តីសម្រេច និងប្រកាស

- ក្រសួងបានចេញសេចក្តីសម្រេចចំនួន ៣២ ច្បាប់ និងប្រកាស ចំនួន១៥ ច្បាប់។

### ២.៥.២. ច្បាប់ស្តីពីអធិការកិច្ច

- បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ផ្ទៃក្នុងក្រសួង ចំនួន ៤៨ លើក នៅទីស្តីការក្រសួង ក្នុងនោះឯកឧត្តមរដ្ឋមន្ត្រីបានដឹកនាំផ្ទាល់ចំនួន៦ លើក

- បានរៀបចំកិច្ចប្រជុំក្រុមការងារចង្អៀតពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចដោយឆ្លងជាមួយ ទីប្រឹក្សាបច្ចេកទេសផ្នែកច្បាប់ជាតិ ចំនួន៣លើក

- បានចូលរួមកិច្ចប្រជុំជាមួយអង្គភាពអធិការកិច្ច តាមក្រសួងស្ថាប័នចំនួន១លើក បានចូលរួមកិច្ចប្រជុំឆ្លងថ្នាក់ដឹកនាំក្រសួងចំនួន៣លើក

- បានចូលរួមកិច្ចប្រជុំជំនាញបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន១លើក។

### ២.៥.៣. អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច

ចំពោះការរៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ចថ្មី ក្រុមការងារនីតិកម្មរបស់ក្រសួងអធិការកិច្ចបានបំពេញការងារដូចខាងក្រោម៖

- ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ចចំនួន៣៥លើក ក្នុងនោះរដ្ឋមន្ត្រីបានដឹកនាំផ្ទាល់ចំនួន២លើក

- រៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង អធិការកិច្ចជាមួយ ក្រសួងមុខងារសាធារណៈ ចំនួន៤ លើក

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួងពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច ចំនួន៤ លើក នៅទីស្តីការគណៈរដ្ឋមន្ត្រី

- បានចូលរួមកិច្ចប្រជុំរវាងតំណាងក្រសួងអធិការកិច្ច និងតំណាងអង្គភាព ប្រឆាំងអំពើពុករលួយនៅអង្គភាពប្រឆាំងអំពើពុករលួយចំនួន១លើក

- បានចូលរួមកិច្ចប្រជុំជំនាញបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន១លើក

- បានចូលរួមកិច្ចប្រជុំចង្អៀតគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចំនួន១លើក

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួងកម្រិតទូលាយ នៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន២លើក។

## ២.៦. ការជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន

### ២.៦.១. ការងាររដ្ឋបាល

ក្រសួងអធិការកិច្ចបានអនុវត្ត និងបំពេញភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ក្រសួងបានទទួលលិខិតចូល ចំនួន២,២២៧ច្បាប់ បញ្ជូនលិខិតចេញ ចំនួន២,៦៤៦ ច្បាប់, ចេញវិញ្ញាបនបត្ររដ្ឋបាល ចំនួន៣០ ច្បាប់ ព្រមទាំងបានរៀបចំកម្មវិធីប្រជុំនានា ចំនួន២៨៦លើក នៅទីស្តីការក្រសួង

- បានរៀបចំ និងបញ្ជូនសារលិខិតជូនពរថ្នាក់ដឹកនាំជារដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងថ្នាក់ដឹកនាំ និងមន្ត្រី រាជការក្នុងក្រសួង ក្នុងឱកាសពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២៤

- បានគ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង

- បានត្រួតពិនិត្យ និងថែទាំម៉ាស៊ីនមេ (Server) និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍

- បានតាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធ Facebook page ផេកក្រសួង (Facebook page) មានអ្នក Follower page ចំនួន៥០៦.៥k ចុចLike page ចំនួន២៧៧.៣k និង Share page ចំនួន២៨.៩k

- បានចូលរួមពិធីមីទ្ទីញ សិក្ខាសាលា វេទិកាសាធារណៈ សន្និបាតបូកសរុបលទ្ធផលការងារ វគ្គបណ្តុះបណ្តាល ពិធីបុណ្យជាតិ-អន្តរជាតិ ពិធីផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម សម្របសម្រួលការធ្វើតេស្តហ័សរកសារធាតុញៀន ពិធីអបអរសាទរបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ពិធីអបអរសាទរ

សមិទ្ធផលការងារ ១ឆ្នាំរបស់ក្រសួងអធិការកិច្ច ពិធីសំណេះសំណាលថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ពិធីបើកកម្មវិធីបរិច្ចាគឈាម ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ទទួលជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ច ផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ពិធីបើក-បិទវគ្គបណ្តុះបណ្តាល ពិធីសម្ពោធស្លាកថ្នាក់រៀន ពិធីបើកថ្នាក់រៀន ភាសាចិន ពិធីបើក-បិទកីឡាជាតិ ពិធីប្រទានភ្លើងជ័យ-ពន្លត់ភ្លើងជ័យ និងចូលរួមកិច្ចប្រជុំផ្សេងៗចំនួន៥៣លើក។

### ២.៦.២. ការងារបុគ្គលិក និងធនធានមនុស្ស

#### *ក. ការងារគ្រប់គ្រងបុគ្គលិក*

ក្រសួងអធិការកិច្ចមានមន្ត្រីរាជការចំនួន ៤៦៤ រូប គឺក្របខណ្ឌ (ក១) ចំនួន ១៥៣ រូប ក្របខណ្ឌ (ក២) ចំនួន១៩១រូប ក្របខ័ណ្ឌ (ក៣) ចំនួន ៨៧រូប ក្របខណ្ឌ (ខ១) ចំនួន៨រូប ក្របខណ្ឌ (ខ២) ចំនួន ៥រូប ក្របខណ្ឌ (ខ៣) ចំនួន ១១រូប ក្របខណ្ឌ (គ) ចំនួន ៩រូប និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ២៦០រូប។ នៅឆ្នាំ ២០២៤ ក្រសួងបានចេញប្រកាសរួមមាន ប្រកាសតែងតាំង ប្រកាសផ្ទេរក្របខ័ណ្ឌ ប្រកាសលុបឈ្មោះ ប្រកាសដាក់ឱ្យមន្ត្រី រាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ប្រកាសអនុញ្ញាតឱ្យចូលបម្រើការងារវិញ ប្រកាសស្តីពីការប្រើប្រាស់មន្ត្រី ជាប់កិច្ចសន្យាសរុប ១៨ ប្រកាស និងបានធ្វើសំណើដំឡើងឋានន្តរស័ក្តិ និងសំណើសុំប័ណ្ណ ប.ស.ស . ធ្វើលិខិតចាត់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចូលរួមកម្មវិធីនានា សំណើសុំនិយ័តអតីតភាពការងារ បានធ្វើឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើម បានរៀបចំបញ្ជីឈ្មោះមន្ត្រីរាជការត្រូវចូលនិវត្តន៍ ក្នុងឆ្នាំ២០២៤ និងធ្វើសំណើសុំ ពិនិត្យ ផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល នៃក្រសួងអធិការកិច្ច ប្រចាំខែ

- បានធ្វើសេចក្តីជូនដំណឹងស្តីពីការរៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញឌីជីថលចាំបាច់ និងជំនាញបច្ចេកទេស ឌីជីថល របស់វិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងអធិការកិច្ច
- បានធ្វើបច្ចុប្បន្នភាពក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាន នៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បានធ្វើរបាយការណ៍ស្តីពីបច្ចុប្បន្នភាពរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ដែលបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- បានធ្វើរបាយការណ៍ស្តីពីសម្រង់អវត្តមានរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលកំពុងបម្រើការងារនៅតាមនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៣ វិទ្យាស្ថានជាតិអធិការកិច្ច នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី ខេត្ត
- បានប្រគល់ជូនសាមីខ្លួននូវវិញ្ញាបនបត្រ ស្តីពីការផ្តាច់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់មន្ត្រីរាជការស៊ីវិល ក្នុងភាពទំនេរគ្មានបៀវត្សលើកទី១ រយៈពេល១២ខែ របស់មន្ត្រីរាជការចំនួន១រូប
- បានប្រគល់ជូនសាមីខ្លួន នូវអនុក្រឹត្យស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន២៦រូប
- បានប្រគល់ជូនសាមីខ្លួន នូវសំណើសុំរៀបចំរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍តាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងមន្ទីរ អង្គភាពថ្នាក់ក្រោមជាតិ
- បានចម្លងត្រឹមត្រូវតាមច្បាប់ដើមប្រកាសលេខ០១៤/២៤ អ.ធ.ក.ប្រ.ក ស្តីពីការទទួលក្របខ័ណ្ឌមន្ត្រីរាជការក្រសួងអធិការកិច្ច

- បានចម្លងត្រឹមត្រូវតាមច្បាប់ដើមសេចក្ដីសម្រេចលេខ១៦៥២/២៤ ម.ស.សសរ ស្ដីពីការចូលបំពេញការងាររបស់សិស្សមន្ត្រីសាលាភូមិន្ទរដ្ឋបាលជំនាន់ប្រជាជាតិជាចម្បង

- បានចម្លងត្រឹមត្រូវតាមច្បាប់ដើមសេចក្ដីសម្រេចលេខ១៦២៩២/២៤ម.ស.សសរស្ដីពីការចូលបំពេញការងាររបស់សិស្សមន្ត្រីសាលាភូមិន្ទរដ្ឋបាលជំនាន់កម្ពុជាក្នុងបេះដូងខ្ញុំ

- បានរៀបចំបញ្ជីឈ្មោះមន្ត្រីរាជការដល់អាយុចូលនិវត្តន៍ក្នុងឆ្នាំ២០២៤

- បានប្រគល់ជូនសាមីខ្លួននូវ (១) សលាកបត្រមន្ត្រីរាជការចូលនិវត្តន៍នៅខែធ្នូ ឆ្នាំ២០២៤ របស់មន្ត្រីរាជការចំនួន១រូប (២) វិញ្ញាបនបត្រផ្ដាច់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់មន្ត្រីរាជការចំនួន១រូបសុំលាឈប់ពីក្របខ័ណ្ឌ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៤

- បានចម្លងត្រឹមត្រូវតាមច្បាប់ដើម៖ (១) អនុក្រឹត្យលេខ១០៣៨ អនក្រ.តត ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ ស្ដីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រ ជូនមន្ត្រីរាជការចំនួន១១រូប និង (២) ព្រះរាជក្រឹត្យលេខ នស/រកត/១០២៤/១៣២៦ ស្ដីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន៦រូប

- បានធ្វើ និងបញ្ជូនលិខិតស្ដីពីសំណើសុំពិនិត្យ និងផ្ដល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្ដូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល រៀងរាល់ខែ ក្នុងឆ្នាំ២០២៤ ជូនទៅក្រសួងមុខងារសាធារណៈ

- បានធ្វើ និងបញ្ជូនលិខិតស្ដីពីការបើកប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាជារៀងរាល់ខែ ជូនទៅធនាគារអេស៊ីលីដា។

### *ខ. ការងារធនធានមនុស្ស*

ក្រសួងបានផ្ដោតការយកចិត្តទុកដាក់ខ្ពស់លើការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ជាលទ្ធផល ឯកឧត្តមរដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រីរាជការបានជំរុញការកសាង និងអភិវឌ្ឍន៍មូលធនមនុស្សមួយចំនួនដូចខាងក្រោម៖

- ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល (១) ជាមួយបេក្ខជន និងបេក្ខនារីអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង និងប្រទេសនូវែលសេឡង់ (២) ជាមួយនិស្សិតជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលអូស្ត្រាលីចំនួន១២រូប (៣) ជាមួយអតីតសិស្សមន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្រមការ នៃសាលាភូមិន្ទរដ្ឋបាលចំនួន១០រូប

- ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ដល់ជំនួយសម្រាប់វគ្គបណ្ដុះបណ្ដាល "ការស្រាវជ្រាវផ្អែកលើការស្ទង់មតិ" រវាងក្រសួងអធិការកិច្ច និងអង្គការមូលនិធិអាស៊ី

ក្នុងក្របខ័ណ្ឌក្រសួង ការកសាងនិងអភិវឌ្ឍន៍ធនធានមនុស្ស ទទួលបានលទ្ធផល ដូចខាងក្រោម៖

- ធ្វើសេចក្ដីជូនដំណឹង (១) ការរៀបចំបើកវគ្គបណ្ដុះបណ្ដាលជំនាញឌីជីថលចាំបាច់ និងជំនាញបច្ចេកទេសឌីជីថល របស់វិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (២) អាហារូបករណ៍របស់ប្រទេសនូវែលសេឡង់ ក្នុងឆ្នាំ២០២៤ (៣) ការជ្រើសរើសមន្ត្រីរាជការក្រសួងចូលរួមវគ្គបណ្ដុះបណ្ដាល រយៈពេលខ្លី របស់ប្រទេសនូវែលសេឡង់ និង (៤) អាហារូបករណ៍ JDS ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតនៅប្រទេសជប៉ុន សម្រាប់ឆ្នាំ២០២៥

ក្រសួងបានរៀបចំ និងចាត់បញ្ជូនមន្ត្រីរាជការចំនួន ៥៧៤ រូប ចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញផ្សេងៗ នៅក្នុងប្រទេស និងក្រៅប្រទេស ក្នុងនោះរួមមាន៖

- ចំនួន ៤០រូប ទៅបណ្តុះបណ្តាល ២វគ្គ នៅសាធារណរដ្ឋឥណ្ឌា

- ចំនួន៨២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញឌីជីថលចាំបាច់ និងជំនាញបច្ចេកទេសឌីជីថល នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៃបណ្ឌិត្យសភា បច្ចេកវិទ្យាឌីជីថលកម្ពុជា

- ចំនួន១៥រូប ចូលរួមវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម នៅសណ្ឋាគារសុខាភ្នំពេញ

- ចំនួន៧រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ឆ្នាំ២០២៤ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចំនួន៤រូប ចូលរៀនវគ្គវិក្រឹត្យការ នៅសាលាភូមិន្ទរដ្ឋបាល

- ចំនួន៤ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី៖ (១) ជំនាញភាសាអង់គ្លេស និងទំនាក់ទំនងកម្រិតមធ្យម ចំនួន ២រូប និង ជំនាញភាសាអង់គ្លេសថ្នាក់មធ្យម និងជំនាញប្រស្រ័យទាក់ទង (Intermediate English Language and Communication Skills) ចំនួន ២រូប

- ចំនួន១០រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំបរិវត្តកម្មឌីជីថល នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថល

- ចំនួន៣រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ តាមប្រព័ន្ធអនឡាញ

- ចំនួន៥០រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអក្ខរកម្មព័ត៌មាន ទិន្នន័យ និងសន្តិសុខសាយប័រ នៅវិទ្យាស្ថានអភិបាលកិច្ច នៃបណ្ឌិត្យសភាបច្ចេកវិទ្យា

- ចំនួន១០៨រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការតាក់តែងលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្ត នៅសាលាភូមិន្ទរដ្ឋបាល

- ចំនួន៧រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែន (NRMIS) សម្រាប់ដំណាក់កាលទី៣ នៅសណ្ឋាគារសុខាខេត្តព្រះសីហនុ

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍកម្មវិធី នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសន្តិសុខសាយប័រ នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៤

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបណ្តាញកុំព្យូទ័រ នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យនីត្យានុកូលភាព នៅទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រ និងវិភាគស្ថិតិកម្រិត១ នៅក្រសួងផែនការ នៅថ្ងៃទី១២-១៦ ខែសីហា ឆ្នាំ២០២៤

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះ នៃការប្រើប្រាស់FMIS នៅសាកលវិទ្យាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី៩-២៣ ខែកញ្ញា ឆ្នាំ២០២៤

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងគ្រប់គ្រង និងការលើកកម្ពស់សីលធម៌សង្គម នៅមន្ទីរកិច្ចការនារី ខេត្តកែប នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៤

- ចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅមន្ទីរកិច្ចការនារីខេត្តកែប នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤

- វិទ្យាស្ថានជាតិអធិការកិច្ច បានបើកវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចបឋមជំនាន់ទី៦ ចំនួន៦វគ្គ ដែលមានសិក្ខាកាមសរុប ចំនួន១៥៤ មកពីក្រសួង ស្ថាប័ន ចំនួន ១៦ និងខេត្តចំនួន៧ ក្នុងនោះ (១) វគ្គ១ និងវគ្គ២ មានសិក្ខាកាម ចំនួន៥២រូប (២) វគ្គ៣ និងវគ្គ៤ មានសិក្ខាកាមចំនួន៥២រូប និង (៣) វគ្គ៥ និងវគ្គ៦ មានសិក្ខាកាម ចំនួន៥០រូប ។

## ២.៦.៣. ការងារហិរញ្ញវត្ថុ និងលទ្ធកម្ម

### *ក. ថវិកាកម្មវិធី*

ក្រសួងអធិការកិច្ចពុំមានប្រភពចំណូលសម្រាប់ទ្រទ្រង់ហិរញ្ញវត្ថុនោះទេ។ កញ្ចប់ថវិកា ឆ្នាំ២០២៤ របស់ក្រសួង មានចំនួន ៤៨.២៦២ ពាន់លានរៀល (ប្រហែល ១២,០៤ លានដុល្លាអាមេរិក) ដែលក្នុងនោះ ថវិកា ថ្នាក់កណ្តាល មាន ២៧.២១៥,៧ ពាន់លាន រៀល ឬ ៥៦,៣០% និងថ្នាក់រាជធានីខេត្ត មាន ២១.០៤៦,៣ ពាន់លានរៀល ឬ៤៣,៦១ % នៃថវិកាសរុប ។

ចំពោះការអនុវត្តការចំណាយសរុប ក្នុងឆ្នាំ ២០២៤ សរុបអនុវត្តបាន ៩៤.៣១ % ក្នុងនោះ ថ្នាក់កណ្តាល អនុវត្តបាន៩២.៣២ % និងថ្នាក់រាជធានី ខេត្តអនុវត្តបាន ៩៦.៨៩ %។

នៅឆ្នាំ ២០២៤ ក្រសួងមានអង្គភាពថវិកា ចំនួន ៤ ចែកជា ៣ អង្គភាពនៅថ្នាក់កណ្តាល និងមួយអង្គភាព នៅតាមបណ្តាមន្ទីររាជធានី ខេត្ត។ អង្គភាពថវិកានៅថ្នាក់កណ្តាល ជាអង្គភាពថវិកាអាណាប័កមិនទាន់ផ្ទេរសិទ្ធិ។ ចំណែកអង្គភាពថវិកាដែលជាមន្ទីរអធិការកិច្ចរាជធានី ខេត្ត ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។

ក្នុងថវិកាកម្មវិធី ឆ្នាំ២០២៤ ក្រសួងមានគោលបំណងគោលនយោបាយ គឺ៖ ការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការអប់រំ បង្ការ ទប់ស្កាត់បាតុភាពអសកម្ម បង្កើនគណនេយ្យភាព ប្រសិទ្ធភាពការងារ និងពង្រឹងនីតិរដ្ឋ។

រចនាសម្ព័ន្ធថវិកាកម្មវិធី របស់ក្រសួងអធិការកិច្ចមានកម្មវិធីចំនួនមួយ គឺ៖ កិច្ចការអធិការកិច្ច ដែលចែកចេញជាអនុកម្មវិធី ចំនួន ៤ និងចង្កោមសកម្មភាព ៣២ ចង្កោមសកម្មភាព (៧ នៅថ្នាក់កណ្តាល និង ២៥ នៅថ្នាក់ក្រោមជាតិ) ដូចខាងក្រោម៖

- អនុកម្មវិធីទី១៖ ការងារអប់រំផ្សព្វផ្សាយច្បាប់ (ចង្កោមកម្មវិធី ២ គឺ៖ (១) ការងារនីតិកម្ម និងអប់រំផ្សព្វផ្សាយច្បាប់ (២) ការងារទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន)។

- អនុកម្មវិធីទី២៖ ការងារអធិការកិច្ច (ចង្កោមសកម្មភាព ២ គឺ៖ (១) ការងារអធិការកិច្ចលើវិស័យសេដ្ឋកិច្ច សន្តិសុខ ការពារជាតិ រដ្ឋបាលទូទៅ និងសង្គមកិច្ច ការគាំទ្ររដ្ឋបាលទូទៅ និង (២) ការងារតាមដានការអនុវត្តច្បាប់ ទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ)។

- អនុកម្មវិធីទី៣៖ សេវាគាំទ្រទូទៅ (ចង្កោមសកម្មភាព ៣ គឺ៖ (១) ការគ្រប់គ្រងរដ្ឋបាល និងកិច្ចការទូទៅ (២) ការគ្រប់គ្រងសវនកម្មផ្ទៃក្នុង និង (៣) ការគ្រប់គ្រងវិទ្យាស្ថានជាតិអធិការកិច្ច)។

- អនុកម្មវិធីទី៤៖ ការងារអធិការកិច្ចរាជធានី ខេត្ត ដែលចែកជាចង្កោមសកម្មភាពចំនួន ២៥ (១ ក្នុង១ រាជធានី ខេត្ត)។

### *ខ.ការងារលទ្ធកម្ម*

គម្រោងលទ្ធកម្ម ក្នុងឆ្នាំ ២០២៤ មានតម្លៃសរុប ៣.៩៨៣ លានរៀល ដែលអនុវត្តបានជាក់ស្តែងមានតម្លៃគម្រោងសរុប ៣.៦៩៤ លានរៀល ឬស្មើនឹង ៩២.៧៤ %។ ក្រសួងបានអនុវត្តកិច្ចលទ្ធកម្មចំនួន ១២ គម្រោង ក្នុងនោះ លទ្ធកម្មទំនិញមានចំនួន ១០កិច្ចសន្យា លទ្ធកម្មសេវាកម្មចំនួន ០១កិច្ចសន្យា និងលទ្ធកម្មសំណង់ចំនួន០១ កិច្ចសន្យា។

***គ. ការងារផ្សេងទៀត***

នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់បានអនុវត្ត និងសម្រេចការងារសំខាន់ៗដូចខាងក្រោម៖

- នាយកដ្ឋានបានទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ដើម្បីស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជា រដ្ឋទេយ្យបុរេប្រទានថវិកា សម្រាប់បៀវត្សដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេសជាដើម

- បានទូទាត់បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស ថ្លៃចំណាយប្រើប្រាស់ទឹកភ្លើង បើកប្រាក់បៀវត្ស និងផ្គត់ផ្គង់ សម្ភារៈ ប្រេងសាំងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាន់ពេលវេលា

- បានបូកសរុបរបាយការណ៍ចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

- បានប្រជុំរៀបចំសេចក្តីព្រាងផែនការថវិកាឆ្នាំ២០២៥ និងការវិភាគមុខងារមន្ត្រីរាជការ

- បានកែសម្រួលផែនការលទ្ធកម្មរបស់មន្ទីរខេត្តព្រះវិហារ (បន្តអនុវត្តតាមផែនការចាស់វិញ)

- បានបញ្ជូនមន្ត្រីរាជការចូលរួមសិក្ខាសាលារបស់លេខាធិការដ្ឋានFMIS និងវគ្គបណ្តុះបណ្តាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានរៀបចំឯកសារប្រគល់ទទួលម៉ូតូម៉ាកHonda Dreamចំនួន៦គ្រឿង

- បានទទួលរថយន្តចំនួន២គ្រឿងដែលជាការឧបត្ថម្ភរបស់ក្រុមហ៊ុនប៊ូយ៉ុង

- បានចុះផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋចំនួនពីរខេត្តរួមមាន៖ (១) ខេត្តប៉ៃលិន ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ និងខេត្តកែប ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤

- បានអមដំណើរ ឯកឧត្តមរដ្ឋមន្ត្រី ក្នុងពិធីប្រគល់-ទទួលរថយន្ត Toyota Hilux Ravo V-Edition 2024 ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ជូនក្រសួងអធិការកិច្ច នៅទីស្តីការក្រសួង

- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០២៤-២០២៨។

### ២.៦.៤. ការងារផែនការ និងស្ថិតិ

នាយកដ្ឋានផែនការ ស្ថិតិបានអនុវត្ត និងបំពេញភារកិច្ចការងារមានដូចខាងក្រោម៖

- ក្រសួងបានរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (ឆ្នាំ២០២៥-២០២៧) បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០២៤-២០២៨ និងបានរៀបចំគម្រោងផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៥-២០២៧

- ក្រសួងនៅបានរៀបចំបូកសរុប និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យ ដើម្បីត្រៀមផ្ញើជូនក្រសួងផែនការ និងទីស្តីការគណៈរដ្ឋមន្ត្រី និងបានបញ្ចប់ការរៀបចំផែនការតាមដានសមិទ្ធកម្មប្រចាំឆ្នាំ២០២៤របស់ក្រសួងទាំងមូលផងដែរ

- បានរៀបចំកែសម្រួលឡើងវិញ និងសម្រេចបន្ថែមធាតុចូលថ្មីៗមួយចំនួនលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០២៤-២០២៨ របស់ក្រសួងអធិការកិច្ច ជូនក្រសួងផែនការ

- បានរៀបចំការងារពិភាក្សាស្តីពីសូចនាករសមិទ្ធកម្ម និងគោលដៅសូចនាករលើគម្រោងថវិកាកម្មវិធីឆ្នាំ ២០២៤ របស់ក្រសួង ជូនក្រសួងផែនការ

- បានរៀបចំធាតុចូលសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ឆ្នាំ២០២៤-២០៣០ ដើម្បីអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងការអភិវឌ្ឍ

- បានបន្តរៀបចំកែសម្រួលធាតុចូលសូចនាករសមិទ្ធកម្ម និងគោលដៅគម្រោងថវិកាកម្មវិធីឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី ខេត្ត

- បានធ្វើសំណើសុំរៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២៥-២០២៧ និងគម្រោងថវិកាប្រចាំឆ្នាំ២០២៥ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត

- បានរៀបចំបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២៥-២០២៧ និងគម្រោងថវិកាប្រចាំឆ្នាំ ២០២៥ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត

- បានបន្តរៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២៥-២០២៧ និងគម្រោងថវិកាប្រចាំឆ្នាំ២០២៥ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត

- បានរៀបចំបង្កើតក្រុមការងារថ្មីសម្រាប់ការពារកញ្ចប់ថវិកាប្រចាំឆ្នាំ២០២៥ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត

- បានរៀបចំលិខិតបង្គាប់ការក្រុមការងារថ្មីសម្រាប់ការពារកញ្ចប់ថវិកាប្រចាំឆ្នាំ២០២៥ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានបន្តរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២៥-២០២៧ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត ព្រមទាំងបានរៀបចំធ្វើជាសៀវភៅដើម្បីចែកជូនថ្នាក់ដឹកនាំ

- បានកែសម្រួលចុងក្រោយផែនការយុទ្ធសាស្ត្រថវិកា ២០២៥-២០២៧ និងគម្រោងថវិកាប្រចាំឆ្នាំ ២០២៥ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត

- បានរៀបចំផែនការសកម្មភាព ២០២៥-២០២៧ នៃការអនុវត្តគោលនយោបាយជាតិប្រជាជន ២០២៦-២០៣០

- បានរៀបចំបូកសរុប និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិផ្លូវការ ដែលមានការចាត់តាំងតាមវិស័យ ទទួលបានពីថ្នាក់កណ្តាល និងថ្នាក់មន្ទីររាជធានី ខេត្ត ដើម្បីសរុបជារបាយការណ៍សមិទ្ធផលរបស់ក្រសួង និងត្រៀមផ្ញើជូនក្រសួងផែនការ និងទីស្តីការគណៈរដ្ឋមន្ត្រី

- បានរៀបចំបូកសរុប និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិផ្លូវការ ដែលមានការចាត់តាំង តាមវិស័យដែលទទួលបានពីថ្នាក់កណ្តាល និងថ្នាក់រាជធានីខេត្ត របស់ក្រសួងអធិការកិច្ចធ្វើជាសៀវភៅ សម្រាប់ចែកជូនថ្នាក់ដឹកនាំក្រសួង

- បានរៀបចំបោះពុម្ពសៀវភៅស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យឆ្នាំ២០២៣ របស់ក្រសួងអធិការកិច្ច ដើម្បីចែកជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងបណ្តាអង្គភាពពាក់ព័ន្ធ

- បានរៀបចំសំណើចុះរៀបចំចងក្រងប្រព័ន្ធទិន្នន័យស្ថិតិផ្លូវការ ដែលមានការចាត់តាំងតាមវិស័យប្រចាំឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច និងបណ្តាមន្ទីររាជធានី ខេត្ត

- បានរៀបចំការងារចងក្រងប្រព័ន្ធទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំង តាមវិស័យ ប្រចាំឆ្នាំ២០២៤

- បានរៀបចំបូកសរុបគម្រោងរបាយការណ៍ស្តីពីលទ្ធផលការអនុវត្តថវិកាកម្មវិធី ប្រចាំឆមាសទី១ ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី ខេត្តទាំង២៥ នៃក្រសួងអធិការកិច្ច

- បានរៀបចំផែនការតាមដានសមិទ្ធកម្មប្រចាំឆ្នាំ២០២៤ របស់ក្រសួង និងបានរៀបចំបូកសរុបគម្រោងរបាយការណ៍សមិទ្ធកម្ម តាមដានការអនុវត្តកម្មវិធី ប្រចាំឆ្នាំ២០២៤របស់ក្រសួង

- បានរៀបចំគម្រោងផែនការសកម្មភាព សម្រាប់ការិយាល័យតាមដាន និងវាយតម្លៃ ក្នុងឆ្នាំ២០២៤

- បានរៀបចំមេរៀនវគ្គបណ្តុះបណ្តាលស្តីពីការតាមដានត្រួតពិនិត្យតាមដាន វាយតម្លៃក្នុងឆ្នាំ២០២៤

- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងពិធីផ្សេងៗចំនួន៨២លើក។

## ២.៦.៥. ការងារសវនកម្មផ្ទៃក្នុង

ការងារសវនកម្មផ្ទៃក្នុងបានសម្រេចលទ្ធផលដូចខាងក្រោម៖

- បានចុះធ្វើសវនកម្ម លើការគ្រប់គ្រងការប្រើប្រាស់សង្ហារិម សម្ភារៈបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា សម្ភារៈបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា នៅទីស្តីការក្រសួងចំនួន១៤នាយកដ្ឋាន និងវិទ្យាស្ថានជាតិអធិការកិច្ច

- បានចុះធ្វើសវនកម្មលើការដឹកនាំ និងការគ្រប់គ្រងធនធានមនុស្ស ទ្រព្យសម្បត្តិរដ្ឋ ការប្រើប្រាស់ចំណូល-ចំណាយថវិការដ្ឋ ក្នុងការិយបរិច្ឆេទ២០២៣ នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៥ គឺខេត្តស្ទឹងត្រែង កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន កំពង់ធំ សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ ខេត្តកណ្តាល រាជធានីភ្នំពេញ រតនគិរី មណ្ឌលគិរី និងខេត្តព្រះសីហនុ

- បានចុះសិក្សាស្រាវជ្រាវករណី មន្ត្រីជាប់កិច្ចសន្យាម្នាក់នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបាត់ដំបងចំនួន១លើក

- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងពិធីផ្សេងៗចំនួន៦៧លើក។

## ២.៦.៦. ការងារវិទ្យាស្ថានជាតិអធិការកិច្ច

វិទ្យាស្ថានជាតិអធិការកិច្ចបានអនុវត្ត និងបំពេញភារកិច្ចសំខាន់ៗមានដូចខាងក្រោម៖

- បានផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋមចំនួន៦វគ្គ ជូនសិក្ខាកាមចំនួន ១៥៤រូប មកពីក្រសួងស្ថាប័នចំនួន ១៦ និងសាលារាជធានី ខេត្តចំនួន ៧

- បានសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលស្តីពី **"ការស្រាវជ្រាវផ្អែកលើការស្ទង់មតិ"** (Survey-based Research) ជូនមន្ត្រីរាជការចំនួន ៦០នាក់ នៃក្រសួងអធិការកិច្ច ដែលជាជំនួយសហប្រតិបត្តិការរវាងអង្គការមូលនិធិអាស៊ីប្រចាំនៅកម្ពុជា (The Asia Foundation) និងវិទ្យាស្ថានជាតិអធិការកិច្ច

- បានពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងចរន្តការងារទូទៅរបស់វិទ្យាស្ថាន និងការងារផ្សេងទៀត ដូចជាការបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាសទី១ ឆមាសទី១ នព្វមាស និងឆ្នាំ២០២៤ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ ការរៀបចំផែនការសកម្មភាពឆ្នាំ២០២៥ របស់វិទ្យាស្ថាន ការរៀបចំគម្រោងថវិកាកម្មវិធីឆ្នាំ២០២៥ របស់វិទ្យាស្ថាន

- បានរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចឆ្នាំ២០២៥ របស់វិទ្យាស្ថាន

- បានរៀបចំរបាយការណ៍សមិទ្ធកម្មស្តីពីលទ្ធផលការអនុវត្តថវិកាកម្មវិធី/អនុកម្មវិធីប្រចាំឆ្នាំ ឆមាស និងប្រចាំឆ្នាំ២០២៤ របស់វិទ្យាស្ថាន

- បានរៀបចំរបាយការណ៍អំពីការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីរបស់វិទ្យាស្ថាន

- បានសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស្រាវជ្រាវផ្អែកលើការស្ទង់មតិ ជូនមន្ត្រីរាជការក្រសួងអធិការកិច្ចចំនួន៦០រូប

- បានរៀបចំសេចក្តីព្រាងសៀវភៅកម្រងអនុសាសន៍សម្តេចធិបតីចំនួន៤វ៉ុល

- បានរៀបចំសេចក្តីព្រាងព្រឹត្តិបត្រអធិការកិច្ចចំនួន១វ៉ុល

- បានចុះស្ទង់មតិស្តីពីការអភិវឌ្ឍមូលធនមនុស្ស ក្នុងវិស័យអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន២០មន្ទីរ

- បានស្រាវជ្រាវប្រមូលផ្តុំលិខិតបទដ្ឋានគតិយុត្តនានា សរុបចំនួន៤៦២ច្បាប់ និងបានចងក្រងអនុសាសន៍សម្តេចធិបតី សរុបចំនួន៣៣ច្បាប់

- បានទំនាក់ទំនងទទួលសៀវភៅចម្រុះមុខវិជ្ជាចំនួន៦៣ក្បាល

- បានផ្សព្វផ្សាយអំពីសកម្មភាពថ្នាក់ដឹកនាំក្រសួង វិទ្យាស្ថាន និងលិខិតផ្សេងៗ ក្នុងផេករបស់វិទ្យាស្ថាន ចំនួន២៩៧លើក

- បានតាមដាន និងទទួលអ្នកចុច Likeចំនួន៣,៣០០នាក់ Shareចំនួន១,៣០៤នាក់ និងComment ចំនួន៩៦នាក់ លើផេករបស់វិទ្យាស្ថានអធិការកិច្ច។

## ២.៧. ការងារសហប្រតិបត្តិការ និងភាពជាដៃគូ

ការងារសហប្រតិបត្តិការអន្តរជាតិជាការងារជំរុញគាំទ្រវិស័យការងារកិច្ចមួយក្នុងចំណោមការងារគាំទ្រដទៃទៀត ឯកឧត្តមរដ្ឋមន្ត្រីបានយកចិត្តទុកដាក់ខ្ពស់ ជំរុញពង្រីកលើយន្តការដែលមានស្រាប់សម្រាប់ការរីកចម្រើននៃវិស័យអធិការកិច្ចនាពេលអនាគត។

សកម្មភាពការងារនៃកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិបានទទួលនូវលទ្ធផល ដូចខាងក្រោម៖

### ២.៧.១. ការជួបសម្តែងការគួរសម និងចូលរួមពិធីផ្សេងៗ

ឯកឧត្តមរដ្ឋមន្ត្រី និងប្រតិភូតំណាងក្រសួងអធិការកិច្ចបានចូលរួមក្នុងកម្មវិធី មានដូចខាងក្រោម៖

- ពិធីអបអរសាទរបុណ្យជាតិ នៃប្រទេស ចំនួន ៦ និង ចូលរួមក្នុង (១) ពិធីចម្រើនព្រះជន្មព្រះចៅអធិរាជជប៉ុន នៅស្ថានទូតជប៉ុន នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ (២) ពិធីខួបកំណើតគម្រប់១១២ឆ្នាំ របស់ឯកឧត្តម គីម អ៊ីលស៊ុង នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ និង (៣) ពិធីបុណ្យចម្រើនព្រះជន្ម៧៦ឆ្នាំ នៃព្រះមហាក្សត្រចក្រភពអង់គ្លេស ព្រះបាទ ឆាលស៍ ទី៣ (King Charles III) នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤

- ទទួលជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតនៃប្រទេសជាមិត្តនានា ចំនួន ៩ លើក

- ទទួលជួបពិភាក្សាការងារជាមួយ ប្រធានក្រុមហ៊ុនក្នុងវិស័យឯកជន និងអង្គការនានា ចំនួន១៤ លើក

- អញ្ជើញចូលរួមពិធីបិទមហោស្រពភាពយន្តអន្តរជាតិ-កម្ពុជាលើកទី១៣ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

- ចូលរួមគោរពវិញ្ញាណក្ខន្ធឯកឧត្តម Nguyen Phu Trong អគ្គលេខាធិការ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម នៅស្ថានទូតវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

- ចូលរួមកម្មវិធីCocktail ដើម្បីទទួលស្វាគមន៍គណៈប្រតិភូ IDC-CDI ដែលចូលរួមកិច្ចប្រជុំគណៈកម្មា-ធិការប្រតិបត្តិអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៤

- ចូលរួមកម្មវិធីបើកវេទិកាពិសេស ស្តីពីតួនាទីយុវជនក្នុងសន្តិភាព កិច្ចសន្ទនា សហគ្គិភាព និងការឆ្លើយតបបញ្ហាប្រឈម និងកិច្ចពិភាក្សាស្តីពីធម្មនុញ្ញសន្តិភាពដើម្បីមនុស្សជាតិ និងភពផែនដី ក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ (IDC-CDI) នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤

- ចូលរួមថ្លែងសន្និសីទសារព័ត៌មាន ស្ដីពីលទ្ធផលកិច្ចប្រជុំប្រកបដោយជោគជ័យខ្ពស់ ក្នុងឱកាសដែលគណបក្សប្រជាជនកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះ និងអញ្ជើញចូលរួមពិធីលាងសាយភោជន៍ជាមួយគណៈប្រតិភូ IDC-CDI នៅខេត្តសៀមរាប នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤

- ជូនដំណើរគណៈប្រតិភូ IDC-CDI ទស្សនកិច្ចក្នុងតំបន់បេតិកភណ្ឌប្រវត្តិសាស្ត្រអង្គរ ដើម្បីបង្ហាញពីប្រវត្តិសាស្ត្រ អរិយធម៌ វប្បធម៌ដ៏រុងរឿងរបស់កម្ពុជា ក៏ដូចជាការជំរុញភ្ញៀវទេសចរណ៍អញ្ជើញមកទស្សនាកម្ពុជាក្រោមម្លប់សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ និងរៀបចំពិធីអាហារថ្ងៃត្រង់ជូនគណៈប្រតិភូ IDC-CDI នៅសណ្ឋាគារបុរីអង្គរ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤

- ចូលរួមក្នុងព្រឹត្តិការណ៍សម្ដែងសិល្បៈពិសេស ក្រោមប្រធានបទ "ពាក្យសច្ចាព័ណ៌មាស" ដែលជាផ្នែកមួយនៃយុទ្ធនាការឆ្នាំនៃការផ្លាស់ប្ដូរប្រជាជន និងប្រជាជនកម្ពុជា-ចិន២០២៤ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤។



*រូបថតអនុស្សាវរីយ៍ **ឯកឧត្តម ហួត ហាក់** អតីតរដ្ឋមន្ត្រីក្រសួងអធិការកិច្ច ជាមួយឯកឧត្តម Dominic Williams ឯកអគ្គរាជទូតនៃចក្រភពអង់គ្លេសប្រចាំព្រះរាជាណាចក្រកម្ពុជាក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅទីស្ដីការក្រសួងអធិការកិច្ច*

## ២.៧.២. ដំណើរទស្សនកិច្ច

ដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិ ក្រសួងបានធ្វើទស្សនកិច្ច ចំនួន ២លើក មានដូចខាងក្រោម៖

- លើកទី១៖ គណៈប្រតិភូក្រសួងអធិការកិច្ចចំនួន១១រូប ដឹកនាំដោយលោកជំទាវ **សុខ វិទ្យាយ** រដ្ឋលេខាធិការប្រចាំការ បានអញ្ជើញទៅទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីដកស្រង់បទពិសោធការងារច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅថ្ងៃទី១០ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤

- លើកទី២៖ គណៈប្រតិភូជាន់ខ្ពស់ក្រសួងអធិការកិច្ចចំនួន១០រូប ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី **ហួត ហាក់** បំពេញទស្សនកិច្ចផ្លូវការ រយៈពេលមួយសប្ដាហ៍ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃ៩ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤។ ជាលទ្ធផល គណៈប្រតិភូបានជួបជាមួយថ្នាក់ដឹកនាំវៀតណាមសំខាន់ៗ រួមមាន ឯកឧត្តម **ផាម មិញឈិញ** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ឯកឧត្តម **ឌ័ន ហុង ហ្វុង** អគ្គអធិការ នៃអធិការកិច្ចរដ្ឋាភិបាលវៀតណាម ឯកឧត្តម Duong Ngoc Hai អនុប្រធានគណៈកម្មាធិការប្រជាជន និងជាប្រធានគណៈត្រួតពិនិត្យ ទីក្រុងហូជីមិញ និងឯកឧត្តម Vo Van Minh ប្រធាន

គណៈកម្មាធិការ ប្រជាជនខេត្តប៊ិញយឿង។ ឯកឧត្តមរដ្ឋមន្ត្រី បានចុះអនុស្សរណៈ នៃការយោគយល់គ្នាជាមួយឯកឧត្តម **ឡឹន ហុង ហ្វុង** អគ្គអធិការនៃអធិការកិច្ចរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអធិការកិច្ច រវាងក្រសួងអធិការកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង អធិការកិច្ចរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពង្រឹង និងពង្រីកកិច្ចសហ-ប្រតិបត្តិការលើការបណ្តុះបណ្តាលធនធានមនុស្ស ការផ្លាស់ប្តូរទស្សនកិច្ចផ្លូវការ ទស្សនកិច្ចសិក្សា និងបទពិសោធលើការងារអធិការកិច្ច ការងារទទួល និងដោះស្រាយបណ្តឹង សំដៅចូលរួមលើកកម្ពស់អភិបាលកិច្ចល្អ ពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ និងទប់ស្កាត់អំពើអសកម្មនានា។ គណៈប្រតិភូក៏បានជួបពិភាក្សាជាមួយវិស័យឯកជននៅសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនវៀតណាមធំៗ ចំនួន៤រួមមាន៖ សម្ព័ន្ធក្រុមហ៊ុន VIETTEL, សម្ព័ន្ធក្រុមហ៊ុនប្រេង និងឧស្ម័នវៀតណាម (PETROVIETNAM), ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម (BIDV), ក្រុមហ៊ុនឧស្ម័នវៀតណាម (PV GAS) និងមជ្ឈមណ្ឌលផ្គត់ផ្គង់និងចែកចាយឧស្ម័នវៀតណាម ដែលជាបុត្រសម្ព័ន្ធរបស់ PETROVIETNAM។

### ២.៧.៣. ការទទួលគណៈប្រតិភូដៃគូសហប្រតិបត្តិការ

ក្រសួងអធិការកិច្ចបានរៀបចំ និងសម្របសម្រួល ទទួលគណៈប្រតិភូសាលាបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច នៃអធិការកិច្ចរដ្ឋាភិបាលវៀតណាម ចំនួន១៥ រូប មកបំពេញទស្សនកិច្ចការងារនៅកម្ពុជា នៅពីថ្ងៃទី២៧-៣០ ខែតុលា ឆ្នាំ២០២៤។

### ២.៧.៤. សហប្រតិបត្តិការ និងភាពជាដៃគូ

- ក្រសួងបានចុះអនុស្សរណៈ នៃការយោគយល់គ្នា (១) ជាមួយក្រសួងព័ត៌មាន ស្តីពីកិច្ចសហប្រតិបត្តិការផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍ នៅប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ (២) ជាមួយសាលាភូមិន្ទរដ្ឋបាល នៃក្រសួងមុខងារ សាធារណៈស្តីពីកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីចំនួន១០៨នាក់ ទៅបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ (៣) ជាមួយអធិការកិច្ចរដ្ឋាភិបាលវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអធិការកិច្ច នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានអនុវត្ត និងបំពេញការងារ មានដូចខាងក្រោម៖

- បានចងក្រងសៀវភៅដំណើរទស្សនកិច្ច ចំនួន២គឺ៖ (១) ដំណើរទស្សនកិច្ច នៅសាធារណរដ្ឋប្រជាមានិតចិន ឆ្នាំ២០១៧ និង (២) ដំណើរទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ឆ្នាំ ២០២៤

- បានសម្របសម្រួលការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំជំនួយស្មារតីស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីចំនួន៧លើក៖ (១) កម្ពុជា-សាធារណរដ្ឋតួកគី (២) កម្ពុជា-ហុងគ្រី (៣) កម្ពុជា-ហ្វីលីពីន (៤) កម្ពុជា-គុយបា (៥) កម្ពុជា-ឥណ្ឌូនេស៊ី (៦) កម្ពុជា-ចិន (៧) កម្ពុជា-សាធារណរដ្ឋម៉ាដាហ្គាស្កា

- បានរៀបចំជំនួយស្មារតីសម្រាប់ឯកឧត្តមរដ្ឋមន្ត្រី ដើម្បីទទួលជួប និងចូលរួមក្នុងកិច្ចជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ អង្គទូត និងភ្ញៀវបរទេស នៅទីស្តីការក្រសួងចំនួន ៨លើក៖ (១) លោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋតួកគីប្រចាំកម្ពុជា (២) ឯកឧត្តមឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពហុងគ្រីប្រចាំទីក្រុងហាណូយសាធារណរដ្ឋសង្គមនិយមវៀតណាម (៣) លោកនាយកវិទ្យាស្ថានខុងជឺរាជបណ្ឌិត-

សភាកម្ពុជា (៤) ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំកម្ពុជា (៥) លោកជំទាវឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពគុយបាប្រចាំកម្ពុជា (៦) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពឥណ្ឌូនេស៊ីប្រចាំកម្ពុជា (៧) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រ កម្ពុជា (៨) លោកជំទាវ អគ្គលេខាធិការព្រឹទ្ធសភាសាធារណរដ្ឋម៉ាដាហ្គាស្កា

- បានទំនាក់ទំនងសម្របសម្រួលការងារជាមួយស្ថានទូតចិនប្រចាំកម្ពុជា និងគណៈកម្មាធិការជាតិត្រួតពិនិត្យចិន (NCS) ដើម្បីពន្លឿនការពិនិត្យ និងកែសម្រួលលើខ្លឹមសារ MOU រវាងក្រសួងអធិការកិច្ច និង NCS ហើយ បច្ចុប្បន្នការងារនេះ ភាគីទាំងពីរពុំទាន់មានការឯកភាពគ្នាលើខ្លឹមសារសេចក្តីព្រាងទាំងស្រុងនៅឡើយ

- បានធ្វើរបាយការណ៍ និងសេចក្តីប្រកាសព័ត៌មានអំពីលទ្ធផល នៃកិច្ចជំនួបពិភាក្សាការងារចំនួន២លើក គឺជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពចិន និងឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ហុងគ្រី

- បានធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងក្រសួងអធិការកិច្ចជាមួយៈ អូស្ត្រាលី ឡាវ ថៃ ម៉ាឡេស៊ី ហុងគ្រី វៀតណាម សិង្ហបុរី ណូវែលសេឡង់ និងឥណ្ឌូនេស៊ី ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំសម្របសម្រួលការងារចាត់ចែងបញ្ជូនលិខិតចំនួន៤លើកៈ (១) អញ្ជើញជូនស្ថានទូតចំនួន២៧ និងអង្គការអន្តរជាតិចំនួន១១ ដើម្បីចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសការងារឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច (២) លិខិតជូនពរថ្ងៃបុណ្យចូលឆ្នាំប្រពៃណីជាតិចិន ជូនឯកឧត្តមឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពចិនប្រចាំកម្ពុជា និង GIV (៣) លិខិតអបអរពិធីបុណ្យចូលឆ្នាំខ្មែរជូនស្ថានទូតចំនួន១៥ និងអង្គការចំនួន៥ (៤) លិខិតជូនពរថ្ងៃបុណ្យចូលឆ្នាំប្រពៃណីជាតិវៀតណាម ជូនឯកឧត្តមឯកអគ្គរដ្ឋទូតវៀតណាមប្រចាំកម្ពុជា និង GIV

- បានរៀបចំបែបបទស្នើសុំធ្វើលិខិតឆ្លងដែនការទូតផ្លូវការជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងដែលត្រូវទៅបំពេញបេសកកម្ម នៅក្រៅប្រទេសសរុបចំនួន៤០ច្បាប់

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីត្រៀមរៀបចំកិច្ចប្រជុំ JCBC កម្ពុជា-ហ្វីលីពីន លើកទី៤ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំខ្លឹមសារ និងស្នើសុំគោលការណ៍រៀបចំបណ្ណជូនពរឆ្នាំសកល (២០២៤-២០២៥) ជូនបណ្តាស្ថានទូត អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំ និងចាត់បញ្ជូនលិខិតថ្លែងអំណរគុណជូនស្ថានទូតតួកគី ស្ថានទូតប្រ៊ុយណេដារូសាលឹម និងអង្គការ The Asia Foundation ដែលបានអបអរសាទរជូនចំពោះឯកឧត្តមរដ្ឋមន្ត្រី ក្នុងឱកាសដែលរាជរដ្ឋាភិបាលតែងតាំង ជារដ្ឋមន្ត្រីក្រសួងអធិការកិច្ច

- បានទំនាក់ទំនងជាមួយ GIV ពិនិត្យកែសម្រួលលើសេចក្តីព្រាង MOU ថ្មី រវាងភាគីទាំងពីរ ជំនួស MOU ចាស់ និងបានធ្វើលិខិតទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្នើសុំពិនិត្យ និងផ្តល់មតិលើសេចក្តីព្រាង MOU នោះ

- បានទំនាក់ទំនងសម្របសម្រួលជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ GIV និងរៀបចំឯកសារពាក់ព័ន្ធផ្សេងៗចំនួន២លើកៈ (១) គណៈប្រតិភូនីតិកម្មក្រសួងចំនួន១១ រូប ដឹកនាំដោយ **លោកជំទាវ សុខ វិឡាយ រដ្ឋលេខាធិការប្រចាំការ** អញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីខែមីនា ឆ្នាំ២០២៤ (២) គណៈប្រតិភូជាន់ខ្ពស់ក្រសួងចំនួន ១០រូប ដឹកនាំដោយ ឯកឧត្តម

រដ្ឋមន្ត្រីអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ និងចុះហត្ថលេខាលើ MOU ថ្មីរវាងភាគីទាំង២ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីខែមិថុនា ឆ្នាំ២០២៤

- បានសម្របសម្រួល និងបដិសណ្ឋារកិច្ចទទួល-ជូនដំណើរភ្ញៀវបរទេសលោក ប៉ែន ស៊ីវុន (Pen Sivun) ប្រធានសមាគម HOME FOUNDATION និងលោក JAHN ARIID STRAY ប្រធានសមាគម CAMBODIAN AID ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមរដ្ឋមន្ត្រី កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ នៅទីស្តីការក្រសួង

- បានសម្របសម្រួល ជាមួយអធិការកិច្ចរដ្ឋាភិបាលវៀតណាម ដើម្បីបញ្ជូនសិក្ខាកាម ក្រសួងអធិការកិច្ចទៅបំពេញទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរជំនាញចំនួន២វគ្គ នៅសាលាបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចវៀតណាម ក្នុងឆ្នាំ២០២៤

- បានចងក្រង និងធ្វើបច្ចុប្បន្នភាពតារាងបញ្ជីឈ្មោះសិក្ខាកាម ដែលបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាមកន្លងមក

- បានរៀបចំ និងចាត់បញ្ជូនលិខិតថ្លែងអំណរគុណជូនឯកឧត្តមអគ្គអធិការ នៃអគ្គធិការកិច្ចរដ្ឋាភិបាលវៀតណាម ករណីអបអរសាទរឯកឧត្តមរដ្ឋមន្ត្រី ដែលបានតែងតាំងជារដ្ឋមន្ត្រីក្រសួងអធិការកិច្ច និងអញ្ជើញឯកឧត្តមរដ្ឋមន្ត្រីទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសវៀតណាម

- បានរៀបចំ និងចាត់បញ្ជូនលិខិតសាររំលែកទុក្ខជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា

- បានធ្វើរបាយការណ៍កិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម (JC) លើកទី២១ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានទំនាក់ទំនងសម្របសម្រួល និងស្នើសុំកិច្ចសហប្រតិបត្តិការពីស្ថានទូតចិនប្រចាំកម្ពុជា ដើម្បីពិនិត្យកែសម្រួលខ្លឹមសារ នៃសេចក្តីព្រាង MOU រវាងក្រសួងអធិការកិច្ច និង គណៈកម្មាធិការជាតិត្រួតពិនិត្យThe National Committee of Supervision (NCS) នៃសាធារណរដ្ឋប្រជាមានិតចិន

- បានទំនាក់ទំនងជាមួយស្ថានទូតថៃប្រចាំកម្ពុជា ដើម្បីត្រៀមសហប្រតិបត្តិការរវាងក្រសួងអធិការកិច្ច និងការិយាល័យដោះស្រាយបណ្តឹង (The Office of Ombudsman) ថៃ

- បានសម្របសម្រួលជាមួយវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីបណ្តុះបណ្តាលភាសាចិនកម្រិតមូលដ្ឋានសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងអធិការកិច្ច នៅទីស្តីការក្រសួងអធិការកិច្ច

- បានទំនាក់ទំនងសម្របសម្រួលជាមួយស្ថានទូតឥណ្ឌាប្រចាំកម្ពុជា និងរៀបចំឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ចំនួន៣៩ រូប (មកពីក្រសួងមហាផ្ទៃចំនួន១រូប) ឱ្យចូលរួមវគ្គបណ្តុះបណ្តាល នៅសាធារណរដ្ឋឥណ្ឌាចំនួន២វគ្គ៖ (១) វគ្គ Public Policy and Governance for Civil Servants កាលពីខែមេសា ឆ្នាំ២០២៤ (២) វគ្គ Performance Audit កាលពីខែឧសភា ឆ្នាំ២០២៤

- បានចូលរួមកិច្ចជំនួបពិភាក្សាការងារជាមួយអង្គការ និងតំណាងវិទ្យាស្ថានចំនួន៨លើក៖ (១) ជាមួយតំណាង វិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជាស្តីពីសំណើសុំផ្តល់វគ្គបណ្តុះបណ្តាល ភាសាចិនសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី រាជការក្រសួង ជាលទ្ធផលវិទ្យាស្ថានបានឯកភាពតាមសំណើនាយកដ្ឋាន បានរៀបចំផ្សព្វផ្សាយសេចក្តីជូនដំណឹង និងទទួលបានការចុះឈ្មោះសរុបចំនួន៦៩រូប (ថ្នាក់បឋមចំនួន១២រូប និងថ្នាក់មូលដ្ឋានគ្រឹះចំនួន៥៧រូប) ឆ្នាំ២០២៤ (២) អង្គការមូលនិធិអាស៊ី ប្រចាំកម្ពុជានៅទីស្តីការក្រសួងចំនួន២លើក

ដើម្បីស្នើសុំឧបត្ថម្ភការបើកវគ្គ បណ្តុះបណ្តាលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដោយផ្តល់ជំនួយជាទឹកប្រាក់សរុបចំនួន១៥,០០០ដុល្លារ (ដប់ប្រាំពាន់ដុល្លារសហរដ្ឋអាមេរិក) សម្រាប់ឆ្នាំ២០២៤ (៣) អង្គការ UNDP ចំនួន២លើកនៅទីស្តីការក្រសួង ដើម្បីស្នើសុំឧបត្ថម្ភការរៀបចំវគ្គបណ្តុះបណ្តាលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង (៤) កិច្ចប្រជុំអំពីប្រធានបទ សម្រាប់បណ្តុះបណ្តាលមន្ត្រីរាជការ (៥) ជាមួយអង្គការ Oxfam (៦) កិច្ចប្រជុំស្តីពីការងារត្រៀមជួបជាមួយអង្គការ UNDP (៧) កិច្ចប្រជុំចំនួន២លើកស្តីពីវឌ្ឍនភាពការងារទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងពិភាក្សាបែងចែកភារកិច្ចសម្រាប់ពិធីចុះហត្ថលេខាកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានជាតិអធិការកិច្ច និងអង្គការ The Asia Foundation

- បានសហការសម្របសម្រួលជាមួយវិទ្យាស្ថានខុងជឺ និងវិទ្យាស្ថានជាតិអធិការកិច្ចរៀបចំការធ្វើតេស្តភាសាចិនកម្រិត HSK3 សម្រាប់មន្ត្រីរាជការក្រសួងអធិការកិច្ច ទីស្តីការក្រសួង

- បានបញ្ជូនលិខិតទៅអង្គការអន្តរជាតិ និងស្ថានទូតនានាសរុបចំនួន១២ច្បាប់

- បានរៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងអធិការកិច្ច ដើម្បីចូលរួមបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ៤វគ្គ៖ (១) វគ្គបណ្តុះបណ្តាល JENESYS កម្ពុជា-ជប៉ុនឆ្នាំ២០២៤ (២) អាហារូបករណ៍ Chevening ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សា នៅចក្រភពអង់គ្លេស សម្រាប់ឆ្នាំ២០២៥-២០២៦ (៣) អាហារូបករណ៍ JDS ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅព្រះរាជាណាចក្រជប៉ុន សម្រាប់ឆ្នាំ២០២៥ និង (៤) វគ្គបណ្តុះបណ្តាលរយៈពេលខ្លី នៅប្រទេសនូវែលសេឡង់ សម្រាប់ឆ្នាំ២០២៤

- បានរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីរាយនាមអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍សំខាន់ៗដែលមាន និងពុំទាន់បានកិច្ចសហប្រតិបត្តិការជាមួយក្រសួងអធិការកិច្ច

- បានបន្តសហការជាមួយវិទ្យាស្ថានជាតិអធិការកិច្ច សម្របសម្រួលការបណ្តុះបណ្តាលភាសាចិនកម្រិតមូលដ្ឋានសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងអធិការកិច្ច នៅទីស្តីការក្រសួងអធិការកិច្ច។

## ២.៨. ការងារបរិវត្តកម្មឌីជីថល

ចំពោះការងារបរិវត្តកម្មឌីជីថល ក្រុមការងារឌីជីថលក្រសួងអធិការកិច្ចបានសម្រេចនូវការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- បានបង្កើតគេហទំព័ររបស់ក្រសួងអធិការកិច្ច (inspection.gov.kh) ដោយធ្វើការបញ្ចូលព័ត៌មាន សកម្មភាពការងារបណ្ណុំឯកសារសាធារណៈនានា និងទទួលពាក្យបណ្តឹងអនឡាញរបស់ក្រសួងអធិការកិច្ច

- បានបង្កើតថ្នាល (Mobile App) ក្រសួងអធិការកិច្ចសម្រាប់ប្រើលើទូរស័ព្ទ និងឧបករណ៍ឆ្លាតវៃនានាដែលប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ iOS និង Android

- បានរៀបចំ និងកែសម្រួលសោភ័ណភាពបណ្តាញខ្សែអ៊ីនធឺណែត និងខ្សែកាបផ្សេងៗ នៅក្នុងបរិវេណទីស្តីការក្រសួង

- បានដំឡើងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព នៅទីស្តីការក្រសួងចំនួន៥៨កាមេរ៉ា

- បានដំឡើង LED នៅក្នុងសាលប្រជុំ សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ដែលមានបណ្តោយ៧,២២ម៉ែត្រ និងទទឹង២,៨៨ម៉ែត្រ សរុបទំហំ២១.០៨ម៉ែត្រការ៉េ

- បានដំឡើងទូរទស្សន៍ LCD ចំនួន២គ្រឿង នៅអគារAទីស្តីការក្រសួង (មួយគ្រឿងសម្រាប់បង្ហាញកម្មវិធីប្រជុំនានា និងមួយគ្រឿងទៀត សម្រាប់បង្ហាញពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំក្រសួង)

- បានដំឡើងប្រព័ន្ធបណ្ដាញទូរស័ព្ទ លេខកូដខ្លី (Hotline) ១២៦៨ ចំនួន១ខ្សែ ដែលប្រើសម្រាប់ទទួលការហៅចូលពីសាធារណជន ក្នុងការសាកសួរព័ត៌មានទូទៅ និងសម្រាប់ដាក់និងទទួលពាក្យបណ្ដឹង

- បានរៀបចំដំឡើងម៉ាស៊ីនមេចម្បង (Virtualization Server) សម្រាប់រក្សាទុកទិន្នន័យបម្រើ និងចែករំលែកទិន្នន័យទៅកាន់អង្គភាព ក្រោមឱវាទក្រសួង

- បានរៀបចំដំឡើងប្រព័ន្ធ Zoom Meeting សម្រាប់កិច្ចប្រជុំតាមអនឡាញនៅក្នុងសាលប្រជុំសម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន

- ក្រុមការងារបរិវត្តកម្មឌីជីថលបានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំ QR Code ស្តង់ដា នៃថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh នៅលើវិញ្ញាបនបត្របញ្ជាក់ការសិក្សា នៃវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈអធិការកិច្ច របស់វិទ្យាស្ថានជាតិអធិការកិច្ចចំនួន៤លើក សរុបស្មើនឹង២០៨ វិញ្ញាបនបត្រ

- ក្រុមការងារបរិវត្តកម្មឌីជីថលក្រសួងអធិការកិច្ច បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងតភ្ជាប់អ៊ីនធឺណែតថ្មី ព្រមទាំងបែងចែកល្បឿនអ៊ីនធឺណែតតាមការកំណត់ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ សម្រាប់ប្រើប្រាស់នៅទីស្តីការក្រសួងរួចរាល់

- ក្រុមការងារបរិវត្តកម្មឌីជីថល បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំបន្ទប់មជ្ឈមណ្ឌល គ្រប់គ្រងទិន្នន័យរួម (Data Center) សម្រាប់ប្រើប្រាស់ជាមជ្ឈមណ្ឌលគ្រប់គ្រង និងបែងចែកប្រព័ន្ធព័ត៌មានវិទ្យា សេវាអ៊ីនធឺណែត និងទិន្នន័យរួម (database) នៅទីស្តីការក្រសួងអធិការកិច្ច

- ក្រុមការងារបរិវត្តកម្មឌីជីថលបានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំ និងបំពាក់សម្ភារៈបរិក្ខារអ៊ីនធឺណែតថ្មីបន្ថែមរួមមាន៖ ដំឡើងទូ Main Server នៅបន្ទប់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរួម សម្រាប់ផ្ទុកសម្ភារៈបរិក្ខារមេ (Router, Switch និងខ្សែបណ្ដាញមេ) និងដំឡើងទូរ Sub Server ចំនួន២ទីតាំងទៀត នៅអគារB និងអគារC ដើម្បីបំពេញតាមតម្រូវការប្រើប្រាស់នៅទីស្តីការក្រសួងអធិការកិច្ច

- ក្រុមការងារបរិវត្តកម្មឌីជីថល បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បំពាក់ឧបករណ៍ចែកសេវាអ៊ីធឺណែត Access Point (WiFi Router) ចំនួន៧៤គ្រឿង និងប្រអប់ភ្ជាប់អ៊ីធឺណិត (Outlet) ចំនួន ១១៩ប្រអប់ តាមអគារ និងបន្ទប់នីមួយៗ

- ក្រសួងអធិការកិច្ចបានស្នើសុំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំវគ្គបណ្ដុះបណ្ដាលជំនាញឌីជីថលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំនួន៥វគ្គ នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា សរុបចំនួន១៨២រូប

- ក្រុមការងារបរិវត្តកម្មឌីជីថលក្រសួងអធិការកិច្ច បានទទួល Server ចំនួន១គ្រឿង និងកុំព្យូទ័រចំនួន ១៨៧គ្រឿង (កុំព្យូទ័រយួរដៃ១០០គ្រឿង និងកុំព្យូទ័រលើតុ៨៧គ្រឿង) ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- ក្រុមការងារបរិវត្តកម្មឌីជីថល នៃក្រសួងអធិការកិច្ច បានសហការជាមួយក្រុមការងារបច្ចេកទេសក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំដំឡើងគណនីសម្រាប់អ្នកប្រើប្រាស់លើកុំព្យូទ័រយួរដៃ និងកុំព្យូទ័រលើតុទាំង១៨៧គ្រឿង ដើម្បីផ្ដល់ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការតាមបណ្ដាអង្គភាពចំណុះក្រសួងប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

## ២.៩. ការងារផ្សេងៗ

### ២.៩.១. ការងារថ្នាក់ដឹកនាំ

ឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងអធិការកិច្ចបានចូលរួមកិច្ចប្រជុំ និងកម្មវិធីសំខាន់ៗ ក្រោមព្រះរាជាធិបតីភាព របស់**ព្រះករុណា ព្រះមហាក្សត្រ** ប្រមុខរដ្ឋស្តីទី និងក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រី សំខាន់ៗ មានដូចខាងក្រោម៖

- ចូលរួមជាមួយថ្នាក់ដឹកនាំកំពូល ចំនួន៥លើក
- ឯកឧត្តមរដ្ឋមន្ត្រីបានចូលរួម និងអមដំណើរជាមួយប្រមុខរាជរដ្ឋាភិបាល (នាយករដ្ឋមន្ត្រី) ក្នុងជំនួប និងកម្មវិធីសំខាន់ៗ ចំនួន ៧៤ លើក
- ចូលរួមក្នុងជំនួបជាមួយថ្នាក់ដឹកនាំផ្សេងទៀត ដឹកនាំកិច្ចប្រជុំ និងចូលរួមកម្មវិធីផ្សេងៗ ចំនួន ១២៥ លើក។

### ២.៩.២. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និង FMIS

ក្រសួងអធិការកិច្ចបានចូលរួមក្នុងកម្មវិធីការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS អស់រយៈពេល ជាង ២០ ឆ្នាំ ពីដំណាក់កាលទី ១ ដល់ដំណាក់ កាលទី៤។ ពេលនេះ ក្រសួងបានចូលរួមក្នុងដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"។ ក្រសួងគ្រោងដាក់បញ្ចូល អង្គភាពថវិកាទាំងអស់ឱ្យក្លាយទៅជា អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ។

ក្រសួងអធិការកិច្ចបានបង្កើតក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលបានអនុវត្ត និងបំពេញ រួមមានដូចខាងក្រោម (ករណីនេះ គួរសរសេរថា មានដូចខាងក្រោម៖

- បានបញ្ចូលតួលេខ នៃការគ្រោងថវិកាប្រចាំត្រីមាសនីមួយៗក្នុងប្រព័ន្ធគ្រប់គ្រងការធ្វើផែនការសាច់ប្រាក់ទាន់ពេលវេលា
- បានរៀបចំ (១) របាយការណ៍ប្រចាំត្រីមាសនីមួយៗ នៃការអនុវត្តផែនការចំណាយ ដោយអនុវត្តឱ្យបានតាមភាគរយ ធៀបនឹងច្បាប់ហិរញ្ញវត្ថុ និងបានផ្ញើជូនអគ្គ.ថវិកានីយកម្មបានទាន់ពេលវេលា (២) សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីហិរញ្ញវត្ថុសាធារណៈ (FMM) (៣) ផែនការលទ្ធកម្មប្រចាំឆ្នាំ ដើម្បីដាក់ជូនកសហវបានទាន់ពេលវេលា (៤) ផែនការរជ្ជទេយ្យបុរេប្រទាន សម្រាប់អនុវត្តឆ្នាំបន្ទាប់២០២៥ (៥) ផែនការសាច់ប្រាក់តាមប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ (Cash Management System)
- បានអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ FMIS ពេញលេញ (១) នីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា (២) មុខងារលទ្ធកម្មពេញលេញក្នុងប្រព័ន្ធ FMIS (៣) មុខងារផែនការថវិកា
- ចាត់ចែងបើកផ្តល់ប្រាក់បេសកកម្មក្នុង និងក្រៅប្រទេស តាមប្រព័ន្ធធនាគារ
- អនុវត្តការទូទាត់ថវិការជ្ជទេយ្យបុរេប្រទានប្រចាំត្រីមាសនីមួយៗ (ជុំទី១.២.៣.៤) ទាន់ពេលវេលា
- ធ្វើរបាយការណ៍អនុវត្តថវិកាប្រចាំត្រីមាសនីមួយៗ ដោយស្រង់ចេញពីប្រព័ន្ធFMIS និងធ្វើដោយដៃតាម MS Excel
- បានបិទបញ្ជប់សំណើថវិកា និងបិទប្រតិបត្តិការថវិកាយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤
- បានបញ្ចូលព័ត៌មានទ្រព្យសម្បត្តិរដ្ឋក្នុងប្រព័ន្ធ SARMIS

- អាផ្ងាធរកោន់កាប់ទ្រព្យសម្បត្តិរដ្ឋបានប្រើប្រាស់ និងទាញរបាយការណ៍បូកសរុបរួម សម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (កើនឡើង/ថយចុះ)ប្រចាំឆ្នាំ និងសៀវភៅគោល (៥ឆ្នាំ) ដែលអាចត្រូវបានទាញចេញពីប្រព័ន្ធ SARMIS (Online)

- កាត់បន្ថយគម្លាត នៃផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ ដែលអនុម័តត្រូវបានកាត់បន្ថយ

- បានសាកល្បងអនុវត្តញែកបន្ទុកបុគ្គលិក

- យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃថវិកាសមិទ្ធកម្មត្រូវបានរៀបចំ បញ្ចូលក្នុងប្រព័ន្ធ FMM

- បានរៀបចំរបាយការណ៍សវនកម្មសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មានប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំ

- ការអនុវត្តផែនការសកម្មភាព (MAP) និងសូចនាករសមិទ្ធកម្មគន្លឹះ (KPI) យ៉ាងតិច៩០% សម្រេចបានតាមផែនការ

- សេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំ និងផ្ញើជូន **អគហ** ទាន់ពេលវេលា

- ផែនការសកម្មភាព (MAP) និងសូចនាករសមិទ្ធកម្មគន្លឹះ(KPI) សម្រាប់ឆ្នាំ២០២៥ ត្រូវបានរៀបចំ និងផ្ញើជូន **អគហ** បានទាន់ពេលវេលា។

### ២.៩.៣. ការកែទម្រង់រដ្ឋបាលសាធារណៈ

ក្រសួងអធិការកិច្ចបានចូលរួមក្នុងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ មានដូចខាងក្រោម៖

- បានធ្វើការវិភាគមុខងារ ជាពិសេសក្នុងការរៀបចំរចនាសម្ព័ន្ធថ្មីរបស់ក្រសួងអធិការកិច្ច

- បានចូលរួមប្រជុំ និងសិក្ខាសាលាចំនួន ៥លើក ដឹកនាំដោយក្រសួងមុខងារសាធារណៈដែលរួមមានកិច្ចប្រជុំពិភាក្សាលើវឌ្ឍនភាពនៃការពិនិត្យឡើងវិញការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន និងការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួងស្ថាប័ន

- បានចូលរួមប្រជុំជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបានចំនួន ២លើក លើសេចក្តីព្រាងចំនួន២រួមមាន៖ (១) សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការជ្រើសរើស និងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ (២) សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែង។

### ២.៩.៤. ការងារយេនឌ័រ

ក្រសួងអធិការកិច្ចមានមន្ត្រីរាជការជាស្ត្រី នៅថ្នាក់កណ្តាល និងរាជធានី ខេត្តសរុបចំនួន២៤៥រូប មន្ត្រីជាប់កិច្ចសន្យា ចំនួន ៨៥រូប។ ក្រុមការងារយេនឌ័រ បានធ្វើសកម្មភាពសំខាន់ៗ មានដូចខាងក្រោម៖

- បានរៀបចំកម្មវិធីប្រជុំ ចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងការងារយេនឌ័រនៅតាមបណ្តាក្រសួងស្ថាប័នចូលរួមយុទ្ធនាការ១ ម៉ឺនរៀល១ម៉ឺននាក់ និងចូលរួមវគ្គបណ្តុះបណ្តាល និងបានរៀបចំកម្មវិធីវេទិកាសាធារណៈស្តីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រីក្នុងក្រសួងសរុបបានចំនួន ១២លើក

- បានចូលរួមសួរសុខទុក្ខ ជួយសម្របសម្រួលការព្យាបាលជំងឺ នៅមន្ទីរពេទ្យ និងនាំយកអំណោយ របស់ថ្នាក់ដឹកនាំជូនដល់មន្ត្រីរាជការជាស្ត្រីមានជំងឺ មន្ត្រីជួបគ្រោះថ្នាក់ចរាចរណ៍ សម្រាលបុត្រ និងទទួលមរណភាព

ចំនួន ១០រូប ដែលរួមមានអំណោយឧបត្ថម្ភរបស់៖ (១) **ឯកឧត្តម ហួត ហាក់** អតីតរដ្ឋមន្ត្រីក្រសួងអធិការកិច្ច បានឧបត្ថម្ភជាថវិកាចំនួន ៣,៥០០,០០០៛ (២) **ឯកឧត្តម សុខ សូកេន** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច បានឧបត្ថម្ភក្រុមការងារយេនឌ័រ រួមមាន៖ ជាថវិកាសរុបចំនួន ៤,០០០,០០០៛ ជាសម្ភារៈប្រើប្រាស់ សម្ភារៈអនាម័យ ជូនមន្ត្រីជាប់កិច្ចសន្យា ផ្តល់រង្វាន់ជាម៉ូតូជូនដល់កូនរបស់មន្ត្រីរាជការដែលជាសិស្សជាប់និទ្ទេសA ផ្តល់ម៉ូតូ ១គ្រឿងដល់ប្រធានសន្តិសុខ និង (៣) អំណោយរបស់ក្រុមការងារយេនឌ័រក្រសួងចំនួន ២.០០០.០០០៛

- បានរៀបចំកម្មវិធីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ក្រោមប្រធានបទ «**ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល**»

- ចូលរួមកិច្ចប្រជុំប្រមូលធាតុចូលលើរបាយការណ៍ ស្តីពីការអនុវត្តនូវសេចក្តីថ្លែងការណ៍ ទីក្រុងប៉េកាំង សម្រាប់៣០ឆ្នាំ

- ចូលរួមពិភាក្សាប្រមូលធាតុចូល និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រនារីរតនៈឆ្នាំ២០២៤-២០២៨ និងអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនារីភេទ (ស៊ី-ដ)

- បានសម្របសម្រួលសាច់ញាតិរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទៅសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យព្រះកេតុមាលា តាមខ្លឹមសារ MOU ចំនួន៦រូប។

## ២.៩.៥. ការងារក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួងអធិការកិច្ច

- បុគ្គលដែលត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលសម្រាប់ឆ្នាំ២០២៤ មានចំនួន៩២នាក់ ក្នុងនោះ ២នាក់បានទទួលមរណភាព ដូច្នេះបុគ្គលត្រូវជាប់កាតព្វកិច្ចដាក់ស្តែងចំនួន៩០នាក់ បានដាក់លិខិតប្រកាសរួច

- បុគ្គលដែលត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលសម្រាប់ឆ្នាំ២០២៥ មានចំនួន ៨៦នាក់ បានដាក់លិខិតប្រកាសរួច

- បានធ្វើការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ តាមបណ្តាអង្គភាពមួយចំនួនក្រោមឱវាទក្រសួងអធិការកិច្ច និងបានផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពការងារក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួងអធិការកិច្ចតាមរយៈបណ្តាញព័ត៌មាននានា ជាពិសេស ក្នុងគ្រុបតេឡេក្រាម ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួងអធិការកិច្ច

- បានទំនាក់ទំនង និងសម្របសម្រួលការងារប្រកាសទ្រព្យសម្បត្តិ និងបំណុលជូនថ្នាក់ដឹកនាំក្រសួង និងបុគ្គល ជាប់កាតព្វកិច្ច បានដាក់ប្រកាសទាន់ពេលវេលា

- បានចូលរួម និងរៀបចំបដាអបអរសាទរទិវាជាតិ-អន្តរជាតិប្រយុទ្ធអំពើពុករលួយ ៩ធ្នូ ជារៀងរាល់ឆ្នាំ

- បានធ្វើរបាយការណ៍អំពីលទ្ធផល នៃការអនុវត្តសកម្មភាពការងារប្រឆាំងអំពើពុករលួយជូន ឯកឧត្តម រដ្ឋមន្ត្រី ពិនិត្យ និងសម្រេច ដើម្បីធ្វើជូនអង្គភាពប្រឆាំងអំពើពុករលួយ។

## ២.៩.៦. ការងារអនុគណៈកម្មការគ្រឿងឥស្សរិយយសក្រសួងអធិការកិច្ច

អនុគណៈកម្មការនេះបានស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ចំនួន១២៦គ្រឿង និងបណ្ណសរសើរ ចំនួន២១២បណ្ណ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួង។

## ២.៩.៧. ការងារអន្តរវិស័យ

*ក. ការងារពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ៖*

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងបានរៀបចំ និងចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ និងទិវាផ្សេងៗរបស់ជាតិចំនួន១៥លើករួមមានៈ (១) ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ថ្ងៃ៧ មករា (២) ទិវាអន្តរជាតិនារី៨មីនា (៣) ពិធីបុណ្យ ចូលឆ្នាំថ្មីប្រពៃណីជាតិ (៤) ពិធីបុណ្យពិសាខបូជា ថ្ងៃ១១ឧសភា (៥) ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៤ឧសភា (៦) ព្រះរាជពិធីច្រត់ព្រះនង្គ័លថ្ងៃទី១៥ឧសភា (៧) ទិវាប្រកាសរដ្ឋធម្មនុញ្ញថ្ងៃទី២៤កញ្ញា (៨) ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យជាតិ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ «ព្រះបរមរតនកោដ្ឋ» ថ្ងៃទី១៥តុលា (៩) ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៩តុលា (១០) ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ថ្ងៃទី៤-៥-៦ ខែវិច្ឆិកា (១១) ព្រះរាជពិធីបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា (១២) ទិវាសន្តិភាព នៅកម្ពុជា ថ្ងៃទី២៩ធ្នូ (១៣) ពិធីបុណ្យអង្គកឋិនទាន មហាសាមគ្គីគ្រួសារខ្មែរ ដង្ហែរទៅកាន់វត្តពោធិ៍គិរីវង្សារាម ហៅវត្តស្វាយសៀមថ្មី ទឹកដីកម្ពុជាក្រោម (១៤) ពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ថ្ងៃទី៥ ខែសីហា (១៥) ពិធីបុណ្យទន្លេលើកទី៨ឆ្នាំ២០២៤ ក្រោមប្រធានបទ «ទន្លេដើម្បីសន្តិភាពនិងការអភិវឌ្ឍ» នៅខេត្តសៀមរាប។

*ខ. ការងារពាក់ព័ន្ធនឹងក្រសួងបរិស្ថានៈ*

បានចូលរួមកម្មវិធីជាមួយក្រសួងបរិស្ថាន ចំនួន ៧លើកៈ (១) កិច្ចប្រជុំលើកទី១ ក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព នីតិកាលទី៧ នៃរដ្ឋសភាស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍ ដោយចីរភាព (NCSD) (២)សិក្ខាសាលា ស្តីពីភាពធន់នឹងអាកាសធាតុ និងអន្តរកាលថាមពលបច្ច័យសម្រាប់កម្ពុជា នៅក្រសួងបរិស្ថាន (៣) ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការឯកសារសន្ទស្សន៍ ហានិភ័យអាកាសធាតុលើកុមារសម្រាប់កម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី (៤) កិច្ចប្រជុំលើកទី២ ក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព (NCSD) ស្តីពីការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (៥) ពិធីប្រកាសដាក់ឱ្យអនុវត្តក្រមបរិស្ថាន និងធនធានធម្មជាតិ (៦) វេទិកាពិភពលោកស្តីពីសកម្មភាពអាកាសធាតុ២០២៤ (៧) ពិធីបើក-បិទសន្និបាតបូកសរុបការងារបរិស្ថាន ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥។

*គ. ការងារពាក់ព័ន្ធនឹងក្រសួងអប់រំ យុវជន និងកីឡាៈ*

ក្រសួងបានចូលរួមចំនួន៣លើករួមមានៈ (១) ចូលរួមជាកិត្តយសក្នុងពិធីទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៧ ឆ្នាំ២០២៤ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (២) ចូលរួមទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០២៤ ក្រោមប្រធានបទ «TVET រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ» ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** (៣) ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតនៃសកលវិទ្យាល័យលីមកុកវីង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

*ឃ. ការងារពាក់ព័ន្ធនឹងវិស័យឯកជនៈ*

បានចូលរួមព្រឹត្តិការណ៍ចំនួន៣លើករួមមាន៖ (១) ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់៖ ការកំណត់មាគ៌ាសម្រាប់វិបុលភាព ប្រកបដោយភាពធន់ និរន្តរភាព និងបរិយាបន្ន ដំណាក់កាលទី១ រៀបចំដោយសភាពាណិជ្ជកម្មកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** (២) ចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់៖ ការកំណត់មាគ៌ាសម្រាប់វិបុលភាព ប្រកបដោយភាពធន និរន្តរភាព និងបរិយាបន្នតំណាក់កាលទី២ រៀបចំដោយសភាពាណិជ្ជកម្មកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** (៣) ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-កម្ពុជាឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

*ង. ការងារតាមដានព័ត៌មាននៅលើគ្រប់បណ្ដាញព័ត៌មាន*

ក្នុងឆ្នាំ២០២៤ ក្រុមការងារតាមដានព័ត៌មាននៅលើគ្រប់បណ្ដាញព័ត៌មាន បានស្រង់ព័ត៌មានចំនួន ៨៥ចំណងជើង។

### ២.៩.៨. ការងារផ្សេងៗ

ក្រៅពីការងារខាងលើ ក្រសួងអធិការកិច្ចបានបង្កើតក្រុងការងារ និងសកម្មភាពការងារមានដូចខាងក្រោម៖

- មូលនិធិគាំទ្រមន្ទីរពេទ្យគន្ធបុប្ផា

- រៀបចំក្រុមកីឡាបាល់ទាត់ក្រសួងមួយក្រុមដែលបានចូលរួមប្រកួតជាមិត្តភាព ដណ្ដើមពានរង្វាន់អន្តរ-ក្រសួងរៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ២០១៨ មក

- រៀបចំប្រទីបក្រសួង ដើម្បីចូលរួមក្នុងពិធីបុណ្យ អុំទូក សំពះ ព្រះខែ អកអំបុក

- បង្កើតសមាគមសង្គហមិត្តភាព ដែលមានសមាជិក សមាជិកាចំនួន ៣៣៨នាក់ (ថ្នាក់កណ្ដាលចំនួន ២០៦នាក់ និងថ្នាក់ មន្ទីររាជធានី ខេត្តចំនួន ១៣២នាក់)

- ការងារសម្ព័ន្ធមេត្រីភាព៖ ក្រសួងអធិការកិច្ច រួមជាមួយក្រុមហ៊ុន ម៉ុងឬទ្ធីគ្រុប និងក្រុមហ៊ុនគូហ៊្វុឡុង បានធ្វើសម្ព័ន្ធមេត្រីភាពជាមួយ អង្គភាពនគរបាលជាតិ វរសេនាតូចលេខ ៨២៧ និងវរសេនាតូចលេខ ២៦៩ ដែលកំពុងឈរជើងនៅភូមិសាស្ត្រព្រំដែនកម្ពុជា-ថៃ ខេត្តកោះកុង។

## ជំពូក ៣. បញ្ហាប្រឈម

ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានជាច្រើនដូចបានលើកឡើងខាងលើ ក្រសួងមានបញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួន រួមមាន៖

- ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តពេញលេញ ដើម្បីគាំទ្រដល់ការងារស្នូលរបស់ក្រសួងអធិការកិច្ចសម្រាប់ដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ចឱ្យមានប្រសិទ្ធភាពនៅឡើយ ជាពិសេសច្បាប់ស្ដីពីអធិការកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធគាំទ្រដល់យន្តការដោះស្រាយបណ្ដឹង។

- យន្តការតាមដាននិងវាយតម្លៃគុណវុឌ្ឍិមន្ត្រីរាជការ រួមទាំងវិន័យនិងក្រមសីលធម៌វិជ្ជាជីវៈនៅមានកម្រិត

- ប្រព័ន្ធតាមដាននិងវាយតម្លៃលទ្ធផលការងារនៅមានកម្រិត

- ពុំមានយន្តការត្រួតពិនិត្យលើការអនុវត្តរបាយការណ៍លទ្ធផលនៃការងារអធិការកិច្ច និងការងារតាមដានការអនុវត្តច្បាប់របស់ក្រសួង ស្ថាប័ន

- ពុំមានយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារអធិការកិច្ចរបស់ក្រសួង ស្ថាប័ន
- ប្រព័ន្ធលើកទឹកចិត្តមន្ត្រីនៅមានកម្រិត
- កញ្ចប់ថវិកា និងមធ្យោបាយបំពេញការងារនៅមានកម្រិត ពុំទាន់ឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែង
- កិច្ចសហប្រតិបត្តិការ និងការគាំទ្រពីដៃគូជាតិនិងអន្តរជាតិនៅមានកម្រិត
- បេសកកម្មលើការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ ការងារដោះស្រាយបណ្តឹង ជាទូទៅមានរយៈពេលលើសពី ៩យប់ ១០ថ្ងៃ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការការងារជាក់ស្តែង
- កិច្ចសហការរបស់ក្រសួង ស្ថាប័ន អង្គភាព ដែលជាមុខសញ្ញាដែលត្រូវរងអធិការកិច្ច និងការតាមដានការអនុវត្តច្បាប់ នៅមានភាពខ្វះខាត ដោយមានបុគ្គល និងមានស្ថាប័នមួយចំនួន មិនទាន់យល់ដឹងច្បាស់ពីតម្លៃនិងមុខងារអធិការកិច្ច ជាពិសេសរបាយការណ៍លទ្ធផល នៃការធ្វើអធិការកិច្ច និងតាមដានការអនុវត្តច្បាប់ ត្រូវបានពន្យារពេលក្នុងការពិនិត្យនិងឯកភាពពីប្រធានស្ថាប័ន និងអង្គភាពមួយចំនួន ដែលធ្វើឱ្យដំណើរការក្នុងការធ្វើអធិការកិច្ច និងតាមដានការអនុវត្តច្បាប់ ត្រូវបានពន្យារពេល និងពុំឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ក្រសួង ស្ថាប័ន និងអង្គភាពទាំងនោះ។
- អង្គភាពអធិការកិច្ចរបស់ក្រសួង ស្ថាប័នមួយចំនួន ពុំបានសហការ និងពុំបានផ្តល់របាយការណ៍ លទ្ធផលអធិការកិច្ចប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំមកក្រសួងអធិការកិច្ច ដើម្បីបូកសរុបរបាយការណ៍ ជូនប្រមុខរាជរដ្ឋាភិបាល ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាននៅឡើយ។
- ពុំទាន់មានផែនការអធិការកិច្ចរួមមួយ សម្រាប់អនុវត្តលើវិស័យអធិការកិច្ចនៅឡើយ ដែលជាហេតុធ្វើឱ្យការចុះធ្វើអធិការកិច្ចមានភាពស្ទួនគ្នា និងមានចន្លោះខ្វះខាត។
- ដើម្បីអនុវត្តមុខងារ តួនាទីនិងភារកិច្ចរបស់ក្រសួងឱ្យបានពេញលេញ ប្រកបដោយប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃវិស័យអធិការកិច្ច កត្តាធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនៅមានកំរិតនៅឡើយ ជាពិសេសធនធានមនុស្សជំនាញច្បាប់ និងកញ្ចប់ថវិកាសម្រាប់ការបណ្តុះបណ្តាល មន្ត្រីអធិការកិច្ចទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រួមទាំងបណ្តាញអធិការកិច្ច។
- ក្រសួង ស្ថាប័នមួយចំនួនបានកសាងលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ ដោយបានកំណត់សមត្ថកិច្ច និងសិទ្ធិអំណាចធ្វើអធិការកិច្ចរបស់ខ្លួនទៅជ្រកក្រោមច្បាប់ជំនាញផ្សេងៗ ធ្វើឱ្យប៉ះពាល់សមត្ថកិច្ចក្រសួងអធិការកិច្ច ក្នុងការដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ច ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច និងមិនមានសុខដុមនីយកម្មក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

## ជំពូក ៤. ទិសដៅ

ដើម្បីសម្រេចបានជោគជ័យ និងទទួលបានសមិទ្ធផលដូចដែលបានគ្រោងទុកក្នុងផែនការ នៅឆ្នាំ២០២៥ ក្រសួងអធិការកិច្ចមានទិសដៅការងារសំខាន់ៗ ដូចខាងក្រោម៖

### ៤.១. ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ

ដើម្បីសម្រេចបាននូវចក្ខុវិស័យដ៏មុតស្រួច និងវែងឆ្ងាយរបស់ក្រសួងអធិការកិច្ចក្នុងការដឹកនាំ និងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីដោះស្រាយបញ្ហាប្រឈមទាំងអស់ខាងលើ ក៏ដូចជា

ចូលរួមពង្រឹងការអនុវត្តស្មារតីនៃមុំទី៣ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១នៃរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយ ទស្សនវិស័យដ៏វែងឆ្ងាយរបស់ឯកឧត្តម **សុខ សូកេន** ក្រសួងអធិការកិច្ច បានដាក់ចេញនូវយុទ្ធសាស្ត្រ «៣៤ជ៤» ដែលអាចជានាបាននូវកំណែទម្រង់អធិការកិច្ច និងអភិបាលកិច្ចមានលក្ខណៈគ្រប់ជ្រុងជ្រោយ ចំគោលដៅ និងផ្តោតលើលទ្ធផល សំដៅជំរុញការអភិវឌ្ឍវិស័យអធិការកិច្ចនៅកម្ពុជា។

យុទ្ធសាស្ត្រ «៣៤ជ៤» ផ្តោតលើការពង្រឹងការងារស្នូលចំនួន ៤ «៣៤» គឺ (១)**ពង្រឹងការងារអធិការកិច្ច, (២)ពង្រឹងការងារដោះស្រាយបណ្តឹង, (៣)ពង្រឹងការងារតាមដានការអនុវត្តច្បាប់** និង(៤)**ពង្រឹងការងារផ្សព្វផ្សាយ ច្បាប់ និងវេទិកាសាធារណៈ** និងជំរុញការងារគាំទ្រចំនួន ៤ «ជ៤» គឺ (១)**ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត, (២)ជំរុញនិងបង្កើនសមត្ថភាពស្ថាប័ន, (៣)ជំរុញកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ** និង (៤) **ជំរុញការប្រើប្រាស់ បច្ចេកវិទ្យាឌីជីថល**។

យុទ្ធសាស្ត្រ «**៣៤ជ៤**» មានចក្ខុវិស័យវែងឆ្ងាយ ក្នុងការចូលរួមជំរុញឱ្យសង្គមកម្ពុជាមានភាពធន់ និងភាពប្រកួតប្រជែង ព្រមទាំងធ្វើឱ្យស្ថាប័នសាធារណៈមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន និងចូលរួមធានាបាននូវយុត្តិធម៌ តម្លាភាព និងអភិបាលកិច្ចល្អ តាមរយៈបេសកកម្មច្បាស់លាស់ និងមុតស្រួច ដើម្បីពង្រឹង និងលើកកម្ពស់ទំនុកចិត្តលើស្ថាប័នសាធារណៈ ដោយផ្តោតសំខាន់លើ៖ (១) បញ្ចៀសនូវសកម្មភាពមិនអនុលោមតាមច្បាប់ ដើម្បីកាត់បន្ថយការរំលោភបំពានលើអភិបាលកិច្ច ដោយបង្កើតវប្បធម៌នៃការអនុវត្តច្បាប់ និងអភិបាលកិច្ចល្អ (២) រកឱ្យឃើញចំណុចខ្វះខាត ព្រមទាំងភាពមិនប្រក្រតី និងអសកម្ម (៣)ទុកពេលឱ្យស្ថាប័នសាធារណៈដើម្បីកែលម្អនូវចំណុចខ្វះខាត ភាពមិនប្រក្រតី និងភាពអសកម្ម ក្នុងការអនុវត្តច្បាប់ និងអភិបាលល្អ ដើម្បីឈានដល់ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពេញលេញ និង (៤) ឆ្លើយតបជាមួយដំណោះស្រាយប្រកបដោយយុត្តិធម៌ តម្លាភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។




*រូបថតអនុស្សាវរីយ៍ ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងអធិការកិច្ច*
*បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការរៀបចំយុទ្ធសាស្ត្រ «៣៤ជ៤»*

លើសពីនេះទៅទៀត យុទ្ធសាស្ត្រនេះមានគុណតម្លៃស្នូលសំខាន់ៗរួមមាន (១) **សុចរិតភាព៖** លើកកម្ពស់ភាពស្មោះត្រង់ យុត្តិធម៌ និងតម្លាភាព ក្នុងអភិបាលកិច្ច (២) **វិជ្ជាជីវៈ៖** ធានាបាននូវវិជ្ជាជីវៈ និងប្រសិទ្ធភាព ក្នុងការធ្វើអធិការកិច្ច ការទទួលនិងដោះស្រាយបណ្តឹង ការតាមដានការអនុវត្តច្បាប់ និងការអប់រំផ្សព្វផ្សាយ ច្បាប់និងវេទិកាសាធារណៈ (៣) **ភាពច្បាស់លាស់៖** លើកកម្ពស់ការយល់ដឹងរបស់វិស័យឯកជន និងប្រជាពលរដ្ឋ

អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្ត (៤) **គណនេយ្យភាព៖** ធ្វើឱ្យស្ថាប័ន និងបុគ្គលមានការទទួលខុសត្រូវខ្ពស់ចំពោះការអនុវត្តច្បាប់ និងការពង្រឹងអភិបាលកិច្ច និង(៥) **ភាពជាដៃគូ៖** ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋ ឯកជន និងដៃគូអន្តរជាតិនានា។

ទិសដៅការងាររបស់ក្រសួងអធិការកិច្ច សម្រាប់អនុវត្តឆ្នាំ២០២៥ ត្រូវបានគិតគូរៀបចំគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអធិការកិច្ច និងធានាប្រសិទ្ធភាពក្នុងការអនុវត្តមុខងារស្នូលរបស់ក្រសួង និងស្របតាមយុទ្ធសាស្ត្រ «**ចតុកោណ**» ដើម្បីឱ្យមានភាពប្រទាក់ក្រឡាគ្នាជាមួយគោលដៅយុទ្ធសាស្ត្រ វិធានការគន្លឹះ និងផែនការសកម្មភាព ដែលមានរំលេចក្នុងយុទ្ធសាស្ត្រនេះ។

## ៤.២. ការពង្រឹងការងារអធិការកិច្ច

ក្រសួងបានដាក់ចេញទិសដៅការងារសំខាន់ៗ ដើម្បីពង្រឹងការងារអធិការកិច្ច ដែលផ្អែកលើគោលដៅយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន ៖ (១)ពង្រឹងប្រសិទ្ធិភាពនៃការចុះធ្វើអធិការកិច្ច (២)ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងកែលម្អ និងតាមដានការអនុវត្តសេចក្តីជូនដំណឹង, ពង្រឹងការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលអធិការកិច្ច (៣)ពង្រឹងទំនាក់ទំនងនិងសហការជាមួយអង្គភាព អធិការកិច្ចតាម ក្រសួងស្ថាប័ន (៤)កំណត់ឱ្យបានច្បាស់ពីសមត្ថកិច្ច មុខងារភារកិច្ច និងឋានានុក្រមអធិការកិច្ច (៥)ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍ លទ្ធផលការងារអធិការកិច្ចនិងយន្តការតាមដានត្រួតពិនិត្យ លើមុខងារអធិការកិច្ចរបស់ក្រសួងស្ថាប័ន និង(៦) ជំរុញរៀបចំផែនការអធិការកិច្ចរួមប្រចាំឆ្នាំនីមួយៗ ដោយសហការជាមួយអង្គភាព អធិការកិច្ចតាមក្រសួង ស្ថាប័ន ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ នីតិវិធីគំរូស្តង់ដា អធិការកិច្ចរួម និងផ្តល់ការណែនាំជំនាញបច្ចេកទេសដល់ អង្គភាពអធិការកិច្ចមក្រសួង ស្ថាប័ន
- ជំរុញបញ្ចប់នូវរបាយការណ៍លទ្ធផលនៃការចុះធ្វើអធិការកិច្ចនាពេលកន្លងមក និងចេញសេចក្តីជូនដំណឹងស្តីពីការកែលម្អចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន។
- បន្តទទួល និងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលអធិការកិច្ចថ្នាក់ក្រោមជាតិ និងធ្វើអធិការកិច្ចឡើងវិញក្នុងករណីយល់ឃើញថាមិនទាន់ត្រឹមត្រូវ ឬមានការតវ៉ា។
- បន្តចូលរួមប្រជុំការងារក្នុងក្រសួង និងអន្តរក្រសួងតាមការអញ្ជើញ និងចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។
- បន្តពង្រឹងការគ្រប់គ្រងវត្តមាន និងរបៀបរបបការងាររបស់មន្ត្រីរាជការក្នុងអគ្គនាយកដ្ឋានអធិការកិច្ច។
- បន្តជំរុញការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីរាជការក្នុងអគ្គនាយកដ្ឋានអធិការកិច្ច។
- ជំរុញការអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៥ ដោយផ្អែកតាមអភិក្រមទាំង៧ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងចង្អុលបង្ហាញពីថ្នាក់ដឹកនាំក្រសួង។

## ៤.៣. ការពង្រឹងការងារតាមដានការអនុវត្តច្បាប់

ក្រសួងបានដាក់ចេញទិសដៅការងារសំខាន់ៗ ដើម្បីពង្រឹងការងារតាមដានការអនុវត្តច្បាប់ ដែលផ្អែកលើគោលដៅយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន៖ (១)ពង្រឹងការងារតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (២)ពង្រឹងប្រសិទ្ធភាពនៃការចេញសេចក្តីជូនដំណឹងកែលម្អ និងតាមដានការអនុវត្តសេចក្តី

ជូនដំណឹងនិងពង្រឹងការអនុវត្តសេចក្តីសម្រេចស្តីពីលទ្ធផលនៃការងារតាមដានការអនុវត្តច្បាប់ និង(៣) ជំរុញបង្កើតយន្តការតាមដាន ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលការងារតាមដានការអនុវត្តច្បាប់ ដូចខាងក្រោម៖

- ជំរុញបញ្ចប់របាយការណ៍ស្តីពីលទ្ធផលការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជារបស់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ «បញ្ជាឱ្យអភិបាល រាជធានី ខេត្តទាំងអស់ ត្រួតពិនិត្យជាបន្ទាន់លើទីតាំងល្បែងផ្សងសំណាង ក្នុងករណីមានបន្តបើកថ្មីទៀត សូមចាត់វិធានការបិទជាបន្ទាន់ និងរាយការណ៍ផ្ទាល់ជូនសម្តេច» នៅខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង និងខេត្តព្រះសីហនុ

- ជំរុញការចេញសេចក្តីជូនដំណឹងស្តីពីការកែលម្អចំណុចខ្វះខាតការងារ ចុះតាមដានត្រួតពិនិត្យអនុវត្តអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តក្រចេះ ព្រះវិហារ ស្ទឹងត្រែង កំពង់ធំ និងខេត្តមណ្ឌលគិរី

- បន្តស្រាវជ្រាវ និងចងក្រងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី

- ជំរុញការប្រមូលព័ត៌មាន ទិន្នន័យ និងសភាពការណ៍ពីគ្រប់មជ្ឈដ្ឋាននិងគ្រប់មធ្យោបាយ លើចំណុចអសកម្មនានានិងការរំលោភច្បាប់ ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការងារតាមដានការអនុវត្តច្បាប់

- ពង្រឹងយន្តការវិភាគ វាយតម្លៃលើព័ត៌មាន ទិន្នន័យ និងសភាពការណ៍ដែលជាកម្មវត្ថុនៃការតាមដានការអនុវត្តច្បាប់

- ពង្រឹងកិច្ចសហការ ទំនាក់ទំនង និងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គភាពពាក់ព័ន្ធ និងដៃគូនានា ជាពិសេស អង្គភាពរងការតាមដានការអនុវត្តច្បាប់

- ស្វែងយល់ឱ្យបានស៊ីជម្រៅពីផលប៉ះពាល់ នៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងគោលបំណងគាំទ្រដល់ការងារតាមដានការអនុវត្តច្បាប់។

## ៤.៤. ការពង្រឹងការងារដោះស្រាយបណ្តឹង

ក្រសួងបានដាក់ចេញទិសដៅការងារសំខាន់ៗ ដើម្បីពង្រឹងការងារដោះស្រាយបណ្តឹង ដែលផ្អែកលើគោលដៅយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន (១)ពង្រឹងប្រសិទ្ធភាពនៃការទទួលបណ្តឹង និង(២)ពង្រឹងប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹង ដូចខាងក្រោម៖

- ពង្រឹងយន្តការទទួលពាក្យបណ្តឹងឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពខ្ពស់ ទាំងបណ្តឹងតវ៉ា និងបណ្តឹងបរិហារពីគ្រប់មជ្ឈដ្ឋាន ពីសារព័ត៌មាន បច្ចេកវិទ្យាព័ត៌មាន បណ្តឹងអនាមិក និងគ្រប់មធ្យោបាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងការទទួលពាក្យបណ្តឹងតាមរយៈប្រព័ន្ធបច្ចេកវិទ្យា (អនឡាញ) និងការទទួលដោយផ្ទាល់

- ផ្សព្វផ្សាយអំពីយន្តការនៃការទទួលបណ្តឹងរបស់ក្រសួងអធិការកិច្ច

- រៀបចំកន្លែងទទួលបណ្តឹងឱ្យបានសមស្រប សម្រាប់ទទួលសាធារណជនដែលមកដាក់ពាក្យបណ្តឹង ដើម្បីធានានូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ក្នុងការងារបណ្តឹង

- ពង្រឹងនីតិវិធីនៃការដោះស្រាយបណ្តឹង ដើម្បីកំណត់អំពីគោលការណ៍ច្បាស់លាស់ ពីរបៀបរបប នៃការដោះស្រាយបណ្តឹងឱ្យបានឆាប់រហ័ស និងបង្កើនជំនឿទុកចិត្តពីគ្រប់ភាគីពាក់ព័ន្ធ សំដៅពង្រឹងប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹង

- ពង្រឹងយន្តការដោះស្រាយពាក្យបណ្តឹងឱ្យមានប្រសិទ្ធភាពខ្ពស់

- ពង្រឹងសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីដោះស្រាយបណ្តឹង ដោយត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងអនុវត្តតួនាទីឱ្យបានទូលំទូលាយ ស្មើភាព មិនរើសអើង ប្រកបដោយភាពទន់ភ្លន់តែម៉ឺងម៉ាត់ និងផ្អែកលើច្បាប់ ស្របតាមគោលការណ៍ (១) តម្លាភាព (២) មិនលម្អៀង (៣) សុចរិតភាព (៤) ប្រសិទ្ធភាព និង(៥) ការសម្ងាត់។ ក្នុងន័យនេះ ក្រសួងអធិការកិច្ចបានដាក់ចេញនូវវិធានការគន្លឹះពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីដោះស្រាយបណ្តឹង ដោយរៀបចំឯកសារក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីដោះស្រាយបណ្តឹង

- ពង្រឹងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធដូចជា ដើមបណ្តឹង ចុងចម្លើយ សាក្សី អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ ដើម្បីគាំទ្រដល់ដំណើរការដោះស្រាយបណ្តឹង។ ហេតុនេះ ក្រសួងអធិការកិច្ចបានដាក់ចេញនូវវិធានការពង្រឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ក្នុងគោលបំណងជំរុញ ពន្លឿនការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាពខ្ពស់

- ពង្រឹងយន្តការតាមដានការអនុវត្តសេចក្តីសម្រេចរបស់ក្រសួង ក្នុងការងារបណ្តឹង ជាបន្តរហូតដល់បណ្តឹងនោះ សម្រេចជាស្ថាពរ ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការពារផលប្រយោជន៍ជូនភាគីពាក់ព័ន្ធ

- ផ្សព្វផ្សាយឱ្យសាធារណជនបានយល់ដឹងពីមុខងារដោះស្រាយបណ្តឹងរបស់ក្រសួងអធិការកិច្ចឱ្យបានទូលំទូលាយ។

## ៤.៥. ការពង្រឹងការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

ក្រសួងបានដាក់ចេញទិសដៅការងារសំខាន់ៗ ដើម្បីពង្រឹងការងារអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ ដែលផ្អែកលើគោលដៅយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន៖ (១)ពង្រឹងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយច្បាប់ (២)ពង្រឹងប្រសិទ្ធភាពនៃការរៀបចំវេទិកាសាធារណៈ (៣)ពង្រឹងប្រសិទ្ធភាពនៃការវិភាគតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងស្ទង់មតិក្នុងដំណើរការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ (៤) ពង្រឹងការគិតគូរឱ្យ បានគ្រប់ជ្រុងជ្រោយលើមូលដ្ឋានក្នុងការកំណត់លិខិតបទដ្ឋានគតិយុត្ត ប្រធានបទ និងគោលដៅអាទិភាព ក្នុងការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ និង(៥)ជំរុញការផ្សព្វផ្សាយ និងពន្យល់អំពីសារៈសំខាន់ នៃចំណេះដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តឱ្យបានទូលំទូលាយ ដូចខាងក្រោម៖

- ជំរុញ និងពង្រឹងយន្តការវិភាគវាយតម្លៃ និងស្ទង់មតិក្នុងដំណើរការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

- កំណត់ឱ្យបានច្បាស់លាស់នូវអាទិភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងប្រធានបទ និងគោលដៅក្នុងការអប់រំផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ

- ជំរុញការចូលរួម និងការយល់ដឹងពីសារៈសំខាន់នៃការអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈរបស់ក្រសួងអធិការកិច្ចឱ្យបានទូលំទូលាយ ជាពិសេស នៅតាមគោលដៅអាទិភាព

- ជំរុញ និងពង្រឹងការរៀបចំផែនការនិងកម្មវិធីច្បាស់លាស់ និងកំណត់វិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិតសម្រាប់ការអប់រំផ្សព្វផ្សាយច្បាប់និងវេទិកាសាធារណៈ

- បង្កើនមធ្យោបាយក្នុងការអប់រំផ្សព្វផ្សាយច្បាប់ តាមរយៈការផលិតនិងថតស្ប៉ត វីដេអូ បទសម្ភាសន៍ និងមធ្យោបាយសមស្របនានា តាមភាពជាក់ស្ដែង

- ជំរុញ និងពង្រឹងកិច្ចសហការ និងការគាំទ្រតាមគ្រប់រូបភាពជាមួយក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គភាពពាក់ព័ន្ធ និងដៃគូនានា

- ពង្រឹងនូវសមត្ថភាពមន្ត្រីលើជំនាញផ្សព្វផ្សាយច្បាប់ឱ្យមានប្រសិទ្ធភាព។

## ៤.៦. ការជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ក្រសួងបានដាក់ចេញទិសដៅការងារសំខាន់ៗ ដើម្បីពង្រឹងការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលផ្អែកលើគោលដៅយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន ៖ (១)ពង្រឹងប្រសិទ្ធភាពនៃយន្តការរៀបចំលិខិត បទដ្ឋានគតិយុត្ត និង(២)ជំរុញការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រសិទ្ធភាព និងសុខដុមនីយកម្មនៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអធិការកិច្ច ដូចខាងក្រោម៖

- ជំរុញបញ្ចប់សេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ចក្នុងឆ្នាំ២០២៥

- បន្តចូលរួមសិក្សាស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធនឹងការរៀបចំសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តចាំបាច់របស់ក្រសួង កិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃពង្រឹងយន្តការសិក្សាស្រាវជ្រាវ និងចងក្រងទិន្នន័យសម្រាប់គាំទ្រការរៀបចំលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងកៀរគរការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស

- បន្តជំរុញកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងគ្រប់ភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាប្រឈម និងពន្លឿនការរៀបចំលិខិតបទដ្ឋានគតិយុត្ត

- ការរៀបចំរចនាសម្ព័ន្ធរឹងមាំនិងប្រទាក់ក្រឡា មានធនធានមនុស្ស និងធនធានថវិកា សម្ភារៈសម្រាប់លើកទឹកចិត្តនិងគាំទ្រ

- ពង្រឹងយន្តការគាំទ្រ ការកំណត់គោលនយោបាយលើវិស័យអធិការកិច្ច ដែលអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ ដោយឈរលើមូលដ្ឋានកែទម្រង់មួយដ៏ប្រាកដប្រជា ផ្អែកតាមការស្រាវជ្រាវ បទពិសោធ និងផ្អែកតាមស្ថានភាព និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងជំរុញការរៀបចំលិខិត បទដ្ឋានដែលជាអាទិភាពសម្រាប់គាំទ្រដល់ការអនុវត្តមុខងារស្នូលរបស់ក្រសួងអធិការកិច្ច រួមមាន ការងារអធិការកិច្ច ការងារដោះស្រាយបណ្ដឹង ការងារតាមដានការអនុវត្តច្បាប់ និងការងារផ្សព្វផ្សាយច្បាប់ និងវេទិកាសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់វិស័យអធិការកិច្ច

- រៀបចំវិធាន និងនីតិវិធីប្រតិបត្តិ (SOP) សម្រាប់អនុវត្តមុខងារស្នូល របស់ក្រសួងអធិការកិច្ចរួមមាន៖ (១) ការងារអធិការកិច្ច (២) ការងារតាមដានការអនុវត្តច្បាប់ និង(៣) ការដោះស្រាយបណ្ដឹង។

- រៀបចំទស្សនាទានស្ដីពីអធិការកិច្ច

- ជំរុញរៀបចំគោលនយោបាយជាតិស្ដីពីអធិការកិច្ច

- រៀបចំលិខិតបទដ្ឋានគតិយុត្តអាទិភាពគាំទ្រមុខងារស្នូលសំខាន់ៗរបស់ក្រសួងអធិការកិច្ច មានជាអាទិ៍ ដូចខាងក្រោម៖

- អនុក្រឹត្យស្ដីពីការបង្កើតមន្ទីរអធិការកិច្ចរាជធានី ខេត្ត
- អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត
- អនុក្រឹត្យស្ដីពីឯកសណ្ឋាន និងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ច

- អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិមន្ត្រីអធិការកិច្ច
- ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះអង្គភាពចំណុះក្រសួងអធិការកិច្ច
- ប្រកាសស្តីពីការបែងចែកក្រសួង ស្ថាប័ន តាមវិស័យក្នុងការធ្វើអធិការកិច្ច និងការកំណត់សមត្ថកិច្ច របស់នាយកដ្ឋានតាមដានការអនុវត្តច្បាប់ ចំណុះអគ្គនាយកដ្ឋានអធិការកិច្ច
- ប្រកាសស្តីពីរូបសញ្ញា និងត្រារបស់វិទ្យាស្ថានជាតិអធិការកិច្ច
- សេចក្តីណែនាំស្តីពីការប្រើប្រាស់រូបសញ្ញា និងត្រារបស់មន្ទីរអធិការកិច្ចរាជធានី ខេត្ត បណ្តោះអាសន្ន
- បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូអធិការកិច្ច និងតាមដានការអនុវត្តច្បាប់
- ប្រកាសស្តីពីក្រមសីលធម៌មន្ត្រីដោះស្រាយបណ្តឹងនិងអង្កេតស្រាវជ្រាវ
- បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈប្រតិភូដោះស្រាយបណ្តឹង និងអង្កេតស្រាវជ្រាវ។

## ៤.៧. ការជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន

ក្រសួងបានដាក់ចេញទិសដៅការងារសំខាន់ៗ ដើម្បីជំរុញ និងបង្កើនសមត្ថភាពស្ថាប័ន ដែលផ្អែកលើគោលដៅយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន៖ (១)លើកកម្ពស់សមត្ថភាព និងការធ្វើទំនើបកម្ម ស្ថាប័ន (២) ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ធនធានមនុស្ស ៣)អភិវឌ្ឍធនធានមនុស្ស ឈានទៅកសាងមូលធនមនុស្សប្រកបដោយគុណវុឌ្ឍិ (៤)ពង្រឹងយន្តការវាយតម្លៃលទ្ធផលការងារ និងជំរុញប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ដូចខាងក្រោម៖

**ក. ការងាររដ្ឋបាល**

- បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ ដោយសម្រួលលំហូរនៃឯកសារឱ្យបានឆាប់រហ័ស និងទាន់ពេល។

- បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

**ខ.ការងារបុគ្គលិក និងធនធានមនុស្ស**

- បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

- ការជំរុញនិងពង្រឹងប្រសិទ្ធភាពបណ្តុះបណ្តាលក្នុងវិស័យអធិការកិច្ចឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង, ពង្រឹងការអនុវត្តច្បាប់និងក្រមសីលធម៌វិជ្ជាជីវៈនិងវិន័យរបស់មន្ត្រីរាជការ ពង្រឹងវិធានការ វិន័យនិងយន្តការទណ្ឌកម្មចំពោះមន្ត្រីដែលមានកំហុស

- បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ របស់រាជរដ្ឋាភិបាល

- បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ

- ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី ខេត្ត ឱ្យបានទាន់ពេលវេលា។

**គ.ការងារហិរញ្ញវត្ថុ និងលទ្ធកម្ម**

ដើម្បីឈានទៅសម្រេចលទ្ធផលការងារជូនរាជរដ្ឋាភិបាល មន្ត្រីអធិការកិច្ចគួរត្រូវផ្តល់ជូនប្រាក់បៀវត្សខ្ពស់ និងផ្តល់ការលើកទឹកចិត្ត ជាប្រាក់រង្វាន់ ប្រចាំខែ ឬផ្អែកតាមលទ្ធផលការងារ ដើម្បីលើកទឹកចិត្ត ដល់មន្ត្រីដែលបំពេញការងារល្អ។

- បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់បៀវត្សដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

- ត្រៀមអង្គភាពថវិកាថ្មីស្របទៅតាមរចនាសម្ព័ន្ធថ្មីរបស់ក្រសួងស្របតាមអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច ជាពិសេសផ្តោតលើគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព សកម្មភាព សូចនាករ និងសមិទ្ធកម្ម។

- ត្រៀមពង្រឹងអង្គភាពថវិកាទាំងអស់ លើផ្នែកបច្ចេកទេស ដើម្បីឈានទៅអនុវត្តអង្គភាពថវិកា អាណាប័កផ្ទេរសិទ្ធិពេញលេញ នៅឆ្នាំ២០២៦។

- រៀបចំគម្រោងលទ្ធកម្មឱ្យបានល្អ ជាពិសេស ក្រសួងត្រូវយកចិត្តទុកដាក់សំខាន់លើគម្រោងទិញដែលជាតម្រូវការអាទិភាព ដែលមានចែងក្នុងការប្រឈមដែលបានរៀបរាប់ខាងលើ។

**ឃ. ការងារ គោលនយោបាយ និងផែនការ និងស្ថិតិ**

- រៀបចំកែសម្រួល និងបន្ថែមគម្រោងថ្មីៗមួយចំនួនលើគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២៥-២០២៧ របស់ក្រសួងអធិការកិច្ច

- រៀបចំសំណើសុំធ្វើបច្ចុប្បន្នភាព និងផ្តល់ធាតុចូលឡើងវិញ និងបន្តរៀបចំកែសម្រួល និងបន្ថែមធាតុចូលថ្មីៗមួយចំនួនលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផយអជ) ឆ្នាំ២០២៤-២០២៨ របស់ក្រសួងអធិការកិច្ច ដើម្បីបោះពុម្ពជាសៀវភៅ ចែកជូនថ្នាក់ដឹកនាំក្រសួង

- បន្តរៀបចំធាតុចូល សម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ឆ្នាំ២០២៤-២០៣០ ដើម្បីអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍ

- បន្តរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២៥-២០២៧ របស់ក្រសួងអធិការកិច្ច ធ្វើជាសៀវភៅ ដើម្បីចែកជូនថ្នាក់ដឹកនាំក្រសួង

- រៀបចំបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២៥-២០២៧ និងគម្រោងថវិកាប្រចាំឆ្នាំ ២០២៥ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត និងធ្វើផែនការយុទ្ធសាស្ត្រថវិកា២០២៥-២០២៧ និងចូលរួមធ្វើគម្រោងថវិកាប្រចាំឆ្នាំ២០២៦ របស់ក្រសួង

- បន្តរៀបចំកែសម្រួលធាតុចូលសូចនាករសមិទ្ធកម្ម និងគោលដៅគម្រោងថវិកាកម្មវិធីឆ្នាំ២០២៦ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី ខេត្ត

- បន្តរៀបចំបង្កើតក្រុមការងារថ្មី សម្រាប់ការពារកញ្ចប់ថវិកាប្រចាំឆ្នាំ២០២៦ របស់ក្រសួងអធិការកិច្ច ព្រមទាំងបណ្តាមន្ទីររាជធានី ខេត្ត

- បន្តរៀបចំកែសម្រួលធាតុចូលសូចនាករសមិទ្ធកម្ម និងគោលដៅគម្រោងថវិកាកម្មវិធីឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី ខេត្ត

- បន្តរៀបចំបញ្ចូលធាតុចូលសូចនាករសមិទ្ធកម្ម និងគោលដៅគម្រោងថវិកាកម្មវិធីឆ្នាំ២០២៥ របស់អគ្គ-នាយកដ្ឋាន ទាំងបី និងមន្ទីររាជធានី ខេត្ត

- កំពុងរៀបចំពិគ្រោះយោបល់កែសម្រួល និងបញ្ចូលសកម្មភាពថ្មីៗមួយចំនួនទៀត លើគម្រោងចងក្រងស្ថិតិទូទៅ របស់ក្រសួង

- ត្រៀមបន្តរៀបចំទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យរបស់ក្រសួងអធិការកិច្ចសម្រាប់ឆ្នាំ២០២៣

- បានរៀបចំបូកសរុប និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិផ្លូវការ ដែលមានការចាត់តាំងតាមវិស័យ ដែលទទួលបាន ពីថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត របស់ក្រសួងអធិការកិច្ចធ្វើជាសៀវភៅ សម្រាប់ចែកជូនថ្នាក់ដឹកនាំក្រសួង

- ត្រៀមរៀបចំបន្តគម្រោងផ្សេងៗ ដែលជាប្រតិបត្តិការ របស់ក្រសួងអធិការកិច្ច ឱ្យមានសុក្រឹតភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព

- បន្តរៀបចំកែសម្រួលជាតុចូលសូចនាករសមិទ្ធកម្ម និងគោលដៅគម្រោងកម្មវិធីឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានទាំង៣ និងមន្ទីររាជធានី ខេត្ត។

**ង. ការងារវិទ្យាស្ថានជាតិអធិការកិច្ច**

- ពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងអនុវត្តការងារតាមតួនាទីភារកិច្ចរបស់វិទ្យាស្ថាន
- អនុវត្តការងារតាមផែនការសកម្មភាព និងកម្មវិធីបណ្តុះបណ្តាលឆ្នាំ២០២៥
- បើកវគ្គបណ្តុះបណ្តាលជំនាន់៧ ចំនួន៦វគ្គ
- ចុះស្ទង់មតិអំពីវឌ្ឍនភាពការងាររបស់មន្ត្រី ដែលបានទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអធិការកិច្ច
- ជំរុញការស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យអធិការកិច្ច
- រៀបចំចងក្រង សៀវភៅកម្រងអនុសាសន៍ **សម្តេចធិបតី** និង ព្រឹត្តិបត្រអធិការកិច្ច
- ទំនាក់ទំនងដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការពីគ្រឹះស្ថានសិក្សា និងដៃគូអភិវឌ្ឍ។

**ច. ការងារសវនកម្មផ្ទៃក្នុង**

- អនុវត្តការងារសវនកម្មឱ្យមានប្រសិទ្ធភាពតាមផែនការដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០២៥

- ត្រៀមលក្ខណៈក្នុងការចាត់មន្ត្រីឱ្យចូលរួមក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ ជាពិសេសកម្មវិធីឌីជីថល ដែលរៀបចំដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងនាយកដ្ឋាន។

## ៤.៨. ការជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ

ក្រសួងបានដាក់ចេញទិសដៅការងារសំខាន់ៗ ដើម្បីជំរុញកិច្ចការសហប្រតិបត្តិការ និងភាពជាដៃគូ ដែលផ្អែកលើគោលដៅយុទ្ធសាស្ត្រគន្លឹះមួយចំនួន រួមមាន៖ (១)ជំរុញ និងពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ២)ជំរុញ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងពិភពលោក និង(៣)ជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ ដូចខាងក្រោម៖

- ក្រសួងត្រូវកសាងសមត្ថភាពនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដោយបញ្ជូនមន្ត្រីរាជការ,ក្នុងនាយកដ្ឋានទៅចូលរួម ការបណ្តុះបណ្តាល សិក្ខាសាលា និងវេទិកាចែករំលែកជំនាញនានា ជាពិសេស ផ្នែកទំនាក់ទំនងអន្តរជាតិ ពិធីការការទូត និងការប្រាស្រ័យទាក់ទង (Communication) លិខិតឆ្លើយឆ្លង (Correspondence) និងការសម្របសម្រួល (Coordination)

- ក្រសួងត្រូវជំរុញកិច្ចសហប្រតិបត្តិការស៊ីជម្រៅជាមួយដៃគូសំខាន់ៗ រួមមាន៖ (១) បន្តអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយវៀតណាម (២) ត្រៀមចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នា ជាមួយសាធារណរដ្ឋប្រជាមានិតចិន (៣) បន្តសហប្រតិបត្តិការជាមួយឥណ្ឌា (៤) បន្តសហការជាមួយស្ថានទូតផ្សេងៗទៀត ដើម្បីឈានទៅរកកិច្ចសហប្រតិបត្តិការ រួមមាន ថៃ ឥណ្ឌូណេស៊ី ហ្វីលីពីន ដើម្បីឈានទៅចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយស្ថាប័នដោះស្រាយបណ្តឹង (៥) បន្តសហការជាមួយស្ថានទូតហុងគ្រី និងតួកគីយេ ដើម្បី ពិនិត្យលទ្ធភាពផ្លាស់ប្តូរទស្សនកិច្ច និងដកស្រង់បទពិសោធ (៦) ពិនិត្យលទ្ធភាពសហការជាមួយប្រទេសផ្សេងទៀត ដូចជា ជប៉ុន កូរ៉េ សិង្ហបុរី តួកគីយេ។ល។ (៧) ជំរុញ និងពង្រឹងកិច្ចសហការជាមួយអង្គការអន្តរជាតិដូចជា UNDP, Asia Foundation និង អង្គការផ្សេងទៀត និង (៨) ជំរុញកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋដែលបានចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នា

- ជំរុញកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌតំបន់ (១) ជំរុញកិច្ចសហការ និងភាពជាដៃគូ ជាមួយ ASEAN Parties Against Corruption (ASEAN-PAC) (២) វេទិកាដោះស្រាយបណ្តឹងអាស៊ីអាគ្នេយ៍ South East Asian Ombudsman Forum (SEAOF)

- ជំរុញលើកកម្ពស់ការយល់ដឹងពីក្រសួងឱ្យកាន់តែច្រើន ជាពិសេសលទ្ធផលនៃការងារអធិការកិច្ច និងការផ្សព្វផ្សាយនានាតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (Media) បណ្តាញសង្គម និងវេទិកានានា

- បន្តកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានខុងជឺ អង្គការមូលនិធិអាស៊ី វិទ្យាស្ថានជាតិអធិការកិច្ច និងសម្របសម្រួលកិច្ចដំណើរការវគ្គបណ្តុះបណ្តាលភាសាចិន និងជំនាញផ្សេងៗទៀត ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងអធិការកិច្ច។

## ៤.៩. ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

ចាប់ពីឆ្នាំ២០២៥ ក្រសួងនឹងអនុវត្តភារកិច្ចទៅតាមរចនាសម្ព័ន្ធថ្មី ដូចដែលបានកំណត់ក្នុងអនុក្រឹត្យលេខ០៦ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច។ ស្របតាមការដាក់ចេញនូវដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន ៣ ៖ (១)លើកកម្ពស់ការអភិវឌ្ឍអង្គភាពឌីជីថល (២)លើកកម្ពស់អភិវឌ្ឍកម្មវិធីកុំព្យូទ័រ និងឧបករណ៍ឆ្លាតវៃ និង(៣)អភិវឌ្ឍនវានុវត្តន៍ឌីជីថល ក្នុងវិស័យអធិការកិច្ច ដូចខាងក្រោម៖

### ក.កសាងធនធានមនុស្សឌីជីថល

- កសាងសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៅក្នុងក្រសួង និងមន្ទីររាជធានី ខេត្ត ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល សម្រាប់បម្រើឱ្យការប្រើប្រាស់ ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋាភិបាលឌីជីថល

- បន្តស្នើសុំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើការរៀបចំវគ្គបណ្តុះបណ្តាលជំនាញឌីជីថល ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងអធិការកិច្ចជាបន្តបន្ទាប់

- ធ្វើការចែករំលែកចំណេះដឹង និងបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីការងារបរិវត្តកម្មឌីជីថលជូនមន្ត្រីរាជការដែលកំពុងបម្រើការលើការងារឌីជីថលនៅតាមអង្គភាពចំណុះក្រសួងអធិការកិច្ច។

### ខ.រៀបចំការិយាល័យឆ្លាតវៃ (ការិយាល័យឌីជីថល)

- រៀបចំនិងបំពាក់ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ឌីជីថល សុសវែរ និងប្រព័ន្ធព័ត៌មានចាំបាច់ ដើម្បីជួយសម្រួល និងលើកកម្ពស់ប្រសិទ្ធភាពការងារក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បន្តសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើការផ្គត់ផ្គង់សម្ភារៈបរិក្ខារអ៊ីនធឺណែត គ្រប់គ្រង និងថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្ដាញ និងអ៊ីនធឺណែត

- បន្តស្នើសុំសម្ភារៈបរិក្ខារបច្ចេកវិទ្យា និងសុសវែរ (Software) ដែលមានអាជ្ញាបណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សម្រាប់ផ្ដល់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការប្រើប្រាស់

- រៀបចំដំឡើងសុសវែមានអាជ្ញាបណ្ណត្រឹមត្រូវលើកុំព្យូទ័រ ឬឧបករណ៍ឌីជីថលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ សម្រាប់ប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ ដើម្បីធានាសុវត្ថិភាពពីការជ្រៀតជ្រែក លួចបន្លំឯកសារតាមរយៈការវាយប្រហារសាយប័រ (Cyber Attack) ក្នុងទម្រង់ណាមួយ

- បន្តសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំដាក់ QR Code ស្តង់ដា នៃថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh សម្រាប់ផ្ទៀងផ្ទាត់លើវិញ្ញាបនបត្ររបស់ក្រសួងអធិការកិច្ច

- ស្នើសុំថ្នាល និងកម្មវិធីរាជរដ្ឋាភិបាលឌីជីថលចំនួន៤ គឺថ្នាលផ្ទុកឯកសារសាធារណៈផ្លូវការ GO.GOV.KH ថ្នាលបង្កើតទម្រង់បែបបទអនឡាញ FORM.GOV.KH ថ្នាលបញ្ជូនសារពហុទិសដៅ NOMSA.GOV.KH និងកម្មវិធី បញ្ញាសប្បនិម្មិតបំប្លែងអត្ថបទទៅជាសំឡេង ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**គ.រៀបចំ និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងសន្តិសុខឌីជីថល**

- ការពារហេដ្ឋារចនាសម្ព័ន្ធឌីជីថលឱ្យបានគ្រប់ជ្រុងជ្រោយ ធានាសុវត្ថិភាព សន្តិសុខខ្ពស់លើការងារគ្រប់គ្រងប្រតិបត្តិការ និងការប្រើប្រាស់ប្រព័ន្ធឌីជីថល ដើម្បីកសាងភាពជឿទុកចិត្តលើប្រព័ន្ធរដ្ឋាភិបាលឌីជីថល

- បន្តសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំដាក់ QR Code ស្តង់ដា នៃថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh សម្រាប់ផ្ទៀងផ្ទាត់លើឯកសារ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងអធិការកិច្ច

- រៀបចំកែសម្រួលហេដ្ឋានរចនាសម្ព័ន្ធ និងបែងចែកសេវាអ៊ីនធឺណែតប្រើប្រាស់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទៅតាមតម្រូវការជាក់ស្តែង នៅទីស្ដីក្រសួងអធិការកិច្ច

- ធ្វើបច្ចុប្បន្នភាពគេហទំព័រ និងថ្នាល (Mobile App) របស់ក្រសួងអធិការកិច្ចជាប្រចាំ ដើម្បីធានាសុវត្ថិភាព និងឱ្យស្របទៅនឹងការវិវត្តន៍នៃបច្ចេកវិទ្យាឌីជីថលសកល

- ធ្វើការបញ្ចូលព័ត៌មាន និងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំក្រសួង និងឯកសារសំខាន់ៗក្នុងគេហទំព័រ និងថ្នាល (Mobile App) ផ្លូវការរបស់ក្រសួងអធិការកិច្ចឱ្យបានទាន់ពេលវេលា

- រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងកាលវិភាគកិច្ចប្រជុំ (Schedule Meeting Management Web Application) នៅទីស្ដីការក្រសួង។

## ៤.១០. ការងារផ្សេងៗ

### ៤.១០.១. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និង FMIS

- ក្នុងឆ្នាំ២០២៤នេះការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអធិការកិច្ច បានអនុវត្តស្របតាមផែនការ ដោយលទ្ធផលប្រចាំឆ្នាំ៩៥% ហើយកិច្ចការបន្ទាប់ត្រៀមអនុវត្តផែនការសកម្មភាពឆ្នាំ២០២៥ ដើម្បីឈានទៅសម្រេចគោលដៅដែលបានដាក់ចេញ

- ត្រៀមអនុវត្តនីតិវិធីអនុវត្តការងារលើគ្រប់មុខសញ្ញាចំណាយថវិកាចរន្ត នីតិវិធីបង្កើត កែសម្រួលរដ្ឋទេយ្យបុរេប្រទាន និងចលនាឥណទានថវិកាចរន្តតាម FMIS ទាំងស្រុង។

- ត្រៀមលក្ខណៈសម្បត្តិជំរុញ អង្គភាពថវិកាទាំងអស់ឱ្យក្លាយជាអង្គភាពថវិកាអាណាប័ក ផ្ទេរសិទ្ធិពេញលេញនៅឆ្នាំ២០២៦។

### ៤.១០.២. ការងារយេនឌ័រ

- រៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទៅក្នុងវិស័យអធិការកិច្ចឆ្នាំ ២០២៥-២០២៨

- រៀបចំវេទិកាសាធារណៈស្តីពីបញ្ហាប្រឈម និងសំណូមពររបស់មន្ត្រីរាជការជាស្ត្រី

- រៀបចំ បូកសរុបលទ្ធផលការងារយេនឌ័រប្រចាំឆ្នាំ២០២៥

- រៀបចំប្រតិភូក្រុមការងារយេនឌ័រក្រសួងចុះពិនិត្យ និងស្តាប់សំណូមពររបស់មន្ត្រីរាជការជាស្ត្រីនៅតាមរាជធានី ខេត្តទាំង២៥

- រៀបចំផែនការបង្កើតទារកដ្ឋាននៅក្រសួង។

### ៤.១០.៣. ការងារចងសម្ព័ន្ធមេត្រីភាព

- ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាពឱ្យកាន់តែជិតស្និទ្ធជាមួយកងវរសេនាតូចនគរបាលព្រំដែនឱ្យកាន់តែជិតស្និទ្ធ តាមរយៈការគាំទ្រនានា ដើម្បីរួមចំណែកថែរក្សាការពារបូរណភាពទឹកដី និងរក្សាបាននូវសុខសន្តិភាព ។

### ៤.១០.៤. ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

បន្តកែលម្អប្រព័ន្ធវាយតម្លៃ នៃគុណវុឌ្ឍិ ក្នុងការជ្រើសរើសថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួងក្នុងឆ្នាំ២០២៥ ដើម្បីស្នើសុំគ្រឿងឥស្សរិយយស តាមលំដាប់ឱ្យកាន់តែសុក្រឹត។

### ៤.១០.៥. ការងារក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួង

- បន្តអនុវត្តតួនាទី-ភារកិច្ចដូចមានចែងក្នុងប្រកាសលេខ០០៦/២៣ អ.ធ.ក.ប្រក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងអធិការកិច្ចស្តីពីការបង្កើតជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួងអធិការកិច្ច

- ត្រៀមចូលរួមប្រជុំការងារក្នុងក្រសួង និងអន្តរក្រសួងតាមការអញ្ជើញ និងតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួងអធិការកិច្ច

- ត្រៀមអនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួងអធិការកិច្ច។

## ជំពូក ៥. សេចក្តីសន្និដ្ឋាន

ក្រសួងអធិការកិច្ចដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងដំណើរការនៃកំណែទម្រង់សំខាន់ៗ ដើម្បីពង្រឹងនិងលើកកម្ពស់គុណភាពស្ថាប័នសាធារណៈ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព។

តាមរយៈការអនុវត្តមុខងារស្នូលទាំងបួន ក្រសួងអធិការកិច្ចសម្រេចបាននូវសមិទ្ធផលសំខាន់ៗរួមមានៈ (១) ក្រសួង ស្ថាប័ន និងអង្គភាពដែលរងអធិការកិច្ចបានយកចិត្តទុកដាក់អនុវត្តតួនាទី ភារកិច្ច ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បានចាត់វិធានការចំពោះអង្គភាពក្រោមអាណាព្យាបាល ឱ្យពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, បានកែលម្អនីតិវិធីនៃការផ្តល់សេវាសាធារណៈ និងបានពង្រឹងប្រសិទ្ធភាពការងារមន្ទីរ-អង្គភាព ព្រមទាំងបានចូលរួមចំណែក ក្នុងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាតិ និងបង្កើនចំណូលថវិកាជាតិផងដែរ។ (២) បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុង

ការបង្ការ ទប់ស្កាត់ កែលម្អ និងប្រឆាំងនឹងការបំពានអំណាច និងបាតុភាពអសកម្មនានាក្នុងសង្គម ដើម្បីពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ តម្លាភាព គណនេយ្យភាព អភិបាលកិច្ចល្អ និងយុត្តិធម៌ សង្គម តាមរយៈការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ជាពិសេសការសម្រុះសម្រួលបញ្ចប់វិវាទដោយ សន្តិវិធី ស្របតាមយុទ្ធសាស្ត្រ និងនយោបាយឈ្នះ-ឈ្នះ។ ជាក់ស្តែង ក្រសួងបានដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាពនិងទទួលបានភាពជោគជ័យ ទោះបីជាបណ្តឹងនោះមានភាពស្មុគស្មាញ រាំរ៉ៃជាច្រើនឆ្នាំ និងបានឆ្លងកាត់ការដោះស្រាយទាំងក្នុងប្រព័ន្ធតុលាការ និងយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការផ្សេងទៀត ក៏ដោយ។ (៣) បានរកឃើញថា មន្ត្រីជំនាញនៅតាមទីស្នាក់ការត្រួតពិនិត្យច្រកលើសចំនួនកំណត់ និងពុំបានត្រួតពិនិត្យរួមគ្នាចំពោះទំនិញ និងអ្នកដំណើរឆ្លងកាត់រវាងសមត្ថកិច្ចនគរបាលជាតិ និងសមត្ថកិច្ចគយ។ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនៅតាមខេត្តខ្លះ នៅមានចំណុចខ្វះខាតមួយចំនួនដែលមិនបានអនុវត្តឱ្យបានពេញលេញស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្រសួងអធិការកិច្ចបានធ្វើសេចក្តីជូនដំណឹង និងណែនាំទៅដល់ស្ថាប័នពាក់ព័ន្ធឱ្យកែលម្អនូវចំណុចខ្វះខាត ដែលបានរកឃើញ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ (៤) បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋនៅតាមតំបន់ងាយរងគ្រោះ ឱ្យយល់ដឹងអំពីច្បាប់ស្តីពីអភិបាលកិច្ច ព្រមទាំងកម្មវិធី និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ សំដៅកាត់បន្ថយ និងលុបបំបាត់អំពើហិង្សា ការរំលោភបំពានលើសិទ្ធិមនុស្ស និងចូលរួមដោះស្រាយរាល់បញ្ហា ប្រឈមផ្នែកច្បាប់ ដែលកើតមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និង(៥) បានខិតខំពង្រឹងប្រសិទ្ធភាព ការងារស្នូលទាំង៤ របស់ក្រសួង និងជំរុញនិងលើកកម្ពស់សមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស។ សមិទ្ធផលដែលសម្រេចបានទាំងនេះ ក៏បានកើតចេញពីការចូលរួមចំណែក និងការសហការល្អពីក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គភាពពាក់ព័ន្ធ ព្រមទាំងដៃគូជាតិនិងអន្តរជាតិនានា។

ទន្ទឹមនឹងសមិទ្ធផលជាច្រើនដែលសម្រេចបាន វិស័យអធិការកិច្ចមានបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានយុទ្ធសាស្ត្រគន្លឹះក្នុងការដោះស្រាយ ដើម្បីបន្តចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការពង្រឹងអភិបាលកិច្ច និងការលើកកម្ពស់ភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ។ ក្នុងន័យនេះ ក្រសួងអធិការកិច្ចក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ឯកឧត្តម **សុខ សូភេន** បានដាក់ចេញនូវទិសដៅ ការងារឆ្នាំ២០២៥ ព្រមជាមួយគ្នានឹងការដាក់ចេញយុទ្ធសាស្ត្រ «៣៤៨៤» ប្រកបដោយការគិតគូរគ្រប់ជ្រុងជ្រោយ ដែលមានលក្ខណៈប្រទាក់ក្រឡា ដើម្បីគាំទ្រដល់បេសកកម្មរបស់ក្រសួងអធិការកិច្ចក្នុងការដឹកនាំ និងគ្រប់គ្រង វិស័យអធិការកិច្ច សំដៅធ្វើឱ្យសង្គមកម្ពុជាមានភាពធន់ និងភាពប្រកួតប្រជែង ព្រមទាំងធ្វើឱ្យស្ថាប័នសាធារណៈ មានប្រសិទ្ធភាព គណនេយ្យភាពនិងបរិយាបន្ន និងធានាបាននូវយុត្តិធម៌ តម្លាភាព និងអភិបាលកិច្ចល្អ។

តាមរយៈទិសដៅការងារឆ្នាំ២០២៥ និងគោលដៅយុទ្ធសាស្ត្រ វិធានការគន្លឹះ ព្រមទាំងសកម្មភាពអាទិភាពសំខាន់ៗដែលបានដាក់ចេញខាងលើ នឹងធ្វើឱ្យបញ្ហាប្រឈមក្នុងវិស័យអធិការកិច្ចអាចត្រូវបានដោះស្រាយ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា សំដៅអភិវឌ្ឍវិស័យអធិការកិច្ច ឱ្យកាន់តែប្រសើរបន្ថែមទៀត ជាមួយនឹងការបន្តគាំទ្រពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ក្រសួងអធិការកិច្ច

Ministry of Inspection

# ទំនាក់ទំនង
# CONTACT


ក្រសួងអធិការកិច្ច
Ministry of Inspection

អគារលេខ ១២៦ ផ្លូវលេខ ៣ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

#126 St. 3 Sangkat Tonle Bassac
Khan Chamkarmon Phnom Penh

023 221 458
info@inspection.gov.kh


សម្រាប់ទាញយកឯកសារ
Access Documents

បណ្ដាញតេលេក្រាមរបស់ក្រសួងអធិការកិច្ច
Ministry of Inspection's Telegram

បណ្ដាញសង្គមឯកឧត្តមរដ្ឋមន្ត្រី
H.E. Minister Sok Soken

WWW.INSPECTION.GOV.KH